ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ សារសំខាន់នៃការយល់ដឹងពីរបបខ្មែរក្រហម និងការអប់រំពីអំពើប្រល័យពូជសាសន៍ សម្រាប់មនុស្សជំនាន់ក្រោយរបស់កម្ពុជា

◆ ភាគព្វកិច្ចយោធា និងប្រវត្តិសាស្ត្រយោធានៅក្នុងប្រទេសកម្ពុជា

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ៣១៧ ខែឧសភា ឆ្នាំ២០២៦

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

### សំបុត្រ


- អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម .......... ១
- សារសំខាន់នៃការយល់ដឹងពីរបបខ្មែរក្រហម .. ៣
- កាតព្វកិច្ចយោធា និងប្រវត្តិសាស្ត្រយោធា ..... ៤
- រដ្ឋាភិបាលថៃបានយកក្បួនយុទ្ធសាស្ត្រចាស់ ... ៨
- ប្រសិនបើថៃដកកម្លាំងយោធាត្រឡប់ទៅកាន់..... ៩
- នយោបាយប្រាកដនិយមរបស់ប្រទេសថៃ..... ១១
- ប្រទេសថៃ អះអាងថាខ្លួនធ្លាប់ជួយដល់កម្ពុជា.. ១៣


### ផ្នែកឯកសារ


- ទូរលេខ១៩ ចុះថ្ងៃទី១៥-៧-៧៧ ............ ១៤
- លាង គុង ៖ អនុវត្តផែនការ .................... ១៥
- ដួង គ្រេង ហៅ ហ៊ាន លេខាស្រុកមេសាង ... ១៨
- កែវ បូរ៉ែន ភ្នាក់ងារសេអ៊ីអា................... ២២


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


- រឿងរ៉ាវរបស់វីរកងទ័ព ព្រាំ ប៊ុន ឡាំង ......... ២៥
- «កូនប្រុសខ្ញុំបានសម្រាកជារៀងរហូត ........ ២៨
- ម៉ែន គា ៖ ខ្ញុំចូលហ្វឹកហាត់កងទ័ពដំបូង....... ៣១
- អាកាសយានដ្ឋានពោធិ៍ចិនតុង៖ ហេដ្ឋារចនាសម្ព័ន្ធមួយដែលតម្កល់ការចងចាំ .................... ៣៣
- គណៈស្ថាបត្យករកម្ពុជា បានដឹកនាំប្រតិភូទស្សនកិច្ច «ព្រះរាជបណ្ណាល័យហ្វូងម៉ែ» .... ៣៦
- ប្រវត្តិសាស្ត្រខ្មែរក្រហម និងសុខភាពរបស់.. ៣៨
- ពិធីបុណ្យកម្សាន្តភូមិរបស់ជនជាតិដើម ....... ៤១
- ក្រុមនិស្សិត ដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ ... ៤៤
- មជ្ឈមណ្ឌលឯកសារកម្ពុជាតាំងបង្ហាញ ...... ៤៨




អដ្ឋិធាតុរបស់ជនរងគ្រោះ ក្រោយរបបខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

### ផ្នែកវេទិកាពិភាក្សាសាធារណៈ


- ទិវាជាតិនៃការចងចាំ ២០ ឧសភា ២០២៦ ... ៥១
- សិស្សអនុវិទ្យាល័យត្រពាំងប្រិយ៍ ទស្សនកិច្ច... ៥៣
- ស្ត្រីជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម .. ៥៦


### ផ្នែកស្រាវជ្រាវរកគ្រួសារ


- ជាតិនេះ ខ្ញុំប៉ិះតែនឹងស្លាប់ចំនួន១៤លើក (ត) .. ៥៩



**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឱ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥៣.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



**ស្មេរលេខនេះ ៖** ឆាំង យុ, លី សុខឃាង, សួត វិចិត្រ, សា ហ៊ី, រីម ពេជ្រដារ៉ូ, អ៊ាន បញ្ញាឫទ្ធិ, សូ ហ្សារីណា, ឈុំ រ៉ា, ស្រេង លីដា, មេក វិន, ថុន ស្រីពេជ្រ និង សៀវ សុផុន

**អ្នកនិពន្ធ និងស្រាវជ្រាវ៖** មីន សាណាស់ **អ្នកបកប្រែ៖** លីម អ៊ិភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយករង៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនី ឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង



Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

**ឆាំង យុ**



*កុមារកំព្រាបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩ អង្គុយនៅមុខប្រាសាទអង្គរវត្ត។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា/ភ្នាក់ងារសារព័ត៌មានវៀតណាម)*

វីរបុរសសម័យទំនើបជារឿយៗត្រូវបានគេសម្គាល់ថាគឺជាបុគ្គលដែលល្បីល្បាញដោយសារតែទ្រព្យសម្បត្តិស្តុកស្តម្ភ ឬឋានៈខ្ពង់ខ្ពស់ក្នុងសង្គម។ ទោះជាយ៉ាងណាក៏ដោយ ទាំងអស់នេះគឺមិនមែនជានិយមន័យ ហើយក៏មិនមែនជាមាត្រាដ៏ត្រឹមត្រូវសម្រាប់វីរបុរសនោះទេ។ វីរបុរសពិតប្រាកដគឺជាបុគ្គលទាំងឡាយណាដែលបានបង្ហាញនូវភាពក្លាហាន ភាពជាអ្នកដឹកនាំ ការបម្រើការងារដោយមិនគិតពីផលប្រយោជន៍ផ្ទាល់ខ្លួន និងគុណសម្បត្តិដ៏ឧត្តុង្គឧត្តមផ្សេងទៀត ដោយមិនគិតពីផលចំណេញ រង្វាន់ ឬបុព្វសិទ្ធិអ្វីឡើយ។ អ្នករស់រានមានជីវិតពីសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងដំណាក់កាលផ្សេងទៀតនៃអំពើអមនុស្សធម៌ ឬការបង្អត់អាហារ និងសេរីភាពពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម គឺជាវីរបុរស។

អ្នករស់រានមានជីវិតទាំងនោះគឺជាវីរបុរស ពីព្រោះអ្នកទាំងអស់បានលះបង់ទាំងសុខភាព សុវត្ថិភាព សេចក្តីសុខផ្ទាល់ខ្លួន និងអាយុជីវិត ដោយមិនមែនដើម្បីស្វែងរកផលប្រយោជន៍ រង្វាន់ ឬបុព្វសិទ្ធិណាមួយឡើយ ប៉ុន្តែគឺដើម្បីតម្រូវការចាំបាច់សម្រាប់ការរស់រានមានជីវិតរបស់ក្រុមគ្រួសារ

សហគមន៍ និងជាតិសាសន៍របស់ខ្លួនៗ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជម្លោះផ្សេងទៀតនៃអំពើអមនុស្សធម៌ និងការបំផ្លិចបំផ្លាញ បាននិងកំពុងទទួលបន្ទុកយ៉ាងធ្ងន់ធ្ងរ ដែលមិនខុសពីវីរកងទ័ពនៅក្នុងជម្លោះប្រដាប់អាវុធនោះឡើយ។ អ្នករស់រានមានជីវិតជាច្រើននាក់ បានបង្ខំចិត្តលះបង់នូវសីលធម៌របស់ខ្លួនដើម្បីគ្រាន់តែអាចរស់ជីវិត។ អ្នករស់រានមានជីវិតជាច្រើន បានឃើញផ្ទាល់ភ្នែក ឬថែមទាំងបានចូលរួមនៅក្នុងសកម្មភាពដ៏ឃោរឃៅយង់ឃ្នង ដែលបានរួមចំណែក ឬធ្វើឱ្យអំពើអមនុស្សធម៌ដែលខ្លួនផ្ទាល់ជាជនរងគ្រោះនោះ កាន់តែបន្តអូសបន្លាយទៅមុខ។

ដោយសារតែមូលហេតុទាំងនេះហើយ ទើបអ្នករស់រានមានជីវិតជាច្រើនបានរែកពុនវិប្បដិសារីយ៉ាងជ្រាលជ្រៅ ដែលមិនអាចលុបបំបាត់បាន មិនត្រឹមតែចំពោះអ្វីដែលខ្លួនប្រហែលជាបានធ្វើតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចំពោះអ្វីដែលខ្លួនមានអារម្មណ៍ថាគួរតែបានធ្វើដើម្បីជួយដល់អ្នកដទៃ។

រឿងរ៉ាវរបស់អ្នករស់រានមានជីវិត បានបើកបង្ហាញឱ្យឃើញនូវទិដ្ឋភាពមួយដែលឆ្លុះបញ្ចាំងពីការតស៊ូប្រយុទ្ធរវាងវិប្បដិសារី និងកំហឹង ភាពទុក្ខសោក និងក្តីសង្ឃឹម ព្រមទាំងអំពើល្អ និងអំពើអាក្រក់ ដែលមិនត្រឹមតែជានិយមន័យនៃវីរបុរសពិតប្រាកដតែប៉ុណ្ណោះទេ ប៉ុន្តែក៏ជាតថភាពនៃស្ថានភាពពិភពលោករបស់យើងថែមទៀតផង។



សាលានៅខេត្តស្វាយរៀងបើកឱ្យសិស្សចូលរៀនវិញ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សារសំខាន់នៃការយល់ដឹងពីរបបខ្មែរក្រហម និងការអប់រំពីអំពើប្រល័យពូជសាសន៍ សម្រាប់មនុស្សជំនាន់ក្រោយរបស់កម្ពុជា

ឆាំង យុ



កុមារបដិវត្តន៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



សិស្សសាលាក្មេងៗមកអានសៀវភៅប្រវត្តិសាស្ត្រខ្មែរក្រហម និងទស្សនាវិថីស្វែងរកការពិតនៅមជ្ឈមណ្ឌលឯកសារកោះថ្ម ស្ថិតនៅឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមគឺជាប្រវត្តិសាស្ត្រមួយដែលពោរពេញទៅដោយអំពើអមនុស្សធម៌ជ្រុលនិយម និងការបំផ្លិចបំផ្លាញធ្ងន់ធ្ងរ ហើយផលវិបាកនៃរបបប្រល័យពូជសាសន៍នេះ នៅតែបន្តជះឥទ្ធិពលមកលើក្រុមគ្រួសារ សហគមន៍ និងប្រទេសជាតិកម្ពុជា ទាំងមូល មកទល់សព្វថ្ងៃនេះ។

មនុស្សជំនាន់ក្រោយ ចាំបាច់ត្រូវតែសិក្សារៀនសូត្រអំពីប្រវត្តិសាស្ត្រនេះ ដោយមិនមែនត្រឹមតែដើម្បីការចងចាំ និងផ្តល់កិត្តិយសជូនដល់ដូនតារបស់ខ្លួនប៉ុណ្ណោះទេ ក៏ប៉ុន្តែគឺដោយសារតែការសិក្សាអំពីប្រវត្តិសាស្ត្រនេះ នឹងជួយដល់មនុស្សជំនាន់ក្រោយឱ្យក្លាយទៅជាពលរដ្ឋបុគ្គល និងអ្នកដឹកនាំដ៏ប្រសើរ និងប្រកបដោយការទទួលខុសត្រូវខ្ពស់ជាងមុន នៅក្នុងពិភពលោកមួយដែលកាន់តែគ្រោះថ្នាក់ និងផុយស្រួយ។

គួរឱ្យស្តាយ ទោះបីជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាអំឡុងពេលដ៏សោកសង្រេងនេះ បានជួយស្រោចស្រង់សង្គមកម្ពុជាឱ្យរួចផុតពីការបំផ្លិចបំផ្លាញក៏ដោយ មនុស្សជំនាន់ក្រោយបែរជាកំពុងឈានជើងចូលទៅក្នុងពិភពលោកមួយដែលទទួលរងផលវិបាកបន្តឡើងដោយភាពល្ងង់ខ្លៅ ការព្រងើយកន្តើយ និងកង្វះខាតការអត់ឱនឱ្យគ្នាទៅវិញទៅមក រីតតែច្រើនឡើងៗទៅវិញ។

ការសិក្សារៀនសូត្រអំពីប្រវត្តិសាស្ត្រ គឺមិនមែនត្រឹមតែជាការអាន ឬការស្តាប់រឿងរ៉ាវ ឬព្រឹត្តិការណ៍ពីអតីតកាលនោះទេ ក៏ប៉ុន្តែវាគឺជាការដាស់តឿនឱ្យមានការប្រុងប្រយ័ត្ន និងការត្រៀមខ្លួនជាស្រេច ដើម្បីប្រឈមមុខនឹងឧបសគ្គនានា ទាំងនៅថ្ងៃនេះ និងថ្ងៃស្អែក។

# ភាគពុកិច្ចយោធា និងប្រវត្តិសាស្ត្រយោធា នៅក្នុងប្រទេសកម្ពុជា

**ឆាំង យុ**



កងទ័ពការពារព្រំដែនទស្សនកិច្ចមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ស្ថិតលើខ្នងភ្នំដងរែក ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កិច្ចការការពារជាតិ ទាមទារឱ្យរដ្ឋាភិបាលមានសមត្ថភាពក្នុងការកសាងកម្លាំងទ័ពឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាព ហើយដើម្បីសម្រេចបានគោលដៅនេះ ច្បាប់ស្តីពីកាតព្វកិច្ចយោធាគឺពិតជាចាំបាច់។ ទោះបីជាយ៉ាងណាក៏ដោយ មូលដ្ឋានគ្រឹះដ៏សំខាន់នៃកងកម្លាំងយោធាសម្រាប់ប្រទេសជាតិមួយមិនមែនផ្តោតត្រឹមតែទៅលើសមត្ថភាពក្នុងការកៀរគរប្រជាជនឱ្យចូលរួមបម្រើកងទ័ពតែប៉ុណ្ណោះទេ ប៉ុន្តែក៏សំដៅដល់ការកសាងនូវវិជ្ជាជីវៈយោធា សមត្ថភាព និងជំនាញដែលចាំបាច់ ក្នុងការចូលបម្រើភារកិច្ចក្នុងជួរកងទ័ពថែមទៀតផង។ ប្រវត្តិសាស្ត្រពិភពលោកអាចផ្តល់ជាឧទាហរណ៍យ៉ាងច្រើនសម្បូរបែបអំពីសមរភូមិ និងសង្គ្រាម ដែលត្រូវកំណត់ដោយជ័យមិនមែនដោយសារតែទំហំនៃកងកម្លាំងជើងគោក និងជើងទឹកនៅក្នុងសមរភូមិនោះទេ ប៉ុន្តែគឺដោយសារវិជ្ជាជីវៈ សមត្ថភាព និងជំនាញរបស់កងកម្លាំងប្រដាប់អាវុធទៅវិញទេ។

វិជ្ជាជីវៈ សមត្ថភាព និងជំនាញតែងត្រូវបានលើកយកមកពិពណ៌នាក្នុងរូបភាពនៃការច្នៃប្រឌិតផ្នែកបច្ចេកវិទ្យា។ ជាការពិតណាស់ បច្ចេកវិទ្យា ក៏ដូចជាទំហំនៃកងកម្លាំងយោធាដែរ គឺជាសមាសធាតុមួយនៅក្នុងការធ្វើសង្គ្រាម។ ប៉ុន្តែបច្ចេកវិទ្យាតែងតែត្រូវបានផ្តល់តម្លៃខ្ពស់ជ្រុល ប្ដុយល់ប្រឡុំអំពីសមត្ថភាពរបស់វា ក្នុងការជះឥទ្ធិពលទៅលើលទ្ធផលនៃជម្លោះយោធា ឬការប្រកួតប្រជែងជាយុទ្ធសាស្ត្រ។ ទំហំកងទ័ព និងបច្ចេកវិទ្យា គឺជាកត្តាសំខាន់ក្នុងកិច្ចការការពារជាតិ ប៉ុន្តែកត្តាទាំងនេះមិនមែនជាសមាសធាតុតែមួយគត់នោះទេ ហើយតាមពិតទៅ កត្តាទាំងពីរខាងលើមិនមែនជាធាតុផ្សំសំខាន់បំផុតនោះដែរ។

វិជ្ជាជីវៈយោធា គឺជាបណ្តុំនៃតម្លៃ បទដ្ឋាន និងឥរិយាបថរបស់កងកម្លាំងយោធា ដែលធ្វើឱ្យមន្ត្រីយោធារូបនោះមានសមត្ថភាព មានប្រសិទ្ធភាព និងមានការប្តេជ្ញាចិត្តចំពោះការប្រតិបត្តិវិន័យផ្ទាល់ខ្លួន ព្រមទាំងវប្បធម៌នៃការសិក្សារៀនសូត្រ។ កងទ័ពដែលមានវិជ្ជាជីវៈខ្ពស់ គឺជាកងទ័ពដែលកែលម្អ ពង្រឹង និងវិវត្តខ្លួនជាបន្តបន្ទាប់ ដើម្បីឆ្លើយតបទៅនឹងការគំរាមកំហែងនាពេលអនាគត។ រីឯសមត្ថភាពសំដៅទៅលើគុណសម្បត្តិនៃជំនាញបច្ចេកទេស ចំណេះដឹងផ្នែកយុទ្ធសាស្ត្រ និងសមត្ថភាពក្នុងការកំណត់អត្តសញ្ញាណ និងគ្រប់គ្រងហានិភ័យ ដែលទទួលបានតាមរយៈការហ្វឹកហ្វឺនយ៉ាងម៉ឺងម៉ាត់។ សមត្ថភាព ទាមទារឱ្យមានការហ្វឹកហ្វឺនដោយផ្អែកទៅលើក្រឹត្យក្រមច្បាស់លាស់ និងបទពិសោធន៍ជាក់ស្តែង។ ដោយឡែក ជំនាញយោធា សំដៅលើសមត្ថភាពរបស់កងកម្លាំងយោធាក្នុងការសម្រេចបាននូវលទ្ធផលដែលចង់បាន នៅក្នុងបរិយាកាសប្រតិបត្តិការជាក់លាក់ណាមួយ។ សរុបមក វិជ្ជាជីវៈយោធា សមត្ថភាព និងជំនាញយោធា មិនត្រឹមតែជាលក្ខណៈសម្បត្តិដ៏សំខាន់របស់កងទ័ពសម័យទំនើបតែប៉ុណ្ណោះទេ ប៉ុន្តែគឺជាអ្វីដែលកំណត់ថាកងកម្លាំងយោធា នឹងមានប្រៀបក្នុងការទទួលបានជោគជ័យជាងកងកម្លាំងដទៃទៀត ហើយកងទ័ពសហរដ្ឋអាមេរិកគឺជាឧទាហរណ៍បញ្ជាក់យ៉ាងច្បាស់អំពីចំណុចនេះ។

កងទ័ពសហរដ្ឋអាមេរិកបានក្លាយជាកងកម្លាំងយោធាដែលខ្លាំងពូកែបំផុត នៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ប៉ុន្តែកងទ័ពសហរដ្ឋអាមេរិកមិនមែនចាប់ផ្តើមឡើងដោយខ្លាំងពូកែភ្លាមៗនោះទេ។ នៅដើមដំបូងក្នុងប្រវត្តិសាស្ត្រ កងទ័ពសហរដ្ឋអាមេរិកមានលក្ខណៈទន់ខ្សោយ រាយប៉ាយ និងមានកម្រិតប៉ុណ្ណោះ បើប្រៀបធៀបទៅនឹងកងកម្លាំងរបស់មហាអំណាចពិភពលោកផ្សេងទៀត ដែលមានកងទ័ពជើងគោក និងកងទ័ពជើងទឹកអចិន្ត្រៃយ៍យ៉ាងច្រើនសន្ធឹកសន្ធាប់ក្នុងអំឡុងសតវត្សរ៍ទី១៨ និងទី១៩។ ក៏ប៉ុន្តែ កងទ័ពសហរដ្ឋអាមេរិកបានវិវត្តខ្លួនទៅតាមពេលវេលា ដែលនេះជាលទ្ធផលនៃតម្រូវការរបស់អាមេរិកក្នុងការមានកងទ័ពអចិន្ត្រៃយ៍ ដើម្បីគាំទ្រដល់ការបង្កើនទំនាក់ទំនងជាមួយពិភពលោក និងជាលទ្ធផលនៃការប្តេជ្ញាចិត្តក្នុងការរៀនសូត្រពីសង្គ្រាមពីមុនៗ ក៏ដូចជាមេរៀនពីអតីតកាល។

ការសិក្សាអំពីប្រវត្តិសាស្ត្រយោធា ប្រហែលជាកត្តាដ៏សំខាន់បំផុតមួយ ដែលបានជួយកំណត់រូបរាងនៃការរីកលូតលាស់ និងការផ្លាស់ប្តូរទម្រង់របស់កងទ័ពសហរដ្ឋអាមេរិកនៅក្នុងសតវត្សរ៍ទី២០។ ប្រវត្តិសាស្ត្រយោធា គឺជាឧបករណ៍មូលដ្ឋានដ៏ចាំបាច់សម្រាប់កសាងក្រឹត្យក្រមច្បាស់លាស់សម្រាប់យោធាអាមេរិក ការអប់រំវិជ្ជាជីវៈ និងសមត្ថភាពសម្របទៅតាមរចនាសម្ព័ន្ធស្ថាប័ន។ ផ្អែកលើបទពិសោធន៍ជាមេរៀនពីយុគសម័យណាប៉ូឡេអុង សង្គ្រាមស៊ីវិល និងរាល់យុទ្ធនាការ ឬជម្លោះបន្តបន្ទាប់នីមួយៗ ដែលសហរដ្ឋអាមេរិកបានចូលរួម ឬសង្កេតការណ៍ពីចម្ងាយ ស្ថាប័នយោធាអាមេរិក បានវិវត្តខ្លួនរហូតក្លាយជាស្ថាប័នដែលកំណត់នូវបទដ្ឋានសម្រាប់ពិភពលោកទាំងមូល។

ប្រវត្តិសាស្ត្រយោធាបានក្លាយជាសមាសភាពមិនអាចខ្វះបាន ក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈយោធាសម្រាប់នាយទាហាន និងពលទាហានជាន់

ខ្ពស់របស់សហរដ្ឋអាមេរិក ដោយសារប្រវត្តិសាស្ត្រត្រូវបានកំណត់ថាជាមធ្យោបាយក្នុងការប្រែក្លាយបទពិសោធន៍អតីតកាលឱ្យទៅជាការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈ។ មេរៀនពីអតីតកាលបានក្លាយជាមូលដ្ឋានគ្រឹះសម្រាប់យុទ្ធសាស្ត្រនាពេលអនាគត មិនត្រឹមតែក្នុងវិស័យយោធាតែប៉ុណ្ណោះទេ ក៏ប៉ុន្តែក្នុងវិស័យរដ្ឋបាលសាធារណៈ និងវិស័យផ្សេងៗទៀតនៃសង្គមថែមទៀតផង។ ប្រវត្តិសាស្ត្រមិនមែនជាមុខវិជ្ជាដ៏គួរឱ្យធុញទ្រាន់ ដែលទុកសម្រាប់តែអ្នកប្រាជ្ញ ឬអ្នកប្រវត្តិសាស្ត្រនោះឡើយ ផ្ទុយទៅវិញ ប្រវត្តិសាស្ត្រគឺជាសៀវភៅមគ្គុទ្ទេសក៍សម្រាប់យុទ្ធសាស្ត្រ ភាពជាអ្នកដឹកនាំ និងការអភិវឌ្ឍន៍ស្ថាប័ន។ នៅសហរដ្ឋអាមេរិក ការសិក្សាប្រវត្តិសាស្ត្រ ត្រូវបានគេមើលឃើញថាជាការខិតខំប្រឹងប្រែងដើម្បីកែលម្អជាប្រចាំ និងការផ្លាស់ប្តូររូបរាងនៃក្រឹត្យក្រមច្បាស់លាស់របស់យោធា។

ការខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងការបង្កើនសមត្ថភាពយោធាឱ្យកាន់តែខ្លាំងក្លាតាមរយៈច្បាប់ស្តីពីកាតព្វកិច្ចយោធានេះ គឺជាមធ្យោបាយឆ្ពោះទៅរកគោលដៅយុទ្ធសាស្ត្រដ៏សំខាន់មួយ ពោលគឺការពង្រឹងកិច្ចការការពារជាតិឱ្យកាន់តែរឹងមាំ។ ទោះបីជាយ៉ាងណាក៏ដោយ អមជាមួយនឹងសារសំខាន់នៃការកែលម្អសមត្ថភាពរបស់ប្រទេសជាតិក្នុងការកៀរគរប្រជាជន នៅមានចំណុចខ្វះខាតមួយក្នុងការអភិវឌ្ឍន៍យោធារបស់កម្ពុជា នោះគឺភាពកង្វះការប្តេជ្ញាចិត្តស្របគ្នាទៅនឹងការលើកកម្ពស់វិជ្ជាជីវៈ សមត្ថភាព និងជំនាញយោធារបស់កងកម្លាំងប្រដាប់អាវុធជាតិ។ កម្ពុជាយកសហរដ្ឋអាមេរិកជាឧទាហរណ៍ដ៏សំខាន់ ពាក់ព័ន្ធទៅនឹងវិធីសាស្ត្រដែលសហរដ្ឋអាមេរិកបានទាញយកប្រយោជន៍ពីប្រវត្តិសាស្ត្រយោធា ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងទាំងនេះ។ ការសិក្សាប្រវត្តិសាស្ត្រយោធាមិនមែនជាដំណោះស្រាយដ៏រហ័សទាន់ចិត្តក្នុងការធ្វើទំនើបកម្មយោធារបស់កម្ពុជានោះទេ។ ការសិក្សាប្រវត្តិសាស្ត្រយោធាមិនបង្កើតឱ្យមានផលចំណេញភ្លាមៗនៅក្នុងការអភិវឌ្ឍន៍បច្ចេកវិទ្យាណាមួយឡើយ ហើយក៏មិនបង្កើតឱ្យមានឥទ្ធិពលភ្លាមៗនៅក្នុងជម្លោះបច្ចុប្បន្នណាមួយដែរ។ ផ្ទុយទៅវិញ ការសិក្សាអំពីប្រវត្តិសាស្ត្រយោធា បង្កើតនូវឱកាសសម្រាប់ការជំរុញវិស័យ ទាំងនេះឱ្យរីកចម្រើនជាជំហានៗក្នុងរយៈពេលវែង។ នាយទាហានដែលសិក្សាប្រវត្តិសាស្ត្រ នឹងមានសមត្ថភាពខ្ពស់ជាងក្នុងការកំណត់អត្តសញ្ញាណ និងគ្រប់គ្រងហានិភ័យនៅលើសមរភូមិ បើប្រៀបធៀបទៅនឹងនាយទាហានដែលមិនធ្លាប់ពិនិត្យមើលបទពិសោធន៍របស់នាយទាហានក្នុងជម្លោះពីមុនៗ។ ដូចគ្នានេះដែរ ទាហានដែលបានសិក្សាប្រវត្តិសាស្ត្រ នឹងមើលឃើញពីឱកាសយុទ្ធសាស្ត្រ ឬស្មានដឹងពីសកម្មភាពរបស់កងកម្លាំងសត្រូវក្នុងរូបភាពខុសប្លែក និងរហ័សជាងទាហានដែលមិនធ្លាប់មានចំណេះដឹងផ្នែកប្រវត្តិសាស្ត្រ។ ជាចុងក្រោយ ទោះបីជាការសិក្សាប្រវត្តិសាស្ត្រមិនអាចបង្កើតនូវវឌ្ឍនភាពបច្ចេកវិទ្យាបានភ្លាមៗក៏ដោយ ប៉ុន្តែវាគឺជាមូលដ្ឋានគ្រឹះសម្រាប់កងទ័ពក្នុងការកំណត់អត្តសញ្ញាណ ការទទួលយក និងការប្រើប្រាស់បច្ចេកវិទ្យាទំនើបប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ បច្ចេកវិទ្យាមានប្រសិទ្ធភាពទៅបាន លុះត្រាតែវាត្រូវបានប្រើប្រាស់នៅលើសមរភូមិ ហើយជារឿយៗបច្ចេកវិទ្យាតែឯកឯង អាចនឹងមិនសូវជាមានតម្លៃ បើប្រៀបទៅនឹងប្រព័ន្ធក្រឹត្យក្រមច្បាស់លាស់ និងយុទ្ធសាស្ត្រដែលគាំទ្រដល់ការប្រើប្រាស់នៃបច្ចេកវិទ្យានោះ។

សន្តិសុខជាតិរបស់កម្ពុជា គឺពឹងផ្អែកលើសមត្ថភាពរបស់កម្ពុជាផ្ទាល់ ក្នុងការកៀរគរកម្លាំងយោធាឱ្យបានឆាប់រហ័សនៅខណៈពេលដែលប្រឈមទៅនឹងការគំរាមកំហែង ក៏ប៉ុន្តែការកៀរគរកម្លាំងយោធាឱ្យបានឆាប់រហ័សនេះ គ្រាន់តែជាផ្នែកមួយនៃបញ្ហាជារួមប៉ុណ្ណោះ ពោលគឺការផ្តោតទៅលើទំនើបកម្មនៃកងទ័ពកម្ពុជា។ កងទ័ពកម្ពុជាគួរតែយកប្រវត្តិសាស្ត្រយោធារបស់កងទ័ពសហរដ្ឋអាមេរិកជាគំរូ ដើម្បីធ្វើជាឧទាហរណ៍មួយ ស្តីពីរបៀបពង្រឹងវិជ្ជាជីវៈ សមត្ថភាព

និងជំនាញនៃកងកម្លាំងរបស់ខ្លួនៗ តាមរយៈមធ្យោបាយនេះ ប្រវត្តិសាស្ត្រយោធានឹងក្លាយជាគ្រឹះសម្រាប់ការបណ្តុះបណ្តាលអ្នកដឹកនាំជំនាន់ក្រោយ ការកែលម្អក្រឹត្យក្រមច្បាស់លាស់សម្រាប់យោធា និងការកសាងវប្បធម៌នៃការផ្លាស់ប្តូររូបរាងថ្មី ដែលប្រទេសជាតិត្រូវការសម្រាប់កិច្ចការការពារជាតិៗ តាមរយៈប្រវត្តិសាស្ត្រយោធា កម្ពុជានឹងមិនត្រឹមតែអាចត្រៀមលក្ខណៈបានល្អប្រសើរក្នុងការធ្វើសង្គ្រាមប៉ុណ្ណោះទេប៉ុន្តែអ្វីដែលសំខាន់ជាងនេះទៅទៀតនោះគឺកម្ពុជានឹងអាចត្រៀមលក្ខណៈបានកាន់តែល្អ ដើម្បីចៀសវាង និងបង្ការកុំឱ្យសង្គ្រាមកើតមានឡើងៗ

**លោក ឆាំង យុ** គឺជា នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងព្រះរាជបណ្ណាល័យ ហ្វូងម៉ែ ព្រម ទាំងជាឯកអគ្គរាជទូតអមព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រៗ លោកគឺជាអ្នកដឹកនាំលើការអប់រំ ការទប់ស្កាត់ និងការសិក្សាស្រាវជ្រាវពីអំពើប្រល័យពូជសាសន៍ៗ ក្នុងរយៈកាលប៉ុន្មានឆ្នាំចុងក្រោយនេះ លោកបានធ្វើការសិក្សាស្រាវជ្រាវស៊ីជម្រៅអំពីប្រវត្តិសាស្ត្រយោធា និងតំបន់ប្រវត្តិសាស្ត្រយោធារបស់កម្ពុជាជាមួយនឹងឯកឧត្តម នាយឧត្តមសេនីយ៍ ណឹម សុវត្ថិ នៃក្រសួងការពារជាតិកម្ពុជាៗ



កងទ័ពការពារព្រំដែនទស្សនកិច្ចមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ស្ថិតនៅលើខ្នងភ្នំដងរែក ខេត្តឧត្តរមានជ័យៗ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# រដ្ឋាភិបាលថៃបានយកក្បួនយុទ្ធសាស្ត្រចាស់ ដែលធ្លាប់ប្រតិបត្តិក្នុងសង្គ្រាមឈ្លានពាននានាពីអតីតកាល

ឆាំង យុ



ប្រាសាទតាមាន់ ស្ថិតនៅក្នុងស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ប្រាសាទតាក្របី ស្ថិតនៅក្នុងស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រដ្ឋាភិបាលថៃបានយកក្បួនយុទ្ធសាស្ត្រចាស់ ដែលធ្លាប់ប្រតិបត្តិក្នុងពេលសង្គ្រាមឈ្លានពាននានាពីអតីតកាល ជាពិសេសគឺនៅក្នុងសម័យសង្គ្រាមលោកលើកទី២មកអនុវត្តសាជាថ្មី។ ក្បួនយុទ្ធសាស្ត្របែបនេះ ត្រូវបានប្រើប្រាស់នាពេលដែលក្រុមមហាអំណាចជាសម្ព័ន្ធមិត្តរបស់អាល្លឺម៉ង់ រឹបអូសយកទីតាំងវប្បធម៌នានា ព្រមទាំងដកហូតយកវត្ថុបុរាណ និងទ្រព្យសម្បត្តិដែលមិនអាចកាត់ថ្លៃបាន ក្នុងគោលបំណងដើម្បីកេងប្រវ័ញ្ច ស្វែងរកប្រាក់ចំណេញក៏ដូចជាដើម្បីគាំទ្រដល់ទ្រឹស្តីប្រវត្តិសាស្ត្រផ្នែកនយោបាយ និងវប្បធម៌។

ទោះបីជាយ៉ាងនេះក៏ដោយ វាគឺជារឿងដែលគួរឱ្យភ្ញាក់ផ្អើលមួយ ដោយស្ថិតនៅក្នុងសម័យទំនើបទៅហើយ ប្រទេសថៃហ៊ានជ្រួលក្នុងការចាត់បញ្ចូលទីតាំងបេតិកភណ្ឌវប្បធម៌របស់ខ្មែរជារបស់ខ្លួនទៅវិញ បើទោះបីជាក្បួនយុទ្ធសាស្ត្ររបស់ខ្លួនធ្លាប់មានឈ្មោះអសោចនៅក្នុងប្រវត្តិសាស្ត្រយ៉ាងណាក្តី។ ខ្ញុំយល់ថា នាយកដ្ឋានវិចិត្រសិល្បៈថៃ ប្រហែលជាបានមើលរំលងនូវកាលៈទេសៈនេះ ឬមួយក៏ប្រហែលជាមានជំនឿថា ទង្វើខុសឆ្គងនេះនឹងត្រូវទទួលយកដោយប្រទេសកម្ពុជា និងពិភពលោក។

នាយកដ្ឋានវិចិត្រសិល្បៈថៃ គួរតែពិចារណាឡើងវិញនូវសកម្មភាពរបស់ខ្លួនទើបជាការប្រសើរ ព្រោះថាគ្មានទង្វើក្បត់ឧត្តមគតិណាដែលធ្ងន់ធ្ងរជាងការដែលស្ថាប័នវប្បធម៌របស់ប្រទេសមួយ បែរជាមានចេតនាដកហូតកេងប្រវ័ញ្ច ឬបំផ្លាញតម្លៃវត្ថុបុរាណវប្បធម៌ ដែលខ្លួនបានស្បថថានឹងថែរក្សា និងការពារនោះឡើយ មិនថាជាសម្បត្តិរបស់ជាតិសាសន៍ណាមួយនោះទេ។

# ប្រសិនបើថៃ ដកកម្លាំងយោធាត្រឡប់ទៅកាន់ទីតាំងឈរជើងរបស់ខ្លួនកាលពីមុនឆ្នាំ២០២៥

## តើនឹងមានអ្វីកើតឡើងចំពោះរដ្ឋាភិបាលរបស់ អានុទីន?

**ឆាំង យុ**



ប្រាសាទព្រះវិហារដែលរងការបំផ្លិចបំផ្លាញពីការផ្ទោះ និងទម្លាក់គ្រាប់ពីកងទ័ពថៃ នៅអំឡុងខែកក្កដា និងខែធ្នូ ឆ្នាំ២០២៥។ (រូបថត៖ តាំង វីនិត្យ)

វាគឺហាក់បីដូចជាគ្មានអ្វីជាមន្ទិលសង្ស័យនោះទេ ពីព្រោះថារដ្ឋាភិបាលរបស់លោក អានុទីន បានប្រកាន់យកវិធីសាស្ត្រជាតិនិយមដោយកម្លាំងយោធាឆ្លើយតបចំពោះជម្លោះព្រំដែន ដើម្បីក្តោបអំណាចនយោបាយរបស់ខ្លួន ហេតុនេះការដកកម្លាំងយោធាត្រឡប់ទៅវិញនឹងត្រូវក្រុមអភិរក្សនិយមថៃ ចាត់ទុកថាជាការក្បត់ឬការដកថយចេញពីគោលជំហរ ដែលផ្តល់ជាផលចំណេញចំពោះស្មារតីជាតិនិយមថៃ។

វាគឺអាចទៅរួច ដែលថារដ្ឋបាលរបស់លោក អានុទីន តាមពិតគឺមានបំណងចង់ដកកម្លាំងយោធារបស់ខ្លួនដោយសម្ងាត់ ដោយសារយល់ឃើញថាការដាក់ពង្រាយកម្លាំងយោធាទាំងនេះ ពុំបានបម្រើដល់គោលបំណងយុទ្ធសាស្ត្រយោធាចាំបាច់ណាមួយឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីផ្គាប់ចិត្តក្រុមអភិរក្សនិយមថៃ រដ្ឋាបាលរបស់លោក អានុទីន ត្រូវតែបង្ហាញថាខ្លួនអាចទទួលបានអ្វីជាថ្នូរពីការដក

កម្លាំងយោធា ដើម្បីអាចរក្សាអំណាចរបស់ខ្លួនបន្តទៀត។ វានៅតែមានភាពស្រពេចស្រពិលចំពោះអ្វីដែលរដ្ឋាភិបាលថៃទាមទារឱ្យភាគីកម្ពុជាបំពេញតាម ប៉ុន្តែប្រហែលជាដំណោះស្រាយ ឬច្រកចេញឆ្ពោះទៅបញ្ចប់ជម្លោះនេះ អាចត្រូវសំយោគចេញពីអ្វីដែលកើតមានក្នុងប្រវត្តិសាស្ត្រ។

ប្រវត្តិសាស្ត្រគឺមិនមែនជាការសិក្សាអំពីអង្គហេតុដែលហួសសម័យ មិនពាក់ព័ន្ធ ឬមិនចាំបាច់នោះឡើយ។ ផ្ទុយទៅវិញ ប្រវត្តិសាស្ត្រគឺជាការសិក្សាអំពីព្រឹត្តិការណ៍ កាលៈទេសៈ រចនាសម្ព័ន្ធ និងយុទ្ធសាស្ត្រទាំងឡាយណាដែលនៅមានប្រសិទ្ធភាព និងបន្តជះឥទ្ធិពលចំពោះបច្ចុប្បន្នភាពរបស់យើង។ ប្រវត្តិសាស្ត្រផ្តល់ជាឧទាហរណ៍រាប់មិនអស់ អំពីសង្គ្រាម ដែលផ្ទុះឡើងដោយសារតែរឿងតូចតាច ជាជាងដោយសារតែតម្រូវការរបស់យោធា អមជាមួយនឹងផលវិបាកធ្ងន់ធ្ងរ បន្សល់ទុកដោយភាគីមានអំណាចខ្ពស់ជាង ហើយដែលវាយតម្លៃខុសលើគូបដិបក្ខដែលតូចទាបជាងខ្លួន។ ឧទាហរណ៍ទាំងនេះគឺជាសក្ខីភាពនៃធម្មជាតិដែលមិនអាចប្រមើលទុកបាននៃសង្គ្រាម ព្រមទាំងផ្តល់ជាទស្សនយល់ឃើញចំពោះជម្លោះរវាងថៃនិងកម្ពុជា ដោយមិនត្រឹមតែបង្ហាញអំពីទម្រង់នៃការវិវត្តទៅនៃជម្លោះនេះតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរំលេចអំពីលទ្ធផលដែលជម្លោះនេះរុញច្រានទៅមុខដោយរបៀបណា ថែមទៀតផង។

នៅចុងបញ្ចប់ ការឈ្លានពានកាន់កាប់របស់ថៃមកលើតំបន់ព្រំដែនកម្ពុជា ប្រាកដណាស់នឹងបន្តអូសបន្លាយរហូតទាល់តែមានអន្តរាគមន៍ដោយផ្ទាល់ពីសំណាក់សហគមន៍អន្តរជាតិ ជាពិសេសសហរដ្ឋអាមេរិក។ ជាអកុសល ស្ថានភាពអន្តរជាតិកំពុងទទួលរងការប្រឈមនានា ដោយសារតែជម្លោះផ្សេងៗក្នុងពេលតែមួយ ហើយវានៅតែជាសំណួរថាតើវាមានឆន្ទៈនយោបាយ និង/ឬអំណាចការទូតគ្រប់គ្រាន់ដើម្បីជំរុញឱ្យមានការដកកម្លាំងយោធាថៃចេញពីដែនអធិបតេយ្យភាពរបស់កម្ពុជា តាមរយៈការចរចាដែរឬទេ ក្រៅពីកិច្ចព្រមព្រៀងសន្តិភាពអចិន្ត្រៃយ៍ដែលសម្រេចបាន។ ខ្ញុំគិតថា នេះគឺជាជម្លោះមួយ នឹងរុញច្រានទៅកាន់លទ្ធផល ដែលអាចទៅរួចចំនួនពីរគឺ៖ លទ្ធផលមួយគឺស្ថានភាពព្រំដែននៅតែទ្រឹងបែបនេះរហូតដល់ឆ្នាំ២០២៩ ឬលទ្ធផលមួយទៀតគឺជម្លោះព្រំដែននេះនឹងកើនកម្តៅ រីករាលដាលកាន់តែខ្លាំងជាងមុន។

ខ្ញុំមើលមិនឃើញពីលទ្ធផលអ្វីផ្សេងទៀតនោះទេ លុះត្រាតែមានអព្ភូតហេតុដ៏អស្ចារ្យអាចកើតមានឡើង។



ប្រាសាទព្រះវិហារដែលរងការបំផ្លិចបំផ្លាញពីការផ្លោងនិងទម្លាក់គ្រាប់ពីកងទ័ពថៃ នៅអំឡុងខែកក្កដា និងខែធ្នូ ឆ្នាំ២០២៥។ (រូបថត៖ តាំង រីនិត្យ)

# នយោបាយប្រាកដនិយមរបស់ប្រទេសថៃ

**ឆាំង យុ**



*លោក ឆាំង យុ នៅព្រះរាជបណ្ណាល័យ ហ្វូនម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

វាគឺពិតជាចាំបាច់ណាស់ក្នុងការចងចាំថា សកម្មភាពនេះអនុវត្តឡើងក្នុងទម្រង់ជាល្បែងអុកសាកល ដែលមានលក្ខណៈយុទ្ធសាស្ត្រ ពហុវិមាត្រ និងមានទំនាក់ទំនងប្រទាក់ក្រឡាគ្នា ហើយការផ្លាស់ប្តូរពីអនុស្សរណៈនៃការយោគយល់គ្នានេះ ទៅកាន់អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ គឺគ្រាន់តែជាការដើរជំហានមួយ ដែលដើរនៅក្នុងល្បែងអុកនៃការប្រកួតប្រជែងជាយុទ្ធសាស្ត្ររវាងប្រទេសថៃ និងប្រទេសកម្ពុជាតែប៉ុណ្ណោះ។

និយាយបានម៉្យាងទៀតថា សកម្មភាពរបស់រដ្ឋាភិបាលកម្ពុជាគឺត្រឹមតែជាវិធីសាស្ត្រឆ្លើយតបតែមួយបែបប៉ុណ្ណោះ ចំពោះការសម្រេចចិត្តនាពេលថ្មីៗរបស់រដ្ឋាភិបាលថៃក្នុងការដកខ្លួនចេញពីអនុស្សរណៈនៃការយោគយល់គ្នា។ បន្ថែមពីលើសកម្មភាពជាក់លាក់របស់កម្ពុជា គឺនៅមានព្រឹត្តិការណ៍ពាក់ព័ន្ធជាច្រើនទៀត ព្រមទាំងកាលៈទេសៈ និងជំហាននានាដែលភាគីទាំងពីរបាននិងកំពុងអនុវត្ត ពាក់ព័ន្ធនឹងច្បាប់សមុទ្រ ហើយដែលព្រឹត្តិការណ៍ទាំងនោះបង្ក

ជាឥទ្ធិពល និងជំរុញឱ្យមានការប្រែប្រួលចំពោះភាគីទាំងពីរទៅវិញទៅមក។

ជាឧទាហរណ៍ គឺការចល័តនិងការដាក់ពង្រាយកម្លាំងយោធានៅតាមបណ្តោយព្រំដែន ព្រមទាំងការត្រៀមលក្ខណៈរួចជាស្រេចនៃកងកម្លាំងយោធាជាដើម សុទ្ធសឹងតែជាសកម្មភាពដែលជះឥទ្ធិពលដល់ទំនាក់ទំនងនៃប្រទេសទាំងពីរ។ ក្រៅពីការធ្វើសកម្មភាពឬការឆ្លើយតបទៅនឹងភាគីម្ខាងទៀត ជួនកាលការសម្រេចចិត្តផ្សេងៗត្រូវបានធ្វើឡើងដើម្បីដោះស្រាយឬឆ្លើយតបទៅនឹងបញ្ហាផ្ទៃក្នុង ឬផលប្រយោជន៍ជាតិរៀងៗខ្លួន។ នេះគឺជាជម្រើសមួយ ដែលអាចយកមកពិចារណាបានថា សកម្មភាពរបស់រដ្ឋាភិបាលថៃពាក់ព័ន្ធនឹងអនុស្សរណៈនៃការយោគយល់គ្នានេះ អាចមានមូលហេតុចម្បង គឺមកពីការចង់បម្រើផលប្រយោជន៍ដល់ក្រុមឥស្សរជនជាន់ខ្ពស់របស់ថៃ ជាជាងការលៈទេសៈដែលពាក់ព័ន្ធនឹងកម្ពុជា។

ករណីនេះ ទំនងជាអាចកើតមាន ឬប្រហែលជាបង្ហាញចេញយ៉ាងពិតជាក់ស្តែងតែម្តង តាមរយៈការឈ្លានពានដោយប្រើប្រាស់កម្លាំងយោធារបស់ប្រទេសថៃមកលើដែនអធិបតេយ្យភាពកម្ពុជា (ក្នុងអំឡុងពេលខិតជិតមកដល់នៃការបោះឆ្នោតថ្នាក់ជាតិរបស់ថៃនាពេលកន្លងទៅ)។ នៅពេលដែលយើងឈប់ផ្តោតការពិនិត្យមើលតែទៅលើសកម្មភាពរបស់រដ្ឋាភិបាលថៃដាច់ដោយឡែកពីអ្វីៗផ្សេងទៀតដែលកំពុងកើតឡើង ហើយចាប់ផ្តើមស្វែងយល់ថាសកម្មភាពទាំងនោះគឺមានទំនាក់ទំនងប្រទាក់ក្រឡាគ្នា និងជាផ្នែកមួយនៃដំណើររឿងដ៏ទូលំទូលាយ ឬក៏អាចជាយុទ្ធសាស្ត្រដ៏ធំមួយ ពោលគឺជា «យុទ្ធសាស្ត្រគ្របលើរាល់យុទ្ធសាស្ត្រ» ឬ «យុទ្ធសាស្ត្រប្រតិដ្ឋសាច់រឿង» របស់ប្រទេសថៃ (សូមអានអត្ថបទរបស់បណ្ឌិត ប៉ាតាជិត តាងស៊ិនមុនខុង ស្តីពី «ការរៀបចំក្របខ័ណ្ឌថ្មីនៃអំពើប្រល័យពូជសាសន៍៖ យុទ្ធសាស្ត្រប្រតិដ្ឋសាច់រឿង និងនីត្យានុកូលភាពនៃការគាំទ្ររបស់ថៃចំពោះខ្មែរក្រហម») ទើបយើងអាចមើលឃើញនូវ «ទិដ្ឋភាពទាំងមូល ជាជាងផ្តោតតែទៅលើហេតុការណ៍ដាក់លាក់» ដូចសុភាសិតមួយថា «មើលទិដ្ឋភាពព្រៃជារួម ជាជាងមើលទៅលើដើមឈើតែប៉ុន្មានដើម»។



ប្រាសាទខ្នារ ស្ថិតនៅលើកំពូលភ្នំ ក្នុងភូមិអូរបាត់ដាវ សង្កាត់បន្សាយរាក់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប្រទេសថៃ អះអាងថាខ្លួនធ្លាប់ជួយដល់កម្ពុជា

**ឆាំង យុ**



ព្រះសម្មាសម្ពុទ្ធកំពុងសមាធិនៅក្រោមដើមពោធិ៍ ដោយមានទេវតាពីរអង្គសំពះប្រណម្យ គោរពបូជាព្រះអង្គដោយសេចក្តីជ្រះថ្លា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ការអះអាងរបស់ប្រទេសថៃ ដែលថាខ្លួនធ្លាប់ជួយដល់កម្ពុជា គឺជាការបំភ្លៃការពិតដោយចេតនា និងជាការក្លែងបន្លំប្រវត្តិសាស្ត្រ ដោយផ្អែកទៅលើមូលដ្ឋានចំនួនពីរ។

ទីមួយ) ការអះអាងបែបនេះ ជួយឱ្យយោធាថៃមានលេសប្រាប់ទៅកាន់ប្រជាជនថៃថា សកម្មភាពឈ្លានពានរបស់ខ្លួនប្រឆាំងនឹងប្រទេសជិតខាងគឺជារឿងសមហេតុសមផល។ យោធា និងរដ្ឋាភិបាលថៃត្រូវការការរៀបរាប់បែបនេះដើម្បីធានាថា ប្រជាជនថៃនឹងគាំទ្រជាបន្តបន្ទាប់ចំពោះយុទ្ធនាការយោធាប្រឆាំងនឹងកម្ពុជា។

ទីពីរ) ការរៀបរាប់បែបនេះ ដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយដល់រដ្ឋាភិបាលថៃក្នុងការកែប្រែការយល់ដឹងរបស់សហគមន៍អន្តរជាតិចំពោះជម្លោះព្រំដែននេះ។

សកម្មភាពរបស់ថៃប្រឆាំងនឹងកម្ពុជា នឹងហាក់ដូចជាមិនសូវខុសច្បាប់ និងមិនសូវអយុត្តិធម៌នោះទេ ប្រសិនបើភាគីថៃអាចដាក់បញ្ចូលសកម្មភាពឈ្លានពានទាំងអស់របស់ខ្លួនទៅក្នុងបរិបទនៃរឿងរ៉ាវមិនពិតរៀបរាប់អំពីការជួយ «ដោយមិនគិតប្រយោជន៍ផ្ទាល់ខ្លួន» របស់ថៃចំពោះកម្ពុជា។ វាជារឿងសំខាន់ដែលត្រូវចងចាំថា ព័ត៌មានគឺជាវិមាត្រដ៏សំខាន់មួយនៃសង្គ្រាម ហើយប្រវត្តិសាស្ត្រគឺជាសមាសធាតុដ៏សំខាន់នៃសមរភូមិព័ត៌មាន។

យោធា និងរដ្ឋាភិបាលថៃបានយល់ច្បាស់អំពីយុទ្ធសាស្ត្រនៃការប្រើប្រាស់ព័ត៌មានដើម្បីកំណត់ទិសដៅនៃសមរភូមិ ហើយភាគីថៃក៏បានទទួលស្គាល់ដែរថា ខ្លួនបានប្រើប្រាស់យុទ្ធសាស្ត្រនេះ ដែលពេលខ្លះប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុតទៀតផង។

កងពល បស្ទិម

ផ្នែក ន.ប

# ទូរលេខ១៦៩ ចុះថ្ងៃទី១៥-៧-៧៧
# សូមជូនសេចក្តីរាយការណ៍ប្រចាំអាទិត្យ

*ដកស្រង់ចេញពីឯកសារ D០១៧៨៦*

**សោម ប៊ុនថន**

១- សភាពការណ៍នៅតាមដែនគោក កោះ និងព្រំដែន ពុំមានសកម្មភាពអ្វីប្លែកទេ។ សភាពការណ៍នៅតាមដែនទឹក ខ្មាំងនៅតែបន្តបញ្ជូនកាណូតគ្រប់ធុនមកចាប់ត្រីក្នុងដែនសមុទ្ររបស់យើងក្នុង១អាទិត្យមានចំនួន ១៦២គ្រឿង ចម្ងាយពីកោះ ៩ ទៅ ១០គ.ម និងមានកាណូតតូចៗខ្លះទៀតប្រហែល ៥គ.ម ពីពយចាំយាមៗ ព្រមជាមួយនេះ មានកប៉ាល់យោធាខ្មាំង ១គ្រឿង កាលពីថ្ងៃ៨-៧ វាបើកកាត់មុខពយចាំយាម ចម្ងាយ ៥គ.ម ហើយសំដៅទៅមុខកោះយ៉ ចម្ងាយ ៨គ.ម ពីកោះ តែវាគ្មានធ្វើសកម្មភាពអ្វីមកយើងទេ។

២- សភាពការណ៍ចោរព្រៃបានបន្តរុករក និងត្រៀមស្ទាក់ជារៀងរាល់ថ្ងៃ គ្មានឃើញសកម្មភាពអ្វីប្លែកទេ នៅគ្រប់មុខសញ្ញាទាំងអស់តាមដែនគោក និងព្រំដែន។

៣- កាលពីថ្ងៃ ៩-៧ កងការពារកោះយើង បានបាញ់កាណូតនេសាទខ្មាំង១គ្រឿង មានចម្ងាយពីពយចាំយាម ៩០០ម ធ្វើឱ្យទូករបស់ខ្មាំងត្រូវខូចខាតជាដំណំ។

មកដល់ថ្ងៃទី១១-៧ កងល្បាតដើងទឹកយើង បានជួបប្រទះទូករបស់ខ្មាំង ជាច្រើនគ្រឿង ចម្ងាយ ៦គ.ម ពីកោះយ៉ៗ ហើយចាប់បានកាណូតរបស់ខ្មាំងបាន ៤គ្រឿង មនុស្សលោតទម្លាក់ទឹកអស់ គ្មានចាប់បានទេ។ សភាពទាំងនេះ យើងគ្មានគ្រោះថ្នាក់អ្វីទេ។

ម.០៩

ទទួលម៉ោង ៣.៣០នាទី ល្ងាច

ថ្ងៃទី ១៥-៧-៧៧

ចម្លងជូនៈ

-បង ៨៩ -មន្ទីរ -ឯកសារ



កងទ័ពបដិវត្តន៍ខ្មែរក្រហមកំពុងដឹកជញ្ជូនកាំភ្លើងធំទៅសមរភូមិ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# លាង គុង ៖ អនុវត្តផែនការ «បង្កប់ស៊ីរូងផ្ទៃក្នុងបដិវត្តន៍កម្ពុជា»

លី សុខឃាង



រោងចក្រក្រឡឹងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

យុវជនខ្មែរកាត់ចិន-វៀតណាម លាង គុង ត្រូវបានអប់រំឱ្យចូលធ្វើសកម្មភាពក្បត់បដិវត្តន៍ខ្មែរក្រហម និង ខិតខំប្រមែប្រមូលកម្លាំងយុវជនអនិកជនចិន។ យុវជនអនិកជនចិនភាគច្រើនបាននិងកំពុងធ្វើការនៅតាមបណ្ដារោងចក្រ ឬមន្ទីរផ្សេងៗនៅភ្នំពេញ។ គុង ត្រូវបានបំពាក់បំប៉នឱ្យជឿថាជ័យជម្នះរបស់ខ្មែរក្រហមមិនមែនបានមកដោយសារកម្លាំងខ្មែរក្រហមនោះទេ ប៉ុន្តែកងកម្លាំងវៀតណាមទៅវិញទេដែលអាចធ្វើឱ្យខ្មែរក្រហមវាយឈ្នះលើរបប លន់ នល់។ គុង ក៏បានស្ដាប់ការប្រមើមើលអំពីអនាគតរបស់កម្ពុជា ដែលថាបក្សពលកររបស់វៀតណាមនឹងក្លាយជាបក្សតែមួយគត់ដែលអាចគ្រប់គ្រងបណ្ដាប្រទេសឥណ្ឌូចិនរួមមាន៖ កម្ពុជា វៀតណាម និង ឡាវ។ តែទោះយ៉ាងណាក៏ដោយ អង្គការខ្មែរក្រហមបានចាប់ខ្លួន គុង នៅក្នុងឆ្នាំ១៩៧៦ ដែលក្នុងចម្លើយសារភាពបានឆ្លើយដាក់យុវជនអនិកជនជាច្រើននាក់។ ខាងក្រោមនេះគឺជាសេចក្ដីសង្ខេបនៃចម្លើយសារភាពរបស់ លាង គុង។



*រោងចក្រតម្បាញនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

លាង គុង គឺជាយុវជនខ្មែរកាត់ចិន-វៀតណាម និងមានប្រពន្ធឈ្មោះ ខាត់ លន។ គុង មានអាយុ២៥ឆ្នាំ (១៩៧៦) ធ្វើការនៅរោងចក្រគ្រឿងដែកភាគនិរតី ចំណែក លន មានអាយុ២០ឆ្នាំ គឺជាកម្មកររោងចក្រតម្បាញតំបន់១៣ នៅក្នុងក្រុងតាកែវជាមួយគ្នា។

ឪពុករបស់គុង មានឈ្មោះ លាង កាច់ (ស្លាប់) គឺជាអនិកជនចិន និងមានទីកន្លែងកំណើតនៅភ្នំពេញ ហើយម្តាយឈ្មោះ ហ៊ុង ឡាន គឺជាជនជាតិវៀតណាម និងបានត្រឡប់ទៅរស់នៅក្នុងប្រទេសវៀតណាម ចាប់តាំងពីឆ្នាំ១៩៧២ មកម្ល៉េះ។ លាង គុង មានបងប្អូនបង្កើតចំនួន៥នាក់ (ប្រុស៣នាក់ និងស្រី២នាក់) រួមមាន៖ ១) លាង អ៊ាវម៉េង (ឡាវ លាង) ដែលត្រូវអង្គការចាប់ខ្លួន, ២) លាង អាយហ័រ (កម្មករជាប្រជាជន១៧ មេសា), ៣) លាង គុង (ផ្ទាល់), ៤) លាង ឈុន (ប្រុស), និង ៥) លាង ឆាយម៉េង (ស្រី)។ ប្អូនទី៤ និងទី៥ របស់គុង គឺ លាង ឈុន និង លាង ឆាយម៉េង បានចេញទៅរស់នៅជាមួយម្តាយនៅក្នុងប្រទេសវៀតណាម។

នៅចន្លោះឆ្នាំ១៩៦១ និង១៩៦៦ គុង បានរៀនបេះអក្សរខ្មែរខ្លះៗ និងរៀនភាសាចិននៅសាលាទួនហ៊ុ សាលាហ៊ីរខៀវ និងលានយ៉ូ នៅក្នុងទីក្រុងភ្នំពេញ។ បន្ទាប់ពីការរៀនសូត្រអស់រយៈពេល៥ឆ្នាំ គុង បានចាប់ផ្តើមធ្វើការងារនៅតាមទីកន្លែងផ្សេងៗ ដូចជារោងចក្រគ្រឿងដែកវល្លិ៍អាន និងវេង ហួតជាដើម។

នៅក្នុងឆ្នាំ១៩៧៣ គុង បានទទួលការអប់រំពីឡាវ ម៉ាក់ ដើម្បីបម្រើយួន ហើយប្រឆាំងនឹងបដិវត្តន៍កម្ពុជា។ គុង បានបញ្ជាក់ថា ម៉ាក់ បាននិយាយយ៉ាងច្រើននិងដដែលៗ អំពីជោគជ័យនៃការពង្រីកតំបន់រំដោះរបស់ខ្មែរក្រហម ហើយសង្ឃឹមថាចក្រពត្តិ និងបរិវារនឹងចាញ់សង្រ្គាមជាក់ជាពុំខាន។ ប៉ុន្តែ គុង បានកត់

*សម្គាល់ថា ម៉ាក់ បានសង្កត់ធ្ងន់ពីកម្លាំង និងឥទ្ធិពលរបស់វៀតណាម នៅក្នុងភាពជោគជ័យជាបន្តបន្ទាប់នេះ ហើយថាកម្លាំងបដិវត្តន៍របស់ខ្មែរក្រហម គឺជាកម្លាំងបន្ទាប់បន្សំ ដែលមិនអាចមានលទ្ធភាពវាយឈ្នះចក្រពត្តិទេ។ តុង បានចងចាំពាក្យ ម៉ាក់ ដែលនិយាយថា៖ «...មានតែវៀតណាមទេ ដែលយកជ័យជម្នះលើចក្រពត្តិអាមេរិក និងបរិវារក្បត់បាន ព្រោះគេធ្វើសង្គ្រាមយូរហើយ គេមានពិសោធន៍ច្រើន មានកម្លាំងខ្លាំង ថ្ងៃខាងមុខគេនឹងរំដោះប្រទេសយើងបានទាំងមូល»។*

*តុងបានបន្តទទួលការណែនាំពី ឡាវម៉ាក់អំពីរបៀបនៃការធ្វើបដិវត្តន៍តាមបែបវៀតណាម ដើម្បីរំដោះនិងកសាងប្រទេសជាតិ ហើយបដិវត្តន៍កម្ពុជាចៀសមិនផុតទេ ដែលត្រូវវៀតណាមគ្រប់គ្រងពីលើដដែល។ ភាពខុសគ្នារវាងបដិវត្តន៍ទាំងពីរបានបង្ហាញឱ្យឃើញថា បដិវត្តន៍កម្ពុជាមិនផ្តល់បុណ្យស័ក្តិ ប្រាក់ខែ និងការរស់នៅឱ្យបានសមរម្យឡើយ ចំណែកឯបដិវត្តន៍វៀតណាមមានទម្រង់ជាបដិវត្តន៍សង្គមនិយម ដែលផ្តល់ប្រាក់ខែដល់កម្មាភិបាល កម្មករ កងទ័ព និងជីវភាពរស់នៅល្អ។ ឡាវ ម៉ាក់ បានប្រាប់ តុង ទៀតថា៖ «...ថ្ងៃអនាគតទៅ ប្រទេសទាំងបីក្នុងឥណ្ឌូចិន គេកសាងទៅជាប្រទេសតែមួយ ក្រោមការគ្រប់គ្រងរបស់បក្សពលករវៀតណាម ក្នុងការកសាងរបៀបរបបរស់នៅប្រទេសទាំងបី ធ្វើតាមវៀតណាម»។ អាស្រ័យហេតុនេះហើយ តុង ត្រូវបានលើកទឹកចិត្តឱ្យគាំទ្រ និងធ្វើបដិវត្តន៍ជាមួយវៀតណាម ដែលនឹងផ្តល់ពន្លឺសម្រាប់អនាគត និងរុងរឿង។*

*ដើម្បីសម្រេចគោលបំណងនេះ តុង អនុវត្តផែនការ «បន្កប់ស៊ីរូងផ្ទៃក្នុងបដិវត្តន៍កម្ពុជា» បំផុសអប់រំប្រមែប្រមូលកម្លាំងប្រឆាំងបដិវត្តន៍កម្ពុជាឱ្យបានច្រើន និងឃោសនាអប់រំឱ្យមានជំនឿលើបដិវត្តន៍វៀតណាម។ តុងបាននិយាយទៀតថា ខ្សែបណ្តាញត្រូវចេះសាមគ្គីគ្នា និងធ្វើការឱ្យសកម្មដើម្បីកុំឱ្យមានការចាប់អារម្មណ៍ ប៉ុន្តែមិនត្រូវធ្វើចេះជាងគេពេកទេ។ តុង បានបង្គុលទៅកាន់ក្រុមគោលដៅអនិកជនចិន ដែលត្រូវឃោសនាអូសទាញឱ្យបានខ្លាំងជាងគេ។*

*តុង ត្រូវបានចាត់បញ្ជូនទៅកាន់តំបន់រំដោះ ដើម្បីទំនាក់ទំនងជាមួយបក្ខពួកម្នាក់ទៀតឈ្មោះ «ហួ» ដែលមានតួនាទីជាប្រធានមន្ទីរបច្ចេកទេស ភូមិភាគពិសេស។ តុង ក៏បានរៀបរាប់ឈ្មោះអនិកជនចិនចំនួន៥នាក់ផ្សេងទៀត ដែលជិតស្និទ្ធជាមួយ «ហួ» រួមមាន៖ លូ, លីវិន, ឆុង, ម៉េង, និងកង។ បើទោះបីជា តុង ត្រូវបាន «ហួ» ណែនាំឱ្យគោរពវិន័យរបស់អង្គការ តុង នៅតែទទួលបាននូវការក្រើនរំឭកឱ្យប្រយ័ត្នប្រយែង និងលាក់ការណ៍។*

*«ហួ» បានប្រាប់ តុង ថា៖ «យើងមកដំបូងគ្មានស្គាល់គេអញ្ចឹង មិនបាច់ធ្វើសកម្មភាពអ្វីទាំងអស់។ បើមានការណែនាំសឹមធ្វើ»។ តុង បាននិយាយថា «បង ហួ»បានអនុញ្ញាតច្បាប់ចំនួនកន្លះខែ ដើម្បីមកសួរសុខទុក្ខបងបង្កើតឈ្មោះ លាង ដែលធ្វើការនៅមន្ទីរបច្ចេកទេសម-២១១។ នៅទីនោះ តុង បានស្គាល់យុវជនអនិកជនចិនចំនួន៥នាក់ទៀត ដែលសុទ្ធសឹងតែជាខ្សែរយៈរបស់ ឡាវ ម៉ាក់។ យុវជនអនិកជនចិនទាំងនោះរួមមាន៖ សឹង, ទើ, ឈន, ដៃ, និងឈានដែលពីរនាក់ (សឹង និងទើ) ធ្វើការនៅមន្ទីរបច្ចេកទេសភូមិភាគពិសេស និងបីនាក់ទៀត (ឈន, ដៃ, និងឈាន) ធ្វើការផ្នែកបកប្រែភាសា នៅមន្ទីរម-២១១។ តុង ត្រូវបានចាប់ខ្លួន នៅក្នុងឆ្នាំ១៩៧៦។*

***កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខ J00២៥៦ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្ម យ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម។ ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ លាង តុង ពិតប្រាកដឬយ៉ាងណានោះទេ។***

# ដួង គ្រេង ហៅ ហ៊ាន លេខាស្រុកមេសាង

## តំបន់២០ ភូមិភាគបូព៌ា ទទួលបានសំបុត្រពីរលើកពី សោ ភឹម មុនឡើងទៅជួបមជ្ឈិមនៅភ្នំពេញ

*ដារ៉ារដ្ឋ មេត្តា*



*សូ វណ្ណា ហៅ សោ ភឹម (រូបឈរខាងមុខទីមួយ រាប់ពីឆ្វេង ក្នុងសម្លៀកបំពាក់ពណ៌ខ្មៅ) និងកងទ័ពខ្មែរក្រហមធ្វើដំណើរទស្សនកិច្ចទៅកាន់កងមួយនៃកងកម្លាំងប្រយុទ្ធស្ម័គ្រចិត្តកុម្មុយនីស្តរបស់វៀតណាម ក្នុងឆ្នាំ១៩៧៣។ រូបថតនេះត្រូវបានថតភ្លាមៗបន្ទាប់ពីកងខ្មាំងសម្ព័ន្ធចាប់ផ្ដើមធ្វើការវាយប្រហារទៅលើមូលដ្ឋានទ័ព ឃុំក្របៅ ក្នុងខេត្តកំពង់ចាម ដែលជាផ្នែកមួយនៃសង្គ្រាមស៊ីវិលប្រឆាំងនឹងរដ្ឋាភិបាលនៃរបបសាធារណរដ្ឋខ្មែរដឹកនាំដោយលោកសេនាប្រមុខ លន់ នល់។ ក្រោយមក សោ ភឹម បានក្លាយទៅជាលេខាបក្សកុម្មុយនីស្តកម្ពុជាប្រចាំភូមិភាគបូព៌ានៃរបបកម្ពុជាប្រជាធិបតេយ្យ។ សោ ភឹម បានធ្វើអត្តឃាតនៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៩៧៨។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា/ភ្នាក់ងារសារព័ត៌មានវៀតណាម)*

នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៧៨ ខ្ញុំបានទទួលសំបុត្រមួយច្បាប់ពីតាភឹម តាមរយៈឈ្មោះ ទុយ ដែលក្នុងន័យសំបុត្រសរសេរថា «ប្រតិបត្តិការកើតឡើងនេះ គឺខាងក្នុងធ្វើរដ្ឋប្រហារផ្ទៃក្នុងហើយស្នើឱ្យគ្រប់ស្រុកប្រមូលកម្លាំងយោធា ទាំងឈ្លបស្រុក ឈ្លបឃុំ ដែលមានប៉ុន្មាននៅខាងក្រោយ ត្រៀមទប់ទល់ការពារបក្សយើងឱ្យបាន»។ ក្នុងសំបុត្រគឺឱ្យខ្ញុំប្រមូលកម្លាំងត្រៀមនៅត្រង់ព្រំប្រទល់ស្រុកមេសាង និងតំបន់២៣ ការពារកម្លាំងមកពីស្វាយរៀង។ ប្រសិនបើឃើញកងទ័ពជិះឡានប្ញុរថក្រោះរបស់អង្គការចូលមក គឺត្រូវបាញ់។ នៅក្នុងថ្ងៃទី២៩ នេះ ខ្ញុំប្រមូលយុទ្ធនារីបានចំនួន២០០នាក់ និងប្រមូលកងឈ្លបគ្រប់ឃុំបានចំនួន៨០នាក់ មករៀបចំខ្សែត្រៀមនៅព្រំប្រទល់តំបន់២៣ ផ្លូវភ្ជាប់មកពីស្វាយរៀង ចាប់ពីភូមិសូរ ដល់ភូមិស្រះតាអឹម ចម្ងាយ

២គី ឡូម៉ែត្រ ដើម្បីការពារកម្លាំងបដិវត្តន៍។ ដល់ថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៧៨ ខ្ញុំបានទទួលសំបុត្រពី តាភឹម មួយច្បាប់ទៀតតាមរយៈឈ្មោះ ទុយ ដដែល ដែលសរសេរថា «កងកម្លាំងប្រដាប់អាវុធទាំងអស់ត្រូវផ្ទាកបាញ់គ្នា ប្រសិនបើគេបាញ់យើង ចាំយើងបាញ់តបតគេវិញ។ ប៉ុន្តែកុំឱ្យគេដកកាំភ្លើងបានហើយកុំឱ្យគេចាប់បានឱ្យសោះ។ ចាំខ្ញុំទៅភ្នំពេញដោះស្រាយរឿងនេះ»។ នៅខែឧសភា ឬ មិថុនា ឆ្នាំ១៩៧៨ សោ ភឹម ជួបសមមិត្តរិនដែលជាប្រធានកងពលទី៤របស់ភូមិភាគបូព៌ា ដោយចៃដន្យដែលកំពុងព្យាបាលជំងឺនៅមន្ទីរសេនាធិការក្នុងក្រុងព្រៃវែងថា «ខ្ញុំត្រូវធ្វើដំណើរទៅ ទីក្រុងភ្នំពេញដើម្បីដោះស្រាយបញ្ហាមួយចំនួនជាមួយមជ្ឈិម បើរយៈពេល១សប្តាហ៍បាត់ដំណឹងខ្ញុំមិនឃើញត្រឡប់មកវិញគឺខ្ញុំស្លាប់ហើយ រិន ឯងត្រូវចូលព្រៃតស៊ូ»។ ក្រោយមក សោ ភឹម លេខាភូមិភាគបូព៌ាបានធ្វើអត្តឃាតជាមួយកងការពាររបស់ខ្លួន បន្ទាប់ពីអស់លទ្ធភាពគេចខ្លួនពីកងទ័ពមជ្ឈិម។

ចំណែក បង ទុយ បានណែនាំខ្ញុំយកសារាចរនេះមកទាក់ទងជាមួយយោធាតំបន់២៤ រួមទាំងយោធាកងពល៧០៣ ដែលសហការគ្នាវាយខ្ញុំនៅព្រៃវែង ឱ្យឈប់បាញ់សិនចាំខាងលើអ្នកដោះស្រាយ។ ពេលនោះខ្ញុំបានយកសារាចរមកដល់ស្រុកបាភ្នំផ្ញើសំបុត្រនោះទៅឱ្យ បងចាន់ ហើយសន្តិសុខស្រុកបាភ្នំបានឃាត់ខ្ញុំនៅកន្លែងនោះ។ ដើម្បីបិតបាំងរឿងនេះខ្ញុំបានសារភាពថា ខ្ញុំមិនដឹងខាងណាខុស ខាងណាត្រូវទេ។ នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៨ បងចាន់ ប្រកាសថា «មានខ្មាំងធ្វើរដ្ឋប្រហារនៅភូមិភាគបូព៌ាក្នុងខែនេះ ដូច្នេះឱ្យខ្ញុំត្រឡប់ទៅស្រុកវិញប្រមូលកងទ័ព ហើយដកអាវុធឱ្យអស់។ ពេលនោះខ្ញុំសម្របខ្លួនចុះទៅធ្វើការតាមការណែនាំរបស់ បងចាន់។ នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ១៩៧៨ ស្រាប់តែមានកងទ័ពមកពីកងពល២៨០ចូលមកចាប់សន្តិសុខស្រុកមេសាងកម្ទេចចោល ហើយដោះលែងអ្នកទោសឱ្យដើរធ្វើបាតុកម្មពេញទាំងស្រុក និងចាប់ប្រធានសហករណ៍ ប្រធានភូមិ គណៈឃុំ និងអនុលេខាស្រុកកម្ទេចចោលអស់។ នៅពេលខ្ញុំឃើញសភាពការណ៍ដូច្នេះ នៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ១៩៧៨ ខ្ញុំរត់គេចមកនៅស្រុកបាភ្នំជាមួយឈ្មោះ ទុយ, ជា, ពេជ, ធី, វ៉ន ដែលអ្នកទាំងនេះគឺជាសមាជិកស្រុកមេសាង។ បងចាន់ឱ្យខ្ញុំនៅមន្ទីរស្រុកបាភ្នំមិនឱ្យដើរទៅណាទេរហូតដល់ថ្ងៃទី១ ខែកក្កដា ទើបអង្គការចាប់ខ្លួនខ្ញុំ។ ខាងក្រោមនេះគឺជាប្រវត្តិរបស់ខ្ញុំចូលបដិវត្តន៍៖

ខ្ញុំឈ្មោះ ដួង គ្រេង ហៅ ហ៊ាន អាយុ៤០ឆ្នាំ (នៅក្នុងឆ្នាំ១៩៧៨) មានស្រុកកំណើត នៅភូមិអំពិលទោល ឃុំព្រៃទទឹង ស្រុកមេសាង តំបន់២០ ភូមិភាគបូព៌ា។ ខ្ញុំមានប្រពន្ធឈ្មោះ ទេស បួ និងប្រពន្ធចុងឈ្មោះ ចាន់ម៉ុត។ នៅឆ្នាំ១៩៥០ ខ្ញុំចូលចលនាខ្មែរឥស្សរ និងមានភារកិច្ចជានីរសាររបស់ឈ្មោះ ឃុត ឃុន កាលនោះគឺជានាយកស្រុកមេសាង (ក្រោយមកនៅឆ្នាំ១៩៧៨ គឺអនុលេខា ស្រុកបាភ្នំ)។ នៅដើមឆ្នាំ១៩៥៤ ខ្ញុំធ្វើជានីរសាររបស់អាចារ្យ ជៀវ គឺជាមេទ័ពខ្មែរឥស្សរតំបន់រមាសហែក។ ពីឆ្នាំ១៩៥៤ ដល់ឆ្នាំ១៩៦០ ខ្ញុំរកស៊ីនៅផ្ទះជាមួយគ្រួសារ។ នៅឆ្នាំ១៩៦០ ខ្ញុំបានទាក់ទងចលនានេះឡើងវិញ តាមរយៈឈ្មោះ ចាប សារុន ហៅ ចិក ហៅ ចន្ទម កាលនោះគាត់គឺជាប្រធានសិល្បៈរបស់កង តាភឹម ដែលមានឈ្មោះកងទ័ពសម្ការយោសនា ក្រោយមកជាលេខាស្រុកព្រៃវែង, ឈ្មោះ មោក ហ៊ួន កាលនោះជាប្រធានស្រុកមេសាង។ នៅឆ្នាំ១៩៦៦ ខ្ញុំចូលបក្សពលករវៀតណាម មានឈ្មោះ មោក ហ៊ួន និង ឈ្មោះ ចន្ទម គឺជាអ្នកខ្សែនាម ចំណែក តាភឹម គឺជាលេខាភូមិភាគបូព៌ា អ្នកទទួលស្គាល់។ នៅកន្លែងរៀបចំកម្មវិធីពេលចូលបក្ស គឺមានពិធីគោរពរូបហូជីមិញ និងទង់បក្សពលករ។

ក្រោយរដ្ឋប្រហារ នៅឆ្នាំ១៩៧០ តាភឹម ចុះមកចាត់តាំងឱ្យខ្ញុំទទួលអនុលេខាស្រុកមេសាង តំបន់២០ និងឈ្មោះ ចិក ហៅ ចន្ទម គឺជាលេខាស្រុកមេសាង។ តាភឹម ខ្សែនាមខ្ញុំឱ្យទាក់ទងឈ្មោះ ស៊ុន លេខាតំបន់២០។ នៅឆ្នាំ១៩៧៣ ស៊ុន បានចាត់តាំងខ្ញុំជាលេខាស្រុកមេសាង និង ជ្រន ទទួលអនុលេខា ហើយ

ចន្ថុមឱ្យកាន់លេខាស្រុកព្រៃវែងវិញ។ ពីឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៤ ខ្ញុំឃើញប្រជាជនអត់បាយច្រើន។

នៅឆ្នាំ១៩៧៥ ក្រោយពេលកងទ័ពខ្មែរក្រហមរំដោះប្រទេសបាន តាភីម លេខាភូមិភាគបានហៅគណៈស្រុកគណៈតំបន់២០ ទាំងអស់ទៅប្រជុំនៅមន្ទីរភូមិភាគ គឺមានឈ្មោះ ស៊ិន មុនចាប់ខ្លួនគឺជាលេខាតំបន់២០, ខ្ញុំ, ចន្ថុម, ឃាងលេខាស្រុកកំចាយមារតំបន់២០, សុងលេខាស្រុកកញ្ជ្រៀចតំបន់២០, ស៊ឹមលេខាស្រុកពញាក្រែក តំបន់២០, ឈាន លេខាតំបន់២២, ស្វូ លេខាតំបន់២៣ និង សួស នៅ ហៅ ឈូក ហៅម៉ែន លេខាតំបន់២៤។ ចំណែកផ្នែកយោធា ឈ្មោះកែវ សំណាង ហៅម៉ុនគឺជាសេនាធិការយោធាភូមិភាគបូព៌ា ២០៣។ នៅពេលប្រជុំគឺមានលើកឡើងនូវផែនការរៀបចំកម្លាំងយោធានៅតាមស្រុក និងតំបន់នីមួយៗឱ្យបានមួយកងពលដើម្បីត្រៀមកម្លាំងធ្វើរដ្ឋប្រហារដណ្តើមរដ្ឋអំណាចពីបក្សកុម្មុយនីស្តកម្ពុជា។ ចំណែករូបភាពខាងក្រៅ ត្រូវធ្វើឱ្យមានទំនាស់រវាងវៀតណាមនិងខ្មែរតាមព្រំដែន តែជម្រៅពេលដោះស្រាយទំនាស់នេះត្រូវទាក់ទងជាមួយវៀតណាមឱ្យជាប់ដើម្បីសហការគ្នាវាយបដិវត្តន៍។ បញ្ហាសេដ្ឋកិច្ចត្រូវត្រៀមធ្វើជង្រុកស្រូវនៅតាមដងផ្លូវជាតិលេខ៧ និងលេខ១៦។ យើងប្រជុំអស់រយៈពេលមួយថ្ងៃក៏បែកគ្នា។ នៅក្នុងឆ្នាំ១៩៧៥ ខ្ញុំបានរៀបចំកម្លាំងយោធាបានមួយវរសេនាតូចនៅក្នុងស្រុករបស់ខ្ញុំ និងកសាងកម្មាភិបាលដឹកនាំបាន៣នាក់គឺ១) ឈ្មោះ កនបច្ចុប្បន្នលេខាវរសេនាតូចយោធាស្រុកមេសាងតំបន់២០។ ២) ឆួយ អនុសេនាវរសេនាតូចយោធាស្រុកមេសាងតំបន់២០។ ៣) ប៊ុនសមាជិកវរសេនាតូចយោធាស្រុកមេសាង។ ចំណែកផ្នែកមូលដ្ឋានខ្ញុំបានណែនាំដល់ប្រធានសហករណ៍ ប្រធានស្រុក ដែលខ្ញុំកសាងបានពីមុនមានឈ្មោះ ដុន ប្រធានសហករណ៍ភូមិព្រៃស្គន់, ឈន់ លេខាឃុំច្រេស ស្រុកមេសាង, ទូច ប្រធានក្រុមនៅសហករណ៍ភូមិផ្អាវ, កួយ ប្រធានសហករណ៍ភូមិបឹង, យ៉ន អតីតចោរលួចគោក្រោយមកប្រធានកងចល័ត, យ៉េង ប្រជាជនភូមិអណ្តូងឃុំស្វាយជ្រំ, ឈ្មោះជូនិងឈ្មោះហៀងឱ្យធ្វើសកម្មភាពចលនាបំផុសទំនាស់ក្នុងសហករណ៍ ចលនាលែងគោឱ្យស៊ីស្រូវ កាប់ជើងគោ បំផុសថាសម្លឆ្នាំងធំសមូហភាពមិនឆ្ងាញ់ដូចឆ្នាំងឯកជនទេ។

នៅក្នុងឆ្នាំ១៩៧៦ ស៊ិន បានហៅខ្ញុំ, ចន្ថុម, ឃាង, ស៊ឹម និង ឈ្មោះ សុង មកប្រជុំនៅមន្ទីរតំបន់២០។ ស៊ិនបានលើកផែនការទទួលពីតាភីម អំពីផែនការយើងត្រូវធ្វើរដ្ឋប្រហារវាយបក្សកុម្មុយនីស្តកម្ពុជានៅចុងឆ្នាំ១៩៧៦នេះ ដោយសហការជាមួយកម្លាំងវៀតណាមចូលមកវាយពីខាងក្រៅ។ ដូច្នេះយើងត្រូវរៀបចំកិនស្រូវអង្ករដើម្បីត្រៀមស្បៀងទទួលកងទ័ពវៀតណាមចូលមកតាមផ្លូវលេខ៧ វាយយកភូមិភាគបូព៌ា។ ក្រោយពីទទួលផែនការ ខ្ញុំរៀបចំកម្លាំងយោធានៅក្នុងស្រុក និងហៅកម្មាភិបាលដែលខ្ញុំអប់រំបានកន្លងមកមកណែនាំឱ្យជ្រួតជ្រាប។ ខ្ញុំបានប្រមូលស្រូវនៅតាមសហករណ៍មកកិនជាអង្ករបានចំនួន១០០បាវដើម្បីត្រៀមផែនការ ប៉ុន្តែផែនការនេះមិនសម្រេច ហើយអង្ករទាំងនោះខ្ញុំបានផ្តល់ទៅឱ្យតំបន់ចំនួន៥០០បាវ ដើម្បីបញ្ជូនទៅឱ្យយួនឈ្មោះ បាហាយ នៅបន្ទាយស្នាប់ផ្លូវលេខ២២។ នៅចុងឆ្នាំ១៩៧៦ ខ្ញុំបានហៅឈ្មោះ សា ផល់ និង ឆាន នៅផ្នែកពេទ្យមកណែនាំឱ្យធ្វើសកម្មភាពព្យាបាលអ្នកជំងឺធ្វើយ៉ាងណាកុំឱ្យជា រីឯថ្នាំបុរាណមិនឱ្យផលិតច្រើនទេគឺត្រូវធ្វើយ៉ាងណាឱ្យប្រជាជនមានទំនាស់ជាមួយបដិវត្តន៍។

នៅឆ្នាំ១៩៧៧ ខ្ញុំកសាងកម្លាំងបានចំនួន៣នាក់ មានឈ្មោះ សាំ សមាជិកសហករណ៍អង្គក្អែក ឃុំព្រៃទទឹង ស្រុកមេសាងតំបន់២០, ឈ្មោះ សុក ប្រជាជននៅសហករណ៍ព្រៃត្រាំ ឃុំព្រៃទទឹង ស្រុកមេសាង តំបន់២០ និងឈ្មោះ អៀម ប្រជាជននៅសហករណ៍ភូមិព្រៃគ្នោត ឃុំស្វាយជ្រំ ស្រុកមេសាង តំបន់២០។ បងស៊ិន លេខាតំបន់២០ បានហៅខ្ញុំ, ឃាង, ស៊ឹម លេខាស្រុកពញាក្រែកតំបន់២០, សុង, ញាំ ប្រធានសន្តិសុខតំបន់២០, ឈ្មោះ ទុយ អនុលេខាតំបន់២០, ភា លេខាស្រុកព្រៃវែង តំបន់២០ មកប្រជុំនៅមន្ទីរស្រុកកំចាយមារ ដោយមានខ្លឹមសារថា៖ ផែនការធ្វើរដ្ឋប្រហារឆ្នាំ១៩៧៧ នេះចាប់ពីខែមេសា ដល់ចុងឆ្នាំ១៩៧៧

ដែលមានកម្លាំងកងទ័ពវៀតណាមជួយវាយ ខាងក្រៅតាមច្រកកំពង់អំពិលមកក្របៅ សំដៅមកផ្លូវជាតិលេខ១៥, ច្រកទី២ចូលតាមឃុំកក់ ឡើងមកផ្លូវជាតិលេខ៧, ច្រកទី៣ចូលតាមមេមត់។ ខាងក្នុងត្រូវរៀបចំកម្លាំងយោធាឱ្យហើយស្រេចដើម្បីសហការជាមួយកម្លាំងវៀតណាម ដណ្ដើមអំណាចបដិវត្តន៍។ តាមស្រុកនីមួយៗត្រូវប្រមូលស្រូវឱ្យបានចំនួន ១០,០០០ថាំង ដើម្បីត្រៀមទុកផែនការនេះ។ ផែនការកែនប្រជាជនធ្វើផ្លូវចាប់ពីព្រៃវែង ទៅកំពង់មានជ័យ ចូលទៅខេត្តតាយនិញ សម្រាប់ផ្លូវដឹកទំនិញនិងផ្លូវរថក្រោះចូលមក។ បងស៊ុនបានណែនាំឱ្យខិតខំកសាងកម្លាំងបន្តទៀតព្រោះកម្លាំងមុនត្រូវអង្គការចាប់អស់មួយចំនួនហើយ។

**កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខ D៤១៦៩៨ រាល់ចម្លើយសារ ភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និង ធ្វើទារុណកម្ម យ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម។ ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់ ដួង គ្រេង ហៅ ហ៊ាន ពិតប្រាកដប៉ុណ្ណាណានោះទេ។**



*សូ វណ្ណា ហៅ សោ ភឹម (រូបឈរនៅកណ្តាល) និងកងទ័ពខ្មែរក្រហមធ្វើដំណើរទស្សនកិច្ចទៅកាន់កងមួយនៃកងកម្លាំងប្រយុទ្ធស្ម័គ្រចិត្តកុម្មុយនីស្តរបស់វៀតណាម ក្នុងឆ្នាំ១៩៧៣។ រូបថតនេះត្រូវបានថតភ្លាមៗបន្ទាប់ពីកងខ្មាំងសម្ព័ន្ធចាប់ផ្តើមធ្វើការវាយប្រហារទៅលើមូលដ្ឋានទ័ព ឃុំក្របៅ ក្នុងខេត្តកំពង់ចាម ដែលជាផ្នែកមួយនៃសង្គ្រាមស៊ីវិលប្រឆាំងនឹងរដ្ឋាភិបាលនៃរបបសាធារណរដ្ឋខ្មែរដឹកនាំដោយលោកសេនាប្រមុខ លន់ នល់។ ក្រោយមក សោ ភឹម បានក្លាយទៅជាលេខាបក្សកុម្មុយនីស្តកម្ពុជាប្រចាំភូមិភាគបូព៌ាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សោ ភឹម បានធ្វើអត្តឃាតនៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៩៧៨។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា/ភ្នាក់ងារសារព័ត៌មានវៀតណាម)*

# កែវ បូរ៉ែន ភ្នាក់ងារសេអ៊ីអា

សួត វិចិត្រ



ចច ក្រេមើរ ភ្នាក់ងារ សេ.អ៊ី.អា ចាប់ដៃជាមួយយោធាខ្មែរក្រហមនៅលើស្ពានខណ្ឌចែកព្រំដែនរវាងកម្ពុជា និងថៃ នៅប៉ោយប៉ែត នៅឆ្នាំ១៩៧៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចម្លើយសារភាពនេះ មានទំនាក់ទំនងនឹង កែវ បូរ៉ែន ដែលមានសកម្មភាពក្បត់នឹងអង្គការបដិវត្តន៍ខ្មែរក្រហម ដូចជា ការចូលរួមជាមួយអង្គការមនុស្សធម៌នៅខែមេសា ឆ្នាំ១៩៧0, ការចូលសមាគមនៅខែវិច្ឆិកា ឆ្នាំ១៩៧៣ និងការចូល សេ.អ៊ី.អា នៅខែសីហា ឆ្នាំ១៩៧៤។ កែវ បូរ៉ែនបានរៀបរាប់នៅក្នុងចម្លើយសារភាពថា៖

«ខ្ញុំឈ្មោះដើម កែវ សុជាតិ ហៅ បូរ៉ែន អាយុ ២៧ឆ្នាំ (ក្នុងឆ្នាំ១៩៧៤) ជនជាតិខ្មែរ មានទីកន្លែងកំណើតនៅភូមិកំពង់គាដេស ឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។ ឪពុកទី១របស់ខ្ញុំឈ្មោះ កែវ កន ចំណែកឯឪពុកទី២ឈ្មោះ លីឈាង (ធ្វើប៉ូលីស) ហើយម្តាយរបស់ខ្ញុំឈ្មោះ ហ៊ុន យឹម អាយុ៥១ឆ្នាំ។ ខ្ញុំមានបងប្អូនចំនួន៣នាក់។

ខ្ញុំបានចូលក្នុងតំបន់រំដោះនៅក្នុងខែមេសា ឆ្នាំ១៩៧៤ ដោយសារអង្គការខ្មែរក្រហមកៀរនិងចាប់ខ្លួន។ ដំបូងខ្ញុំរស់នៅក្នុងភូមិត្រពាំងឃុំស្រែអំបិល ស្រុកស្រែអំបិល តំបន់៣៧ ដោយមានវ័ត្ន ជឹម មាននាទីជាប្រធានសហករណ៍ជាអ្នកទទួលខុសត្រូវ។ ក្រោយមកមិត្តសិនមាននាទីជាគណៈអប់រំយុវជន-

យុវនារីតំបន់៣៧ ជាអ្នកទទួលខុសត្រូវក្នុងកងចល័ត។ ចាប់តាំងពីរស់នៅក្នុងតំបន់រំដោះមក ខ្ញុំមានតួនាទីជាអ្នកតំណាងយុវជនថ្មីផង និងជាយុវជនចល័តក្នុងតំបន់៣៧ផង។ អត្តចរិតរបស់ខ្ញុំពីដើមមកចូលចិត្តស្រីស្រាល្បែងពាលា និងសប្បាយហ៊ឺហា។ បន្ទាប់មកខ្ញុំបានរត់ចេញពីកងចល័តទៅដល់ក្អេង ទើបអង្គការចាប់ខ្លួនបាន។ ប្រវត្តិសកម្មភាព និងខ្សែសន្ធាក់ចាត់តាំងនៅក្នុងតំបន់ខ្ញាំង ដំបូងខ្ញុំបានរស់នៅក្នុងវត្តសួងក្រោមការដឹកនាំរបស់លោកតា ណែន។ តាណែនបានអប់រំខ្ញុំអំពីធម៌ និងបាលី តាមសមាគមពុទ្ធិកមហានិកាយ ហើយណែនាំខ្ញុំឱ្យចេះសន្សំទ្រព្យជិះជាន់ យល់ដឹងពីវណ្ណៈអធន និងវណ្ណៈមូលធន ដើម្បីកេងប្រវ័ញ្ចពីបុគ្គលជុំវិញខ្លួនយកទៅចិញ្ចឹមគ្រួសារ និងបងប្អូន។

លុះដល់ឆ្នាំ១៩៦៤ តាណែនបានបញ្ចូលខ្ញុំទៅក្នុងសមាគមពុទ្ធិកមហានិកាយ។ កាលជំនាន់នោះ តាណែនបានអូសទាញសមាជិកជាព្រះសង្ឃបានចំនួន២៥នាក់។ ក្រោយមកនៅឆ្នាំ១៩៦៥ ខ្ញុំបានដាច់ចេញពីសមាគមពុទ្ធិកមហានិកាយដោយមានទំនាស់ផ្ទៃក្នុង។ បន្ទាប់មក ឈ្មោះ សោម វណ្ណៈ បាននាំសមាជិកទាំង២៥នាក់មករស់នៅជាមួយខ្លួនវិញ ហើយបានអប់រំយើងទាំងអស់គ្នាឱ្យចូលក្នុងក្រុមបញ្ញវន្តធម្មយុទ្ធបាលី គឺសេរីតាមចិត្តចង់ និងមានសិទ្ធិស្មើៗគ្នានៅក្នុងឆ្នាំដដែលនោះ។ លុះដល់ឆ្នាំ១៩៦៨ ខ្ញុំបានសឹកមកវិញដើម្បីធ្វើការងារដូចប្រជាជនដទៃទៀត។

រហូតដល់ខែឧសភា ឆ្នាំ១៩៧០ ខ្ញុំបានទាក់ទងជាមួយ ពត សួន មាននាទីជាវរសេនីយ៍ទោ ស័ក្តិបួនកន្លះ ហើយបុគ្គលរូបនេះបានអប់រំខ្ញុំឱ្យប្រឆាំងរបបកុម្មុយនីស្ត ប្រឆាំងនឹងបដិវត្តន៍ដាច់ខាត ដោយបង្ហាញឱ្យឃើញបដិវត្តន៍គ្មានព្រះពុទ្ធសាសនា គ្មានទីកន្លែងរស់នៅ និងគ្មានយុត្តិធម៌ពិតប្រាកដឡើយ។ លើសពីនេះ ពត សួន បានណែនាំខ្ញុំឱ្យចូលក្នុងអង្គការមនុស្សធម៌ ដោយបង្ហាញឱ្យខ្ញុំឃើញថា សង្គមនេះមានព្រះពុទ្ធសាសនា យុត្តិធម៌ រុងរឿង រស់នៅសម្បូរសប្បាយ ចង់ធ្វើអ្វីបានទាំងអស់ ហើយនាំខ្ញុំដើរពង្វក់ស្រីស្រាល្បែងពាលាគ្រប់បែបយ៉ាងដោយមិនឱ្យមើលឃើញវណ្ណៈក្រីក្រឡើយ។

ក្នុងចំណោមសមាជិកទាំង១៥០នាក់ ខ្ញុំស្គាល់តែ៨នាក់តែប៉ុណ្ណោះ មានអ្នកបើករថយន្ត អ្នកកាន់ខាងបន្លែ និងអង្ករ។ នៅក្នុងអង្គការមនុស្សធម៌ ខ្ញុំបានជ្រួតជ្រាបពីផែនការសំខាន់ៗអំពីការឃោសនាអូសទាញប្រជាជនឱ្យដើរតាមបក្សសាធារណរដ្ឋ ដោយពេលដឹកបន្លែ និងដឹកអង្ករចែកចាយតាមជំរំជនភៀសខ្លួន ត្រូវធ្វើនយោបាយប្រមូលជនភៀសខ្លួន ឬជនក្រីក្រដែលនៅតាមទីជនបទឱ្យចូលរស់នៅក្នុងជំរំនៅអូរបែកក្អម និងដើរបាចត្រាក់នៅទីក្រុងភ្នំពេញ និងតាមទីជនបទ។ យ៉ាងណាមិញ ចំពោះសកម្មភាពជាក់ស្ដែងរបស់ខ្ញុំ គឺដឹកបន្លែចែកតាមជំរំជនភៀសខ្លួន ដើម្បីធ្វើនយោបាយបោកប្រាសឱ្យខ្មែរក្រហមចុះចូល ឬបង្ហាញខ្លួននៅតាមជំរំប្រចាំថ្ងៃ ដើរឃោសនាឱ្យជនភៀសខ្លួនតាមជំរំ ឬនៅតាមទីជនបទប្រឆាំងនឹងខ្មែរក្រហម និងយួនយៀកកុងដាច់ខាត ព្រមទាំងបើកឡានទៅដឹកខ្មែរក្រហមដែលទាហានចាប់យកមកដាក់គុក។

ក្រោយពីធ្វើសកម្មភាពបន្តបន្ទាប់ នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៣ ខ្ញុំបានទៅរស់នៅជាមួយ គឹង សាម៉ន មាននាទីជាវរសេនីយ៍ឯក ដោយមុនពេលរំដោះរស់នៅក្នុងខេត្តឧត្តរមានជ័យ។ នៅក្នុងឆ្នាំ១៩៧៣ដដែលនោះ ខ្ញុំបានដាច់ចេញពីខ្សែរយៈអង្គការមនុស្សធម៌។ ក្រោយមកទៀត គឹង សាម៉ន បានបញ្ជូនខ្ញុំទៅរស់នៅក្នុងសមាគមអភិវឌ្ឍន៍សហគមន៍ ដោយសារខ្លួនបានដឹងថា ខ្ញុំធ្លាប់ធ្វើការនៅក្នុងអង្គការមនុស្សធម៌ស្រាប់។ នៅក្នុងសមាគមនេះមានគ្នាចំនួន១២នាក់ ដែលសុទ្ធសឹងជាសមាជិកសាលាខេត្តឧត្តរមានជ័យ មានតួនាទីអនុសេនីយ៍ត្រី និងព្រិន្ទបាលឯក។ ផែនការរបស់យើងនៅពេលនោះ គឺបង្កើតជាល្ខោននយោបាយដើម្បីពន្យល់ណែនាំប្រជាជនឱ្យប្រឆាំងនឹងខ្មែរក្រហមដាច់ខាត, ដើរធ្វើកូដកម្មនៅពេលយប់ និងឱ្យប្រជាជនមកទស្សនាល្ខោន ហើយកម្លាំងរបស់យើងដើរលួចរបស់របរទ្រព្យសម្បត្តិនៅតាមភូមិដូចជា មាន់ ទា ជ្រូក ដុតផ្ទះប្រជាជនចោល បន្ទាប់មកក៏បង្កើតដានថាខ្មែរ

*ក្រហម។ យើងដើរស៊ើបនៅក្នុងចំណោមប្រជាជនថា តើប្រជាជនណាខ្លះលួចជេរប្រមាថអ្នកសម្តេចល្មោន ហើយបើមានអ្នកជេរ យើងនឹងចាប់យកមកឃុំឃាំង ហើយឱ្យឪពុកម្តាយយកប្រាក់មកលោះ។ ប្រសិនបើមិនមានប្រាក់ទេនឹងសម្លាប់ចោល ហើយចោទថាបានចូលដៃចូលជើងជាមួយខ្មែរក្រហម។*

*ក្រោយមកនៅក្នុងខែសីហា ឆ្នាំ១៩៧៤ ខ្ញុំបានចូល សេ.អ៊ី.អា តាមរយៈ លី ឆៀងចេក ជាវរសេនីយ៍ទោ ស័ក្តិ៤កន្ទះ បន្ទាប់ពីបានជម្រៀសយើងខ្ញុំទៅកាន់កំពង់សីលា កំពង់សោម។ នៅក្នុងចំណោមសមាជិកទាំង៣០នាក់របស់យើងខ្ញុំ ក៏មាន ដែន ដែលជាភ្នាក់ងារ សេ.អ៊ី.អា បានដាក់ចេញនូវផែនការឱ្យយើងបែកគ្នាពីក្រុងកំពង់សោមទៅជួបជុំគ្នានៅ ទួលកន្សែង ឬស្រុកស្រែអំបិល។ បន្ទាប់មកយើងបានទាក់ទងជាមួយ ចន្ទរង្សី (ផ្កាយបួន) នៅខាងលិចពេជ្រនិល ដើម្បីជំរុញឱ្យកងទ័ពដាច់ខាតរបស់យើងកុំទម្លាក់អាវុធចុះចាញ់កងទ័ពបដិវត្តន៍។ ចំណែកអាវុធ និងវិទ្យុនៅសេសសល់ត្រូវទាក់ទងអគ្គលេខាធិការ សេ.អ៊ី.អា នៅកប៉ាល់ ម៉ាយ៉ាហ្គេស ដើម្បីមកទទួលនៅមុខពាមស្រែអំបិល។ ចំពោះ អង្គរ សាច់កំប៉ុង និងត្រី ដែលយន្តហោះទម្លាក់នៅខាងជើងភ្នំកំពង់សីលាត្រូវប្រមូលទុក ព្រមទាំងប្រមូលកម្លាំងជុំគ្នាលើសពី៥០០នាក់ បកក្បាលវាយកម្លាំងបដិវត្តន៍នៅក្រុងកំពង់សោម ដោយមានយន្តហោះចម្បាំងអេហ្វ១១១ ណុសេ១៣០ តេ២៨ចំនួន១៥គ្រឿង និងកប៉ាល់ទឹកមួយចំនួនសម្រាប់ជួយអន្តរាគមន៍។ កម្លាំងសេ.អ៊ី.អា ទាំងអស់មានបំណងបំផ្លាញកម្លាំងបដិវត្តន៍ប្រមាណពី១០ទៅ១៥ភាគរយដែរមុននឹងត្រៀមរត់ទៅស្រុកសៀម។*

*ទោះជាយ៉ាងនេះក្តី ខ្ញុំបានផ្អាកសកម្មភាពចាប់តាំងពីភ្នាក់ងារ សេ.អ៊ី.អា បានដាក់ផែនការមករហូតដល់ខែមេសា ឆ្នាំ១៩៧៥ ទើបខ្ញុំធ្វើសកម្មភាពបន្តដោយសារសុខភាពមិនអំណោយផល។ រហូតដល់ថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៧៧ ទើបខ្ញុំត្រូវបានអង្គការបដិវត្តន៍ខ្មែរក្រហមចាប់ខ្លួនតែម្តង។*

***កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខD៤១៦៩៨។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្ម យ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម។ ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ កែវ បូរ៉ែន ពិតប្រាកដឬយ៉ាងណានោះទេ។***



*យោធាខ្មែរក្រហមទទួលបារីពីបុរសម្នាក់នៅលើស្ពានប៉ោយប៉ែត ព្រំដែនរវាងប្រទេសកម្ពុជា និងថៃ នៅឆ្នាំ១៩៧៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

# រឿងរ៉ាវរបស់វីរកងទ័ព ព្រំ ប៊ុនឡាំង និងក្រុមគ្រួសារ

សា ហ្វី



វីរកងទ័ព ព្រំ ប៊ុន ឡាំង ពលីនៅសមរភូមិទិសប្រាសាទព្រះវិហារ នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




ពិធីបុណ្យសពវីរកងទ័ព ព្រំ ប៊ុន ឡាំង នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្ដីរបស់ខ្ញុំបានលះបង់ជីវិតទាំងវ័យក្មេង ដើម្បីការពារទឹកដីពីការឈ្លានពានរបស់សត្រូវ។ ខ្ញុំពិតជានឹក និងស្រណោះប្ដីរបស់ខ្ញុំខ្លាំងណាស់។ រាល់ថ្ងៃនៅពេលខ្ញុំមើលមុខកូន ខ្ញុំនឹកឃើញប្ដី។ កូនខ្ញុំកំព្រាឪពុកតាំងពីនៅតូចៗ។ អ្នកស្រី ដេង ម៉ុនថា បានរៀបរាប់រឿងរ៉ាវក្រុមគ្រួសារ និងអនុស្សាវរីយ៍ជាមួយប្ដីដែលបានពលីនៅសមរភូមិទិសប្រាសាទព្រះវិហារក្នុងខែធ្នូ ឆ្នាំ២០២៥ ដូចខាងក្រោម៖

នាងខ្ញុំឈ្មោះ ដេង ម៉ុនថា អាយុ២៥ឆ្នាំ បច្ចុប្បន្នខ្ញុំរស់នៅភូមិ១០៩ ឃុំរីករាយ ស្រុករវៀង ខេត្តព្រះវិហារ។ ប្ដីរបស់ខ្ញុំឈ្មោះ ព្រំ ប៊ុន ឡាំង អាយុ២៦ឆ្នាំ មានឋានន្តរសក្តិអនុសេនីយ៍ត្រី បានពលីនៅសមរភូមិទិសប្រាសាទព្រះវិហារ នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៥។ ខ្ញុំមានកូនពីរនាក់ គឺកូនប្រុសច្បងឈ្មោះ លី ម៉េងឡាយ អាយុ២ឆ្នាំ ១០ខែ និងកូនស្រីពៅ លី មន្នីរ័ត្ន អាយុ៨ខែ។

ខ្ញុំ និងប្ដីបានចាប់ផ្ដើមមានទាក់ទង និងស្រឡាញ់គ្នាតាំងពីអំឡុងឆ្នាំ២០២០។ យើងទាំងពីរនាក់បានរៀបការនៅថ្ងៃទី១ ខែមករា ឆ្នាំ២០២៣។ មុនពេលរៀបការ ប្ដីរបស់ខ្ញុំបានខ្ចីលុយគ្រឹះស្ថានមីក្រូហិរញ្ញ-វត្ថុមួយកន្លែងដើម្បីចូលស្ដីដណ្ដឹងខ្ញុំ ហើយលុយដែលបានខ្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនោះប្ដីខ្ញុំបានសងចប់

សព្វគ្រប់នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២៥ នេះ ។ មុនពេលរៀបការយើងមានក្តីស្រមៃចង់បានកូនចំនួន២នាក់ គឺប្រុសម្នាក់ និងស្រីម្នាក់ និងសាងសង់ផ្ទះសមរម្យមួយសម្រាប់ក្រុមគ្រួសារដែលមានសមាជិក៤នាក់ រស់នៅដោយភាពកក់ក្តៅ។

បន្ទាប់ពីរៀបការរួចមានរយៈពេលជិត៣ឆ្នាំ យើងមានកូនប្រុសម្នាក់ និងកូនស្រីម្នាក់សមដូចបំណង។ ទោះបីជាជីវភាពមិនសូវធូរធារ ប៉ុន្តែក្រុមគ្រួសារខ្ញុំពោរពេញដោយសុភមង្គល និងស្នាមញញឹម។ អនុស្សាវរីយ៍ដែលប្តីរបស់ខ្ញុំមានចំពោះប្រពន្ធកូន គឺប្តីរបស់ខ្ញុំស្រឡាញ់ប្រពន្ធកូនខ្លាំងណាស់ និងបានបំពេញតួនាទីជាឪពុកដ៏ល្អម្នាក់។ ចាប់តាំងពីរៀបការរួច ប្តីរបស់ខ្ញុំមិនដែលធ្វើឱ្យក្រុមគ្រួសារពិបាកម្តងណាឡើយ។ ប្តីខ្ញុំបានសន្យាជាមួយខ្ញុំថា ថ្ងៃណាមួយគាត់នឹងសាងសង់ផ្ទះមួយដែលអាចឱ្យក្រុមគ្រួសារខ្ញុំរស់នៅបានសមរម្យ មិនពិបាកដូចសព្វថ្ងៃទេ។

ប្តីខ្ញុំមានស្រុកកំណើតនៅភូមិដំណាក់ចិន ឃុំរស្មី ស្រុករវៀង ខេត្តព្រះវិហារ។ ប្តីខ្ញុំមានឪពុកឈ្មោះ យឹម ប្រឿនលី និងម្តាយឈ្មោះ ឡេវ សុខន។ ប្តីរបស់ខ្ញុំមានបងប្អូនបង្កើតចំនួន៥នាក់ គឺ ទី១) ឈ្មោះ ព្រំ សុខេង (ស្រី) ទី២) ឈ្មោះ ព្រំ សុជឿន (ប្រុស) ទី៣) ឈ្មោះ ព្រំវិជ្ជា (ប្រុស) ទី៤) ឈ្មោះ ព្រំដល្លា (ប្រុស) និងទី៥) ប្តីរបស់ខ្ញុំ ព្រំ ប៊ុន ឡាំង។

ប្តីរបស់ខ្ញុំគឺជាកូនពៅក្នុងគ្រួសារដែលមានជីវភាពក្រីក្រ ប៉ុន្តែប្តីរបស់ខ្ញុំគឺជាក្មេងខិតខំរៀនសូត្រ និងមានក្តីស្រមៃចង់ចូលបម្រើកងទ័ព។ ប្តីរបស់ខ្ញុំបានចូលរៀននៅសាលាបឋមសិក្សាដំណាក់ចិន និងបានបន្តការសិក្សានៅវិទ្យាល័យរវៀង ក្នុងស្រុករវៀង ខេត្តព្រះវិហារ។ នៅឆ្នាំ២០១៨ ប្តីរបស់ខ្ញុំបានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (បាក់ឌុប) ប៉ុន្តែប្តីខ្ញុំមិនបានបន្តការសិក្សានៅថ្នាក់ឧត្តមទេ ដោយសារក្រុមគ្រួសារមានជីវភាពខ្វះខាត។

នៅឆ្នាំ២០១៩ ប្តីរបស់ខ្ញុំបានសម្រេចចូលបម្រើកងទ័ព ដើម្បីការពារប្រទេសជាតិ ដែលជាបំណងប្រាថ្នាតាំងពីនៅក្មេងមកម្ល៉េះ។ ប្តីរបស់ខ្ញុំបានបម្រើការងារជាកងទ័ពនៅក្នុងអង្គភាពកងវរសេនាតូច



វីរកងទ័ព ព្រំ ប៊ុនឡាំង, ប្រពន្ធ និងកូនៗ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អន្តរាគមន៍លេខ២៨១ កងពលតូចអន្តរាគមន៍លេខ១៨ ចំណុះកងពលធំអន្តរាគមន៍លេខ៣ ដែលឈរជើងការពារព្រំដែនទិសទី១ នៅសមរភូមិទិសប្រាសាទព្រះវិហារ។

បន្ទាប់ពីមានការបាញ់សម្លាប់កងទ័ពកម្ពុជាម្នាក់ដែលមិនមានអាវុធនៅក្បែរលេណដ្ឋានក្នុងភូមិសាស្ត្រមុំបីនៃស្រុកជាំក្សាន្ត ខេត្តព្រះវិហារនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥ អង្គភាពប្តីរបស់ខ្ញុំត្រូវបានមេបញ្ជាការបញ្ជូនពីសមរភូមិទិសព្រះវិហារ ទៅឈរជើងប្រចាំការនៅតំបន់មុំបី។ នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៥ ប្តីខ្ញុំបានសុំអនុញ្ញាតច្បាប់ពីអង្គភាពមកមើលថែខ្ញុំដែលគ្រប់ខែ និងសម្រាលកូននៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៥។

នៅអំឡុងពេលប៉ះទង្គិចប្រដាប់អាវុធរវាងកងទ័ពកម្ពុជា និងថៃលើកទី១ ចន្លោះពីថ្ងៃទី២៤ ដល់២៨ ខែកក្កដា ឆ្នាំ២០២៥ ប្តីរបស់ខ្ញុំត្រូវនៅផ្ទះមើលថែខ្ញុំនិងកូនង៉ែត មិនបានចូលរួមប្រយុទ្ធជាមួយសត្រូវឈ្លានពានទឹកដីទេ។ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៥ ប្តីខ្ញុំបានវិលត្រឡប់ទៅអង្គភាពនៅសមរភូមិតំបន់មុំបី ស្រុកជាំក្សាន្តវិញ។

នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៥ មេបញ្ជាការបានបញ្ជូនអង្គភាពប្តីខ្ញុំពីតំបន់មុំបីត្រឡប់មកឈរជើងនៅ

ទិសទី១ សមរភូមិទិសប្រាសាទព្រះវិហារវិញ។ ទោះបីជាប្រចាំការនៅសមរភូមិមុខ ប្តីខ្ញុំតែងតែទូរសព្ទមកសួរសុខទុក្ខប្រពន្ធកូនជាប្រចាំជាពិសេសនៅពេលល្ងាច និងយប់។

ចាប់តាំងពីមានប៉ះទង្គិចប្រដាប់អាវុធរវាងកងទ័ពកម្ពុជា និងថៃលើកទី២ នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥ សភាពការនៅតាមសមរភូមិកាន់តែមានសភាពតឹងតែង។ ប្តីរបស់ខ្ញុំកាន់តែពិបាកទូរសព្ទមកសួរសុខទុក្ខប្រពន្ធកូន ពីព្រោះខ្លាចមានគ្រោះថ្នាក់។ នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៥ ដោយសារទូរសព្ទប្តីរបស់ខ្ញុំមិនមានទឹកប្រាក់គ្រប់គ្រាន់ក្នុងការហៅចេញ ប្តីខ្ញុំបានសុំមិត្តរួមអាវុធនៅក្នុងលេណដ្ឋានជាមួយគ្នាភ្ជាប់ប្រព័ន្ធអ៊ិនធឺណែត រួចបានផ្ញើសារ និងរូបថតមួយចំនួនមកឱ្យខ្ញុំ។ សារដែលប្តីរបស់ខ្ញុំផ្ញើមកខ្ញុំគឺជាពាក្យពេជ្រធម្មតា ប៉ុន្តែពោរពេញដោយសេចក្តីស្រឡាញ់ «ប្តីសុខសប្បាយទេអូនកុំបារម្ភ មើលថែកូន និងប្រាប់ម៉ែផង ប្តីមិនអីទេ»។ ពាក្យសាមញ្ញទាំងនេះ បានក្លាយជាអនុស្សាវរីយ៍ចុងក្រោយ ដែលខ្ញុំរក្សាទុកក្នុងបេះដូងជារៀងរហូត។ នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ ២០២៥ គ្រាប់កាំភ្លើងធំរបស់សត្រូវឈ្លានពានទឹកដីមួយគ្រាប់បានធ្លាក់មកត្រូវចំ និងបានបញ្ចប់ជីវិតប្តីរបស់ខ្ញុំ ដែលជាយុទ្ធជនក្លាហានមួយរូប។

សពប្តីខ្ញុំត្រូវបានដឹកត្រឡប់មកស្រុកកំណើតនៅភូមិដំណាក់ចិន ឃុំរស្មី ស្រុករវៀង ខេត្តព្រះវិហារ នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៥ ដើម្បីរៀបចំធ្វើពិធីបុណ្យសពតាមប្រពៃណីខ្មែរ។ ចាប់តាំងពីថ្ងៃទី២៣ រហូតដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៥ ដែលជាថ្ងៃបុណ្យគម្រប់៧ថ្ងៃ គឺមានអ្នកភូមិ ប្រជាពលរដ្ឋ កងកម្លាំងប្រដាប់អាវុធ ថ្នាក់ដឹកនាំរដ្ឋបាលស្រុករវៀង រដ្ឋបាលខេត្តព្រះវិហារ និងសិស្សានុសិស្ស និស្សិតជាច្រើនកុះករមកចូលរួមរំលែកទុក្ខ។

កាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៦ កន្លងទៅ ខ្ញុំ និងក្រុមគ្រួសារបានរៀបចំធ្វើពិធីបុណ្យគម្រប់ខួប១០០ថ្ងៃ ដើម្បីឧទ្ទិសកុសលដល់ប្តីរបស់ខ្ញុំ ប៉ុន្តែខ្ញុំនៅតែមានអារម្មណ៍ហាក់បីដូចជាប្តីខ្ញុំស្ថិតនៅក្បែរៗខ្ញុំនិងកូនៗជារៀងរាល់ថ្ងៃ។ ការពលីរបស់ប្តីខ្ញុំគឺជាការបាត់បង់ដ៏ធំធេង មិនត្រឹមតែគ្រួសាររបស់ខ្ញុំតែប៉ុណ្ណោះទេ ប៉ុន្តែសង្គមជាតិទាំងមូលបានបាត់បង់មនុស្សល្អម្នាក់ដែរ។ ប្តីរបស់ខ្ញុំបានពលីជីវិតក្នុងបុព្វហេតុការពារទឹកដី គឺជាមោទនភាពសម្រាប់ខ្ញុំ និងក្រុមគ្រួសារ ទោះបីខ្ញុំត្រូវរែកពុនក្នុងការមើលថែ និងចិញ្ចឹមកូនតូចៗទាំងពីរនាក់ក្នុងរយៈពេលវែងឆ្ងាយតទៅមុខទៀតក៏ដោយ។

នៅក្នុងថ្ងៃបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ ខាងមុខនេះ ខ្ញុំមិនមានអារម្មណ៍សប្បាយរីករាយដូចបងប្អូនដទៃទៀតឡើយ ចូលឆ្នាំថ្មីនេះ ខ្ញុំមិនមានប្តីនៅក្បែរដូចចូលឆ្នាំមុនៗឡើយ។ នាងខ្ញុំនឹងខិតខំប្រឹងប្រែងចិញ្ចឹមកូនៗខ្ញុំឱ្យបានរៀនសូត្រខ្ពង់ខ្ពស់ និងមានផ្ទះរស់នៅសមរម្យ ដើម្បីបំពេញក្តីសុបិនប្តីរបស់ខ្ញុំកាលគាត់នៅមានជីវិត។

រឿងរ៉ាវរបស់ អនុសេនីយ៍ត្រី ព្រាំ ប៊ុនឡាំង មិនមែនត្រឹមតែជាប្រវត្តិដ៏ឈឺចាប់របស់ក្រុមគ្រួសារអ្នកស្រី ដេង ម៉ុនថា នោះទេ ប៉ុន្តែគឺជារឿងរ៉ាវរបស់កងទ័ពដែលបានលះបង់ដ៏ធំធេងដើម្បីការពារជាតិមាតុភូមិ ចំពោះមុខសត្រូវការឈ្លានពានទឹកដី។ ឈ្មោះរបស់វីរកងទ័ពព្រាំប៊ុន ឡាំង និងវីរកងទ័ពកម្ពុជាដទៃទៀតត្រូវបានប្រជាជនខ្មែរគ្រប់រូប ជាពិសេសយុវជនជំនាន់ក្រោយចងចាំជារៀងរហូត។


វីរកងទ័ព ព្រាំ ប៊ុនឡាំង និងកូនប្រុស។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ម្តាយរបស់វីរកងទ័ព ហេង កំសាន្ត ៖

## «កូនប្រុសខ្ញុំបានសម្រាន្តជារៀងរហូតនៅលើទឹកដីប្រាសាទព្រះវិហារដ៏សក្តិសិទ្ធិ»

រឹម ពេជ្រជារ៉ូ




អ្នកស្រី ឡាំ វង ត្រូវជាម្តាយរបស់វីរកងទ័ព ហេង កំសាន្ត និងប្អូនស្រីរបស់ ហេង កំសាន្ត។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជារៀងរាល់យប់ ជាពិសេសនៅពេលមេឃចុះត្រជាក់ ខ្ញុំតែងតែនឹកឃើញដល់កូនប្រុសដែលបានសម្រាន្តជារៀងរហូតនៅលើទឹកដីប្រាសាទព្រះវិហារដ៏សក្តិសិទ្ធិ។ អ្នកស្រី ឡាំ វង ម្តាយរបស់វីរកងទ័ពកម្ពុជាឈ្មោះ វរសេនីយ៍ត្រី ហេង កំសាន្ត បានរៀបរាប់រឿងរ៉ាវរបស់ខ្លួនដែលជាស្ត្រីមេម៉ាយ និងអនុស្សាវរីយ៍ជាមួយកូនប្រុសដូចខាងក្រោម៖

នាងខ្ញុំឈ្មោះ ឡាំ វង អាយុ៦៥ឆ្នាំ រស់នៅភូមិសំរោងជើង ឃុំសំរោង ស្រុកសូទ្រនិគម ខេត្តសៀមរាប។ ប្តីខ្ញុំឈ្មោះ ហេង សួរ បានស្លាប់ដោយសារជំងឺតាំងពីឆ្នាំ២០០៨។ ខ្ញុំមានកូនពីរនាក់ គឺកូនទី១) វរសេនីយ៍ត្រី ហេង កំសាន្ត ភេទប្រុស អាយុ៣៣ឆ្នាំ និងកូនទី២) ឈ្មោះ ហេង សៀវម៉ី ភេទស្រីអាយុ២៨ឆ្នាំ ។ គ្រួសារខ្ញុំគឺជាកសិករធ្វើស្រែចម្ការ។

ពេលប្តីខ្ញុំទទួលមរណភាព កូនប្រុសខ្ញុំទើបតែមានអាយុ១៥ឆ្នាំ និងកូនស្រីមានអាយុ១០ឆ្នាំ។ ខ្ញុំត្រូវខំប្រឹងប្រែងតស៊ូធ្វើស្រែចម្ការតែម្នាក់ឯងដើម្បីរកប្រាក់មកផ្គត់ផ្គង់ជីវភាពគ្រួសារ និងឱ្យកូនៗបន្តការ

សិក្សាទៅមុខទៀត។ បន្ទាប់ពីកូនប្រុសខ្ញុំបានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ (ឌីប្លូម) នៅអនុវិទ្យាល័យសំរោង ក៏បានផ្លាស់ទៅរៀនបន្តនៅវិទ្យាល័យ ១០ មករា ក្រុងសៀមរាប ខេត្តសៀមរាប។ ពេលនោះកូនប្រុសខ្ញុំបានស្នាក់នៅផ្ទះរបស់អ៊ំស្រីឈ្មោះ មុំ ដែលជាបងស្រីបង្កើតរបស់ឪពុកខ្លួន។ ទោះបីអត់ពីឪពុកនិងខ្វះខាតថវិការៀនសូត្រ កូនប្រុសខ្ញុំនៅតែខិតខំប្រឹងប្រែងរៀនសូត្ររហូតបានក្លាយជាសិស្សពូកែម្នាក់ប្រចាំវិទ្យាល័យ ១០ មករា។ កូនប្រុសខ្ញុំបានប្រឡងបញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ (បាក់ឌុប) នៅក្នុងឆ្នាំសិក្សា២០១០-២០១១ ដោយទទួលបានលទ្ធផលល្អ។ ប៉ុន្តែដោយសារគ្រួសារខ្ញុំមានជីវភាពខ្វះខាត ខ្ញុំមិនមានលទ្ធភាពក្នុងការចំណាយថវិកាឱ្យកូនប្រុសរៀនបន្តនៅថ្នាក់ឧត្តមសិក្សាឡើយ។ កូនប្រុសខ្ញុំបានរៀនជួសជុលទូរសព្ទដៃនៅក្រុងសៀមរាបមួយរយៈពេលខ្លី មុនពេលចាកចេញទៅស្វែងរកការងារធ្វើនៅក្រុងតាខ្មៅជាមួយមិត្តភក្តិ។ សំណាងល្អកូនប្រុសខ្ញុំបានស្គាល់អ៊ំប្រុសម្នាក់ឈ្មោះ ឆេង មានសណ្ឋានចិត្តល្អបានអនុញ្ញាតឱ្យកូនប្រុសខ្ញុំស្នាក់នៅក្នុងផ្ទះជាមួយនិងបានរាប់អានគ្នាជាឪពុក និងកូនចិញ្ចឹមថែមទៀត។ ឪពុកចិញ្ចឹមរបស់កូនប្រុសខ្ញុំបានជួយជ្រោមជ្រែង និងណែនាំឱ្យកូនប្រុសខ្ញុំឱ្យចូលបម្រើការងារជាកងទ័ពបម្រុងនៅបញ្ជាការដ្ឋានកងអង្គរក្ស។ បន្ទាប់ពីបានឆ្លងកាត់ការហ្វឹកហ្វឺនបច្ចេកទេសយោធាយ៉ាងស៊ិតស៊ាញជាច្រើនដំណាក់កាល និងច្រើនកន្លែងមក ទើបកូនខ្ញុំត្រូវបានបញ្ចូលទៅក្នុងក្របខណ្ឌកងទ័ពពេញសិទ្ធិនៃបញ្ជាការដ្ឋានកងអង្គរក្ស។ បន្ទាប់ពីបានបម្រើការងារជាកងទ័ពនៅបញ្ជាការដ្ឋានកងអង្គរក្សអស់រយៈពេលជាង១០ឆ្នាំ កូនប្រុសខ្ញុំមានឋានន្តរសក្តិជាវរសេនីយ៍ត្រីក្នុងអង្គភាពបញ្ជូនសារនៃបញ្ជាការដ្ឋានកងអង្គរក្ស។

ក្រោយពីមានការបាញ់សម្លាប់កងទ័ពកម្ពុជាម្នាក់ដែលមិនមានអាវុធនៅក្បែរលេណដ្ឋានក្នុងភូមិសាស្ត្រមុំបីនៃស្រុកជាំក្សាន្ត ខេត្តព្រះវិហារនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥ សភាពការណ៍នៅតាមព្រំដែនកម្ពុជា-ថៃ មានការតានតឹងខ្លាំងបន្តបន្ទាប់។ កូនប្រុសខ្ញុំ និងកងទ័ពផ្សេងទៀតត្រូវបានអង្គភាពបញ្ជូនទៅប្រចាំការនៅសមរភូមិទិសទី១ ប្រាសាទព្រះវិហារ។ កូនប្រុសខ្ញុំមានតួនាទីជាភ្នាក់ងារបញ្ជូនសារពីសមរភូមិមកអង្គភាពនៅពេលមានជម្លោះព្រំដែនកម្ពុជា-ថៃផ្ទុះឡើង។ កូនប្រុសខ្ញុំបានប្រាប់ថាតួនាទីជាអ្នកបញ្ជូនសារ គឺមានសារសំខាន់ខ្លាំង ហើយក៏មានគ្រោះថ្នាក់ណាស់ដែរ។ អ្នកបញ្ជូនសារត្រូវក្តាប់ព័ត៌មាន និងឆ្លើយឆ្លងរាល់សភាពការណ៍សង្គ្រាមទៅទីបញ្ជាការដ្ឋាន។

ខ្ញុំតែងតែហៅទូរសព្ទទៅកូនប្រុសជារៀងរាល់ថ្ងៃ ដើម្បីសួរសុខទុក្ខ និងដាស់តឿនឱ្យកូនប្រុសប្រុងប្រយ័ត្ន៖ «កូនឯងត្រូវប្រយ័ត្ន ខ្លាចគេវាយដាប់រាប់ខែ កូនឯងត្រូវត្រៀមស្បៀងក្រៀម ដូចជាមី និងអាហារដែលអាចហូបចុកបានយូរថ្ងៃឱ្យបានច្រើន ពីព្រោះពេលសង្គ្រាមផ្ទុះឡើងយើងមិនអាចចេញមកយកស្បៀងបានដោយងាយស្រួលទេ»។ កូនប្រុសខ្ញុំបានថតរូបផ្ញើមកឱ្យខ្ញុំមើល។ ខ្ញុំឃើញកន្លែងដែលកូនប្រុសស្នាក់នៅក្នុងលេណដ្ឋានរឹងមាំដូចផ្ទះថ្ម ហើយឃើញមានអាយកុម១០-២០គ្រឿងនៅលើតុ។ ពេលខ្ញុំឃើញលេណដ្ឋានកូនប្រុសរឹងមាំបែបនោះ ខ្ញុំហាក់មានអារម្មណ៍មិនសូវព្រួយបារម្ភ ព្រោះគិតថាកូនប្រុសខ្ញុំមានសុវត្ថិភាពនិងអាចការពារខ្លួនបាន។ ក្រោយមកទៀតកូនប្រុសខ្ញុំប្រាប់ខ្ញុំថា គាត់សម្រាកនៅក្នុងលេណដ្ឋាន។ ខ្ញុំសួរទៅកូនប្រុសខ្ញុំវិញថា ហេតុដូចម្តេចក៏សម្រាកក្នុងលេណដ្ឋាន បើស្ងាត់សង្គ្រាមហើយ? ខ្ញុំបានហៅទូរស័ព្ទទៅកូនប្រុសខ្ញុំស្ទើររាល់ថ្ងៃ ហើយកូនប្រុសខ្ញុំបានប្រាប់ថាដ្រូន(យន្តហោះគ្មានមនុស្សបើក) របស់សត្រូវបានហោះឆ្វែលរាល់ថ្ងៃ ប៉ុន្តែវាហោះនៅប៉ែកម្ខាងទៀត។

នៅវេលាម៉ោង៨ព្រឹក ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៥ កូនស្រីខ្ញុំឈ្មោះ ហេង សៀវម៉ី បានហៅទូរសព្ទទៅបងប្រុសតែមិនអាចទាក់ទងបាន។ ខ្ញុំឱ្យកូនស្រីហៅទូរសព្ទទៅគ្រប់ប្រកលួកនៅតែអត់អាចទាក់ទងបានទៀត។ ខ្ញុំក៏ហៅទូរសព្ទទៅអ្នកធ្លាប់ស្គាល់គ្នានៅឃុំស្រអែម គឺជាម្ចាស់អគ្គិសនីនៅផ្សារស្រអែមចម្ងាយពីកន្លែងកូនខ្ញុំប្រហែល៨គីឡូម៉ែត្រ។ ម្ចាស់អគ្គិសនីនោះបានប្រាប់ខ្ញុំថា គ្រាប់ផ្លោងកំពុងធ្លាក់ច្រើន និងធ្លាក់ខាងកើតផ្ទះគាត់មួយគ្រាប់ដែរ។ កងទ័ព និងប្រជាជន

ស៊ីវិលបាននាំគ្នាចូលក្នុងលេណដ្ឋានអស់ហើយ។ ពេលនោះខ្ញុំនឹកឃើញថា ប្រហែលកូនប្រុសខ្ញុំបិទទូរសព្ទកុំឱ្យស្រួបរលកសញ្ញា។

លុះដល់ម៉ោងជិត១០ព្រឹកថ្ងៃដដែលនោះ អង្គភាពកូនប្រុសខ្ញុំនៅក្រុងតាខ្មៅបានទូរសព្ទមកប្រាប់ថា កូនប្រុសខ្ញុំស្លាប់ហើយ។ បន្ទាប់ពីទទួលព័ត៌មានដ៏រន្ធត់នោះ កូនស្រីខ្ញុំហៅទូរសព្ទទៅមេអង្គភាពកូនប្រុសខ្ញុំដើម្បីបញ្ជាក់។ មេអង្គភាពកូនប្រុសខ្ញុំបានប្រាប់ថា កន្លែងកូនប្រុសខ្ញុំបានត្រូវគ្រាប់ផ្លោងរបស់សត្រូវចំនួន៣គ្រាប់ និងបានធ្លុះរហូតដល់ខាងក្នុង។

បន្ទាប់មកអង្គភាពកូនប្រុសខ្ញុំបានប្រាប់ឱ្យខ្ញុំទៅធ្វើដំណើរទៅទីក្រុងភ្នំពេញ ពីព្រោះអង្គភាពបានកំពុងដឹកសពកូនប្រុសខ្ញុំឆ្ពោះទៅក្រុងតាខ្មៅ។ ខ្ញុំបានព្យាយាមធ្វើដំណើរពីភូមិរហូតមកដល់ទីក្រុងតាខ្មៅនៅយប់ថ្ងៃដដែលនោះ គឺក្នុងគោលបំណងចុងក្រោយថានឹងបានស្ទាបអង្អែលមុខកូនប្រុសជាលើកចុងក្រោយ ប៉ុន្តែអ្វីៗមិនបានដូចបំណងឡើយ ពីព្រោះសពកូនប្រុសខ្ញុំ និងសពវីរកងទ័ពចំនួន៣នាក់ទៀតត្រូវបានអង្គភាពដាក់ក្នុងមឈូសបិទជិតហើយ។ ក្មួយប្រុសរបស់ខ្ញុំដែលបានមកដល់មុនបានប្រាប់ខ្ញុំទាំងទឹកភ្នែកថា៖ “កូនមីងឆេះអស់ហើយ នៅសល់តែផ្លាកឈ្មោះដែលជាប់នឹងឯកសណ្ឋានកងទ័ពប៉ុណ្ណោះ”។ សម្ដីនេះបានធ្វើឱ្យខ្ញុំសឹងតែសន្លប់បាត់បង់ស្មារតី ពីព្រោះរូបភាពកូនប្រុសដ៏ស្លូតបូត ពេលនេះ សូម្បីតែមុខមាត់ក៏មិនអាចបានឃើញជាលើកចុងក្រោយ។

កូនប្រុសខ្ញុំបានពលីនៅសមរភូមិទិសប្រាសាទព្រះវិហារ គឺជាការបាត់បង់សមាជិកគ្រួសារដ៏សំខាន់ម្នាក់ ប៉ុន្តែកូនប្រុសខ្ញុំបានបូជាសាច់ស្រស់ឈាមស្រស់ក្នុងបុព្វហេតុការពារជាតិមាតុភូមិឱ្យស្ថិតនៅគង់វង្សបន្តទៀត។

ទោះបីកូនប្រុសខ្ញុំបានលាចាកលោកទៅហើយ ប៉ុន្តែកូនប្រុសស្ថិតនៅក្នុងក្រអៅបេះដូងរបស់ខ្ញុំដែលជាម្ដាយជានិច្ច។ ខ្ញុំជឿជាក់ថា ប្រជាជនកម្ពុជាជាពិសេសយុវជនជំនាន់ក្រោយ នឹងចងចាំឈ្មោះកូនប្រុសខ្ញុំ វីរសេនីយ៍ត្រី ហេង កំសាន្ត និងវីរកងទ័ពកម្ពុជាផ្សេងៗទៀតជារៀងរហូត។




វីរកងទ័ព ហេង កំសាន្ត ពលីនៅសមរភូមិទិសទី១ ប្រាសាទព្រះវិហារ ស្ថិតនៅក្នុងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




ពិធីបុណ្យសពវីរកងទ័ព ហេង កំសាន្ត។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ម៉ែន គា ៖ ខ្ញុំចូលហ្វឹកហាត់កងទ័ពដំបូង ជាមួយអង្គភាពទ័ពវៀតណាម

**សោម ប៊ុនថន**

ខ្ញុំឈ្មោះ ម៉ែនគា កើតក្នុងឆ្នាំ១៩៥២ នៅភូមិអង្គបុស្ស៊ី ឃុំស្វាយធំ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ សព្វថ្ងៃ ខ្ញុំគឺជាមេភូមិអង្គបុស្ស៊ី។ ខ្ញុំមានឪពុកឈ្មោះ ម៉ែន ឃីម និងម្ដាយឈ្មោះ ឃួន ភីម។ ខ្ញុំមានបងប្អូនចំនួន៩ នាក់ គឺស្រី៤នាក់ និងប្រុស៥នាក់ ហើយខ្ញុំគឺជាកូនពៅ។ កាលពីតូច ខ្ញុំរៀននៅសាលាក្នុងភូមិ ដល់ថ្នាក់ទី១០ពីសង្គមចាស់ក៏ឈប់រៀន។ នៅពេល លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ ចេញពីតំណែង នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ខ្ញុំមានអាយុ១៨ឆ្នាំ។ ខ្ញុំបានឮសម្ដេចព្រះ នរោត្តម សីហនុ ប្រកាសប្រាប់កូនចៅ ទាំងអស់ឱ្យចូលព្រៃម៉ាគីតស៊ូប្រឆាំងនឹងរបប លន់ នល់។ ខ្ញុំ និងយុវជនក្នុងភូមិប្រមាណជាង១០បានចាកចេញពីផ្ទះ ទៅចូលរួមជាមួយចលនាតស៊ូតាមការអំពាវនាវរបស់ព្រះអង្គ។ ដំបូង ខ្ញុំនៅ ហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រយោធា នៅក្នុងភូមិស្វាយ ក្នុងស្រុកស្វាយជ្រំ ជាមួយកងទ័ពវៀតណាម។ ក្រោយមក ទើបខាងចលនាតស៊ូខ្មែរក្រហមបានរៀបចំឱ្យមានអង្គភាពទ័ពខ្មែរហៅថា សេប្រាំ (C5) ស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងទ័ពស្រុកស្វាយជ្រំ សហការជាមួយកងទ័ពវៀតណាមខាងជើង (វៀតកុង) ដើម្បីវាយកងទ័ព លន់ នល់ និងទាហានវៀតណាមខាងត្បូង (ធីវគី) ដែលគាំទ្រដោយអាមេរិក។ អំឡុងពេលនោះ ខ្ញុំបានផ្ទេរពីអង្គភាពទ័ពវៀតណាម មកនៅក្នុងអង្គភាពទ័ពរបស់ខ្មែរវិញ។

នៅពេលកងទ័ពបដិវត្តន៍ខ្មែរក្រហមវាយដណ្ដើមបានជ័យជម្នះលើរបប លន់ នល់ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អង្គភាពយោធាស្រុកស្វាយជ្រំរបស់ខ្ញុំ ត្រូវបានចាត់តាំងឱ្យមកនៅកងបង្កបង្កើនផល



ម៉ែន គា គឺជាមេភូមិអង្គបុស្ស៊ី សព្វថ្ងៃរស់នៅភូមិអង្គបុស្ស៊ី ឃុំស្វាយធំ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

របស់ទ័ព គឺគ្រប់គ្រង និងប្រមូលដីលាមកមនុស្សសត្វទុកសម្រាប់ធ្វើជីដាក់ស្រូវនិងដំណាំ ដោយក្នុងមួយក្រុមមានសមាជិក១២នាក់។ ខ្ញុំត្រូវបររទេះដឹកជញ្ជូនជីយកមកទុកនៅក្នុងកង ដូចជាប្រជាជននៅតាមសហករណ៍ដែរ។ ចំណែករបបអាហារខ្ញុំហូបមិនបានគ្រប់គ្រាន់ទេ ព្រោះខាងចុងភៅចែកអង្ករឱ្យយោធាម្នាក់កន្លះកំប៉ុងក្នុងមួយពេលសម្រាប់ហូប។ ក្នុងមួយសប្ដាហ៍ខ្ញុំហូបបាយបានតែមួយថ្ងៃតែប៉ុណ្ណោះ គឺថ្ងៃអាទិត្យ ក្រៅពីនោះខ្ញុំហូបបបរជាមួយសម្លម្ជូរដើមចេក និងម្ជូរត្រកួន។ នៅក្នុងរបបខ្មែរក្រហម ចុងភៅស្ទើរមិនសូវដាក់សាច់ទេ គឺដាក់តែប្រហុក។ ទោះបីខ្ញុំគឺជាកងទ័ព ប៉ុន្តែខ្មែរក្រហមបានបំពាក់បំប៉នគោល

ជំហរឱ្យខ្ញុំលះបង់វណ្ណៈឱ្យអស់ និងរស់នៅដូចប្រជាជនដែរ គឺមិនមានទ្រព្យសម្បត្តិ ឬរបស់របរផ្ទាល់ខ្លួនឡើយ។ រីឯរបបអាហារ ហូបចុកថ្នាក់លើបានកំណត់ដូច្នេះខ្ញុំមិនអាចប្រកែកតវ៉ាបានឡើយ។ ក្រៅពីការងារប្រមូលដី ខ្ញុំត្រូវធ្វើការងារដកស្ទូង និងច្រូតស្រូវនៅក្នុងអង្គភាព។ ថ្ងៃមួយ ពេលខ្ញុំសុំច្បាប់អង្គភាពយោធាស្រុកស្វាយជ្រំមកលេងផ្ទះ ខ្ញុំបានឃើញខ្មែរក្រហមរុះព្រះវិហារ កុដិ និងវាយបំផ្លាញព្រះពុទ្ធបដិមាមួយចំនួននៅភូមិអង្គបុស្សី។ ខ្មែរក្រហមបានយកទីតាំងវត្តអង្គបុស្សី សម្រាប់កងសន្តិសុខ និងឆ្មាំគុកខ្មែរក្រហមឃុំឃាំង និងធ្វើទារុណកម្មប្រជាជន១៧ មេសា ដែលជម្លៀសមកពីទីក្រុងភ្នំពេញ និងក្រុងស្វាយរៀង ដែលត្រូវបានចោទប្រកាន់ថាជាខ្មាំង។ នៅពេលយប់ឆ្មាំគុកបានដាក់ខ្នោះជើងអ្នកទោសទាំងអស់ភ្ជាប់ទៅនឹងរនុកដែកវែងជាជួរ និងឱ្យដេកក្បាលទល់គ្នា។ នៅពេលថ្ងៃឆ្មាំគុកបញ្ជូនអ្នកទោសទាំងអស់ទៅធ្វើការងារពលកម្មនៅតាមសហករណ៍នានា ប៉ុន្តែមិនបានផ្តល់របបអាហារឱ្យអ្នកទោសទាំងនោះស្មើនឹងប្រជាជនឡើយ។ អ្នកទោសភាគច្រើនបានស្លាប់ និងមួយចំនួនទៀតបានធ្លាក់ខ្លួនឈឺធ្ងន់ ហើយត្រូវឆ្មាំគុកសែងយកទៅវាយសម្លាប់ជាមួយត្បូងចប និងគល់ឫស្សីរួចហើយកប់ចោលនៅទួលខាងត្បូងវត្តអង្គបុស្សីតែម្តង។ គុកវត្តអង្គបុស្សីគឺជាគុកធំជាងគេនៅក្នុងឃុំស្វាយធំ ស្រុកស្វាយជ្រំ។

ក្រោយមកអង្គភាពបានបញ្ជូនខ្ញុំពីស្រុកស្វាយជ្រំទៅការពារព្រំដែនជាប់វៀតណាមក្នុងស្រុកចន្ទ្រា។ អំឡុងពេលនោះ ខ្មែរក្រហមបានប្រកាសប្រាប់ប្រជាជន និងកងទ័ពថានឹងវាយវៀតណាម ដើម្បីទាមទារយកទឹកដីកម្ពុជាក្រោមត្រឡប់មកវិញ។ នៅឆ្នាំ១៩៧៧ ខ្ញុំនិងអង្គភាពទ័ពខ្មែរក្រហមបានវាយតទល់ជាមួយកងទ័ពវៀតណាម ហើយត្រូវកងទ័ពវៀតណាមបាញ់បណ្តាលឱ្យខ្ញុំដាច់សរសៃជើង និងបាក់ឆ្អឹងស្មងជើងមួយកំណាត់។ អង្គភាពយោធាខ្មែរក្រហមបានបញ្ជូនខ្ញុំពីសមរភូមិទៅព្យាបាលនៅមន្ទីរពេទ្យក្នុងទីក្រុងភ្នំពេញ។ ខ្ញុំសម្រាកព្យាបាលនៅមន្ទីរពេទ្យមិនទាន់ជាសះស្បើយផង ស្រាប់តែកងទ័ពវៀតណាមវាយចូលមកតាមព្រំដែននៅចុងឆ្នាំ១៩៧៨។ ខ្មែរក្រហមបានបញ្ជាឱ្យប្រធានពេទ្យបញ្ជូនយោធារងរបួសដែលកំពុងសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យទាំងអស់តាមរថភ្លើងឆ្ពោះទៅកាន់ខេត្តបាត់ដំបង។ នៅពេលខ្ញុំទៅដល់ក្រុងបាត់ដំបង យន្តហោះកងទ័ពវៀតណាមបានហោះមកទម្លាក់គ្រាប់បែកចំឃ្លាំងគ្រាប់របស់ខ្មែរក្រហមបណ្តាលឱ្យផ្ទុះឆេះយ៉ាងសន្ធោសន្ធៅ។ ពេលនោះក្រុមគ្រូពេទ្យ និងអ្នកជំងឺបានរត់បែកខ្ញែកគ្នាចូលក្នុងព្រៃលាក់ខ្លួន ចំណែកខ្ញុំបានភៀសខ្លួនបន្តទៅដល់ប៉ៃលិន។ នៅទីនោះ ខ្ញុំឃើញតែសត្វពាហនៈ ជ្រូក មាន់ ទា គោ ដោយឡែកប្រជាជន និងកម្មាភិបាលខ្មែរក្រហមបានចាកចេញទៅរស់នៅតាមព្រំដែនថៃអស់ហើយព្រោះខ្លាចកងទ័ពវៀតណាម។ ខ្ញុំនិងយោធាខ្មែរក្រហមពិការរួមទាំងពេទ្យមួយចំនួនបាននាំគ្នាចូលយកឃ្លាំង និងអង្ករនៅតាមសហករណ៍មកដាំបាយហូប។ ខ្ញុំរស់នៅប៉ៃលិនបានមួយរយៈ ទើបកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាមបាចគ្រាប់ដែលមានខ្លឹមសារថា សូមពុកម៉ែបងប្អូនវិលត្រឡប់មកស្រុកកំណើតវិញព្រោះប្រទេសជាតិបានរំដោះហើយ។ ខ្ញុំបានធ្វើដំណើរចេញពីប៉ៃលិនសំដៅមកខេត្តកំពង់ស្ពឺ ក៏ជួបនឹងកងទ័ពវៀតណាមនៅតាមផ្លូវ។ កងទ័ពវៀតណាមបានសួរខ្ញុំ និងអ្នកភៀសខ្លួនផ្សេងទៀតថា បងប្អូនរស់នៅទីកន្លែងណា? ខ្ញុំបានប្រាប់ថានៅខេត្តស្វាយរៀង។ ខណៈនោះ កងទ័ពវៀតណាមនាំខ្ញុំនិងអ្នកជម្លៀសផ្សេងទៀតនៅអង្គភាពទ័ពវៀតណាម និងបានដាំបាយឱ្យយើងហូបម្នាក់មួយឆ្អែត បន្ទាប់មកទើបបញ្ជូនយើងទៅកន្លែងអប់រំនយោបាយ ស្ថិតនៅជាប់ផ្លូវជាតិលេខ៤។ កងទ័ពវៀតណាមបានប្រាប់ខ្ញុំនិងអ្នកភៀសខ្លួនផ្សេងទៀតកុំឱ្យភ័យបារម្ភ ហើយនៅថ្ងៃបន្ទាប់ ខ្ញុំនិងអ្នកភៀសខ្លួនបានដើរបន្តឆ្ពោះទៅកាន់ទីក្រុងភ្នំពេញ។ ខ្ញុំបានទៅបើកអង្ករពីរដ្ឋអំណាចនៅម្តុំទួលគោកបានចំនួន៥គីឡូ បន្ទាប់មក ខ្ញុំដើរសំដៅមកខេត្តព្រៃវែងនិងរស់នៅជាមួយបងបានមួយរយៈ ទើបត្រឡប់មករស់នៅស្រុកកំណើតក្នុងខេត្តស្វាយរៀងវិញ។ ខ្ញុំបានធ្វើចូលធ្វើការងារក្នុងក្រុមប្រវាស់ដៃ ហើយក្រោយមកទើបប្រជាជនជ្រើសរើសឱ្យខ្ញុំធ្វើជាមេភូមិ។ សព្វថ្ងៃខ្ញុំមានជំងឺតេតាណូស ដោយសារអំបែងគ្រាប់បន្សល់នៅក្នុងខ្លួនតាំងពីសម័យសង្គ្រាម និងមានជំងឺលើសឈាម។

# អាកាសយានដ្ឋានពោធិ៍ចិនតុងៈ ហេដ្ឋារចនាសម្ព័ន្ធមួយដែលតម្កល់ការចងចាំ និងប្រកបដោយកាលានុវត្តភាព

អ៊ាន បញ្ញាឫទ្ធិ



*លោក ឆាំង យុ (ពាក់អាវធំ) និងក្រុមស្ថាបត្យករវ័យក្មេងព្រះរាជបណ្ណាល័យ ហ្វូងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា និងបុគ្គលិក នៅព្រលានយន្តហោះអន្តរជាតិពោធិ៍ចិនតុង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

អាកាសយានដ្ឋាន គឺជាហេដ្ឋារចនាសម្ព័ន្ធដែលមានមុខងារចម្រុះខ្ពស់ និងបង្កប់នូវអត្ថន័យជានិមិត្តរូបយ៉ាងជ្រាលជ្រៅ។ អាកាសយានដ្ឋាន គឺជាចំណងភ្ជាប់រវាងប្រជាជាតិមួយទៅកាន់ពិភពលោក។ យើងអាចសិក្សាស្វែងយល់ពីប្រវត្តិសាស្ត្ររបស់ប្រទេសមួយបាន តាមរយៈការផ្លាស់ប្តូរនៃទីតាំងអាកាសយានដ្ឋានរបស់ប្រទេសនោះ។ នៅក្នុងទីក្រុងភ្នំពេញ អាកាសយានដ្ឋានអន្តរជាតិពោធិ៍ចិនតុង បានឈរជាសាក្សីនៃការផ្លាស់ប្តូរនៃរបបដឹកនាំនៅក្នុងប្រទេសកម្ពុជា នាអំឡុងសតវត្សរ៍កន្លងទៅ ដោយរាប់ចាប់តាំងពីសម័យអាណានិគម រហូតដល់សម័យឯករាជ្យ ឆ្លងកាត់របបប្រល័យពូជសាសន៍ ការរំដោះជាតិ រហូតមកដល់សេដ្ឋកិច្ចដ៏មមាញឹកនាពេលបច្ចុប្បន្ន។ អស់រយៈកាលកន្លងទៅនេះ ការជួសជុលកែលម្អថ្មីៗនីមួយៗនៃអាកាសយានដ្ឋានពោធិ៍ចិនតុង បានចាក់ស្រេះរួមបញ្ចូលគ្នាជាមួយនឹងស្ថាបត្យកម្ម និងទិដ្ឋភាពជុំវិញដែលបន្សល់ពីអតីតកាល រហូតដល់ពេលវេលាដែលប្រទេសកម្ពុជាបានរីកចម្រើនលើសពីសមត្ថភាពដែលអាកាសយានដ្ឋាននេះ អាចទ្រទ្រង់បានទាំងស្រុង។

កាលពីឆ្នាំមុន អាកាសយានដ្ឋានអន្តរជាតិតេជោដែលមានទីតាំងស្ថិតនៅចម្ងាយ ២០ គីឡូម៉ែត្រ ភាគ

ខាងត្បូងរាជធានីភ្នំពេញ បានបើកដំណើរការ។ ដោយមានទំហំធំជាងអាកាសយានដ្ឋានពោធិ៍ចិនតុង ប្រមាណជាង ៥ ដង និងត្រូវបានសាងសង់ឡើងតាមបទដ្ឋានទំនើបចុងក្រោយបំផុត អាកាសយានដ្ឋានអន្តរជាតិតេជោ ត្រូវបានរចនាឡើងដោយក្រុមហ៊ុន Foster + Partners តាមរចនាបថស្ថាបត្យកម្មអាកាសយានដ្ឋានដ៏ល្បីល្បាញប្រចាំក្រុមហ៊ុននេះ។ អាកាសយានដ្ឋានអន្តរជាតិតេជោ ឆ្លើយតបទៅនឹងតម្រូវការដែលកំពុងកើនឡើងរបស់ប្រទេសកម្ពុជា និងបម្រើជាវិធានវាស់វែងអំពីកម្រិតអភិវឌ្ឍន៍របស់ជាតិ ហើយនេះ ក៏គូសបញ្ជាក់អំពីការបញ្ចប់ប្រតិបត្តិការរបស់អាកាសយានដ្ឋានអន្តរជាតិពោធិ៍ចិនតុងដែរ។

នៅពេលដែលត្រូវបានបញ្ចប់តួនាទីដែលបានកំណត់ទុក តើមានអ្វីកើតឡើងចំពោះសំណង់ស្ថាបត្យកម្មនៃអាកាសយានដ្ឋានពោធិ៍ចិនតុង ដែលត្រូវបានរចនាឡើងយ៉ាងល្អិតល្អន់ក្នុងការបម្រើដល់តួនាទីជាក់លាក់របស់ខ្លួន? ចំពោះទីធ្លាមួយដែលតម្កល់នូវប្រវត្តិសាស្ត្រយ៉ាងច្រើនសម្បូរបែបនេះ តើអត្ថន័យរបស់អាកាសយានដ្ឋានពោធិ៍ចិតតុង អាចបន្តវិវត្តទៅមុខទៀតយ៉ាងដូចម្តេច?

សមាគមស្ថាបត្យករខ្មែរ បានរៀបចំការប្រកួតប្រជែងមួយក្រោមប្រធានបទ «ពោធិ៍ចិនតុងកើតឡើងវិញ» ដោយអញ្ជើញស្ថាបត្យករវ័យក្មេងឱ្យមកបញ្ចេញស្នាដៃច្នៃប្រឌិតថ្មីៗ ដើម្បីស្វែងរកចម្លើយចំពោះសំណួរទាំងនេះ។ ការប្រកួតប្រជែងនេះ បានស្វែងរកគំនិតក្នុងការបំប្លែងអតីតអាកាសយានដ្ឋានភ្នំពេញចាស់នេះឱ្យទៅជា «ទីក្រុងអេប៉ុង» ដោយផ្តោតសំខាន់លើភាពធន់ជាមួយការជន់លិចក្នុងក្រុងតំបន់លំហបៃតង និងការគ្រប់គ្រងធនធានទឹក។ ក្នុងចំណោមស្នាដៃប្រកួតប្រជែងទាំងអស់ ស្នាដៃរបស់ក្រុមស្ថាបត្យករនៃព្រះរាជបណ្ណាល័យ ហ្វូងម៉ែ ដែលរួមមានលោក ទិត្យ សត្យាវង្ស, កញ្ញា លាង ចាន់ធី, កញ្ញា លឹម វណ្ណសូលីហ្សា និងលោក វនរ័ត្នវិសាល ដែលទទួលបានជ័យលាភីលេខ១ស្ទួន បានបញ្ចូលនូវក្របខ័ណ្ឌបន្ថែមទៅក្នុងគម្រោងទីក្រុងអេប៉ុងនេះ។ ក្របខ័ណ្ឌទាំងនោះ មិនត្រឹមតែផ្តល់នូវការគោរពផ្តល់តម្លៃដល់ប្រវត្តិសាស្ត្រនៃអាកាសយានដ្ឋានពោធិ៍ចិនតុងតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបង្ហាញនូវចក្ខុវិស័យសម្រាប់អនាគតសម្រាប់ទីតាំងនេះ និងទីក្រុងទាំងមូលថែមទៀតផង។

ក្រុមស្ថាបត្យករនៃព្រះរាជបណ្ណាល័យ ហ្វូងម៉ែ បានប្រើប្រាស់អគារអ្នកដំណើរ និងរោងជួសជុលយន្តហោះដែលមានស្រាប់ ដើម្បីបម្រើដល់ពហុមុខងារផ្នែកវប្បធម៌ និងការអប់រំ ដោយប្រែក្លាយទីតាំងនេះទៅជាមជ្ឈមណ្ឌលសម្រាប់ពលរដ្ឋ សង្គម និងសេដ្ឋកិច្ចនៅចំកណ្តាលនៃទីក្រុងភ្នំពេញ។ ចំពោះទីលានចុះចតយន្តហោះដ៏ធំទូលាយវិញ រួមមានផ្ទៃដីក្រាលដោយបេតុង តំបន់បៃតង និងតំបន់ដីសើម ត្រូវបានរៀបចំឱ្យដំណើរការរួមគ្នាជាប្រព័ន្ធជលសាស្ត្រ ដើម្បីប្រមូល និងប្រើប្រាស់ទឹកឡើងវិញសម្រាប់ការស្រោចស្រព និងតម្រូវការផ្សេងៗក្នុងបរិវេណនោះ។ ជាពិសេស ទីតាំងនេះនឹងជួយគ្រប់គ្រងលំហូរទឹកភ្លៀង ដើម្បីកសាងភាពធន់នឹងការជន់លិចក្នុងក្រុង។ បន្ថែមលើប្រព័ន្ធប្រកបដោយប្រសិទ្ធភាពនេះ លំហបៃតងដ៏ចាំបាច់ និងមានភាពបត់បែនសម្រាប់សហគមន៍ នឹងបង្កើតបានជាខែលការពារ និងប្រព័ន្ធបញ្ចុះកម្តៅប្រឆាំងនឹងការកើនឡើងនៃសីតុណ្ហភាពក្នុងតំបន់។ ផ្លូវដើរដែលត្រូវបានរៀបចំយ៉ាងហ្មត់ចត់ជុំវិញទីលានចុះចតយន្តហោះនេះ នឹងនាំផ្លូវអ្នកថ្មើរជើងឱ្យឆ្លងកាត់ធម្មជាតិ ការដាក់តាំងស្នាដៃសិល្បៈថ្មីៗ និងស្តូបអនុស្សាវរីយ៍រំឭកដល់វីរកងទ័ពដ៏អង់អាចដែលបានធ្វើពលិកម្មដើម្បីប្រទេសជាតិ។

ទីក្រុងអេប៉ុង និងលំហសហគមន៍ដ៏រស់រវើកនេះ នឹងផ្លាស់ប្តូរមុខមាត់របស់អាកាសយានដ្ឋានពោធិ៍ចិនតុងក្នុងការបម្រើនូវមុខងារថ្មី ដោយផ្តល់និយមន័យថ្មីដល់អត្ថន័យនៃ «ពោធិ៍ចិនតុង» រួចជាស្រេចទៅហើយ។ ទោះបីជាយ៉ាងណាក៏ដោយ កេរដំណែលមួយដែលគ្រោងឡើងសម្រាប់អនាគតនេះ គួរតែមានវិសាលភាពឆ្ងាយហួសពីពេលអ្វីដែលមានស្រាប់នាពេលបច្ចុប្បន្ន។

នៅប៉ែកអាគ្នេយ៍នៃបរិវេណអាកាសយានដ្ឋានពោធិ៍ចិនតុង ដែលហ៊ុមព័ទ្ធទៅដោយតំបន់ដីសើម

និងស្ថិតនៅ ទល់មុខតំបន់លំនៅឋានដីកុះករ ក្រុមស្ថាបត្យករនៃព្រះរាជបណ្ណាល័យ ហ្វូងម៉ែ បានស្នើឱ្យដាក់ទីតាំង «ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ» ដែលជាវិទ្យាស្ថាន-សារមន្ទីរ រចនាឡើងដោយស្ថាបត្យករដ៏ល្បីល្បាញកម្រិតពិភពលោក លោកស្រី ហ្សាហា ហាឌីដ សម្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា។ តាមរយៈការឆ្លុះបញ្ចាំងពីគំនិតផ្តួចផ្តើមនៃការព្យាបាលផ្លូវចិត្តតាមរយៈស្ថាបត្យកម្មរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា អគារស៊ុមឈើទាំងប្រាំនៃព្រះរាជបណ្ណាល័យ ហ្វូងម៉ែ ត្រូវបានរចនាឡើង ដើម្បីបង្ហាញការគោរពយ៉ាងជ្រាលជ្រៅចំពោះប្រាសាទអង្គរវត្ត និងមានតួនាទីជា៖

- **ស្តូបអនុស្សាវរីយ៍រំឭក៖** ដើម្បីថ្វាយព្រះរាជកិត្តិយសដល់សម្តេចម៉ែ ព្រះរាជវង្សានុវង្ស និងផ្តល់កិត្តិយសដល់ជនរងគ្រោះទាំងអស់ក្នុងរបបខ្មែរក្រហម។
- **មជ្ឈមណ្ឌលសកលលោក៖** ដើម្បីបម្រើដល់ការស្រាវជ្រាវ និងការសិក្សាអំពីអំពើប្រល័យពូជសាសន៍ និងអំពើឃោរឃៅក្នុងកម្រិតធំ។
- **បណ្ណសារឌីជីថល៖** ដើម្បីរក្សាទុកនូវរាល់កំណត់ត្រានានាស្តីពីរបបខ្មែរក្រហម។

ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ នឹងបន្តនូវមរតកស្ថាបត្យកម្មនៃអាកាសយានដ្ឋានពោធិ៍ចិនតុង គិតចាប់តាំងពីសម័យស្ថាបត្យកម្មខ្មែរបែបដែនថ្មី រហូតមកដល់បច្ចុប្បន្ន។ ទម្រង់ស្ថាបត្យកម្ម និងសម្ភារសំណង់ ត្រូវបានរចនាឡើងដោយបញ្ចូលនូវប្រព័ន្ធទប់ទល់កម្តៅ ការការពារកម្តៅថ្ងៃ ការប្រមូលថាមពលពន្លឺព្រះអាទិត្យ និងការប្រមូលទឹកភ្លៀង ដែលធាតុទាំងអស់នេះ ត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធអេកូឡូស៊ីនៃទីតាំងទាំងមូលយ៉ាងរលូន។ អគារនីមួយៗបំពេញមុខងារខុសៗគ្នា តែរួមគ្នាជាធ្លុងមួយក្នុងការភ្ជាប់ទំនាក់ទំនងរវាងផ្នែកផ្សេងៗ និងមនុស្សជាតិ។ រចនាសម្ព័ន្ធជាស៊ុមឈើទាំងនេះមានឫសគល់ពីដី លូតលាស់ទៅជាទម្រង់មុខកាត់អគារ និងចាក់ស្រេះចូលទៅក្នុងផ្ទៃនៃជាន់នីមួយៗ បង្កើតបានជាអង្គភាពរួមគ្នាតែមួយយ៉ាងល្អឯក។ ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ គឺជាស្ថាបត្យកម្មសំយោគចេញពីអត្តន័យនៃស្លឹកទ្រាំង ដែលធ្លាប់ប្រើសម្រាប់ចារសិលាចារឹកខ្មែរបុរាណ ដែលត្រូវបានស្គាល់ថាជា «ស្លឹករឹត»។ ក្នុងនាមជាស្នាដៃរចនាចុងក្រោយបង្អស់មួយរបស់លោកស្រី ហ្សាហា ហាឌីដ និងជារចនាសម្ព័ន្ធអគារដែលមានស៊ុមឈើដំបូងគេបង្អស់មួយរបស់ក្រុមហ៊ុននេះ វិទ្យាស្ថាន-សារមន្ទីរនេះ នឹងឈរជាគូឆ្លើយឆ្លងផ្តោះផ្តង ជាមួយនឹងអាកាសយានដ្ឋានអន្តរជាតិតេជោ ដែលរចនាឡើងដោយលោក ណរម៉ែន ហ្វូសស្ទើ ដែលបង្កើតបានជាអគារស្ថាបត្យកម្ម ជាគោលដៅទេសចរណ៍ថ្មីមួយសម្រាប់ប្រទេសកម្ពុជា។

តាមរយៈការផ្តល់ថាមពលថ្មីដល់កេរដំណែលនៃពោធិ៍ចិនតុង «ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ» ដែលជាវិទ្យាស្ថាន-សារមន្ទីរ នឹងក្លាយជាកម្លាំងចលករ រុញច្រានឆ្ពោះទៅកាន់អនាគតតាមរយៈការស្រាវជ្រាវយ៉ាងសកម្ម ការសិក្សារៀនសូត្រ និងការចូលរួមពីសហគមន៍។ ទន្ទឹមនឹងនេះ ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ ក៏ជាឃ្លាំងតម្កល់នូវការចងចាំដើម្បីផ្តល់កិត្តិយសដល់អតីតកាល និងបុព្វបុរស ក៏ដូចជាទីធ្លាមួយសម្រាប់ការព្យាបាលរបួសផ្លូវចិត្តថែមទៀតផង។

**អ៊ាន បញ្ញាឫទ្ធិ** គឺជាអ្នករចនាពហុជំនាញ ដែលធ្វើការលើវិស័យស្ថាបត្យកម្ម ការរចនាបែបទស្សនីយភាព និងប្រព័ន្ធផ្សព្វផ្សាយឌីជីថល។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកស្ថាបត្យកម្ម ពីសាលារចនាជាន់ខ្ពស់នៃសាកលវិទ្យាល័យ ហាវើដ។



ព្រលានយន្តហោះអន្តរជាតិពោធិ៍ចិនតុង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# គណៈស្ថាបត្យករកម្ពុជា បានដឹកនាំប្រតិភូទស្សនកិច្ច «ព្រះរាជបណ្ណាល័យហ្វូងម៉ែ» ដើម្បីសិក្សាអំពីការគ្រប់គ្រងឯកសារ ការចែករំលែកចំណេះដឹង និងគោលបំណងនៃការសាងសង់បណ្ណាល័យ ជាកេរដំណែលប្រវត្តិសាស្ត្រសម្រាប់មនុស្សជំនាន់ក្រោយ

**សោម ប៊ុនថន**



គណៈស្ថាបត្យករកម្ពុជា បានដឹកនាំប្រតិភូទស្សនកិច្ច «ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ» ដើម្បីសិក្សាអំពីការគ្រប់គ្រងឯកសារ ការចែករំលែកចំណេះដឹង និងគោលបំណងនៃការសាងសង់បណ្ណាល័យ ជាកេរដំណែលប្រវត្តិសាស្ត្រសម្រាប់មនុស្សជំនាន់ក្រោយៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឯកឧត្តម ហង្ស សុតសំភារ រដ្ឋលេខាធិការ និងជាអគ្គលេខាធិការនៃគណៈស្ថាបត្យករកម្ពុជា កាលពីរសៀល ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៦ បានដឹកនាំប្រតិភូទៅទស្សនកិច្ច និងពិភាក្សាការងារ ជាមួយឯកឧត្តម ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងស្ថាបនិកព្រះរាជបណ្ណាល័យ ហ្វូងម៉ែ និងជាឯកអគ្គរាជទូតអមព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ នៅ «ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ» ដែលបានបើកសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ក្រោមដំណើរយាងជាព្រះអធិបតីភាពដ៏ខ្ពង់ខ្ពស់ពី សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត កាលពីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ កន្លងមកៗ

### ដំណើរទស្សនកិច្ចនេះបានផ្ដោតលើ៖

១) ការស្វែងយល់អំពីការរៀបចំបណ្ណាល័យ ហួងម៉ែ ការទុកដាក់ ថែរក្សា គ្រប់គ្រងឯកសារ និងការចែករំលែកចំណេះដឹងទូទៅ ទាំងប្រវត្តិសាស្ត្រ សង្គម វប្បធម៌ និងសម្រាប់ការសិក្សាស្រាវជ្រាវជាសាធារណៈ និងសកល។

២) ការស្វែងយល់អំពីវត្ថុបំណង និងគោលដៅនៃគម្រោងសាងសង់ «ព្រះរាជបណ្ណាល័យ ហួងម៉ែ» ដែលជាសំណង់អគារនិម្មាបនកម្មខ្មែរស៊ីវិល័យទំនើប នាសហសម័យកម្ពុជា ដើម្បីទុកជាប្រវត្តិ-សាស្ត្រនិងកេរដំណែលដល់មនុស្សជំនាន់ក្រោយ។

ដំណើរទស្សនកិច្ចនេះក៏មានការអញ្ជើញចូលរួមពី ឯកឧត្តម អៀង អូនទី អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាស្ថាបត្យករអាស៊ាន, លោកជំទាវ នន់ ភានី ទីប្រឹក្សា, ឯកឧត្តម ជា ច័ន្ទថៃប៉ាស, ឯកឧត្តម សេង សោត, ឯកឧត្តម ទូស សាភឿន, ឯកឧត្តម គង់ កុសល អគ្គលេខាធិការរងគណៈស្ថាបត្យករកម្ពុជា, ឯកឧត្តម កែវវ៉ូហៀ អគ្គនាយករងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់, តំណាងសហភាពសហព័ន្ធយុវជនកម្ពុជា វិស័យដីធ្លីនគរូបនីយកម្ម និងសំណង់, ស្ថាបត្យករអាស៊ាន, សមាគមស្ថាបត្យករខ្មែរ, សមាគមអ្នកវិនិយោគអ្នកសាងសង់និងស្ថាបត្យករ កម្ពុជា, សមាគមអតីតនិស្សិតខ្មែរ ផ្នែកវិស្វកម្មនិងស្ថាបត្យកម្មពីប្រទេសចិន និងមន្ត្រីនៃគណៈស្ថាបត្យករកម្ពុជា។









គណៈស្ថាបត្យករកម្ពុជា បានដឹកនាំប្រតិភូទស្សនកិច្ច «ព្រះរាជបណ្ណាល័យ ហួងម៉ែ» ដើម្បីសិក្សាអំពីការគ្រប់គ្រងឯកសារ ការចែករំលែកចំណេះដឹង និងគោលបំណងនៃការសាងសង់បណ្ណាល័យ ជាកេរដំណែលប្រវត្តិសាស្ត្រសម្រាប់មនុស្សជំនាន់ក្រោយ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប្រវត្តិសាស្ត្រខ្មែរក្រហម និងសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

*សូ ហ្វារីណា*



បួន រុំ អាយុ៤៩ឆ្នាំ គឺជាជនពិការ នៅឃុំអបួនលើ ស្រុកកោះញែក ខេត្តមណ្ឌលគិរី។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



វណ្ណៈ បញ្ញា អាយុ១០ឆ្នាំ គឺជាកុមារពិការ នៅឃុំអបួនលើ ស្រុកកោះញែក ខេត្តមណ្ឌលគិរី។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៦ លោក ហាន សុខន មេឃុំអបួនលើ បានស្នើសុំរទេះរុញសម្រាប់ជនពិការចំនួន៣គ្រឿង ពីមជ្ឈមណ្ឌលឯកសារកម្ពុជា ជូនដល់ជនពិការនៅក្នុងឃុំអបួនលើ។ នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៦ មជ្ឈមណ្ឌលឯកសារកម្ពុជា និងព្រះរាជបណ្ណាល័យ ហ្វូងម៉ែ តាមរយៈមជ្ឈមណ្ឌលចងចាំជនជាតិដើមភាគតិច ខេត្តមណ្ឌលគិរី បានធ្វើការដឹកជញ្ជូន និងប្រគល់រទេះរុញដល់លោកមេឃុំ ដើម្បីធ្វើការចែកជូនដល់ជនពិការចំនួន៣រូប តាមការស្នើសុំ មានដូចជា៖

១) ទួន ចក់ ភេទប្រុស អាយុ៧៨ឆ្នាំ
២) បួន រុំ ភេទប្រុស អាយុ៤៩
៣) វណ្ណៈ បញ្ញា ភេទប្រុស អាយុ១០ឆ្នាំ

លោកអ៊ំ ទួន ចក់ បានមានប្រសាសន៍ថា «ខ្ញុំសប្បាយចិត្តនិងរំភើបនៅពេលទទួលបានរទេះរុញដែលផ្តល់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងព្រះរាជបណ្ណាល័យហ្វូងម៉ែ តាមរយៈមជ្ឈមណ្ឌលចងចាំជនជាតិដើមភាគតិច ខេត្តមណ្ឌលគិរី។ ខ្ញុំដេកតែនៅលើកន្ទេលមួយកន្លែងជិត២ឆ្នាំមកហើយ។ នៅពេលបានជិះលើរទេះ ខ្ញុំអាចចេញទៅខាងក្រៅ និងអាច

មើលឃើញធម្មជាតិស្រស់បំព្រង។ម្យ៉ាងទៀតរទេះរុញនេះអាចកាត់បន្ថយការលំបាកដល់ប្រពន្ធ និងកូនរបស់ខ្ញុំ ដោយមិនសូវចំណាយពេលរបស់គាត់មកថែទាំខ្ញុំ។ ខ្ញុំអាចរុញរទេះបានដោយខ្លួនឯងនៅពេលចង់ទៅណាមកណា»។

ចាប់តាំងពីឆ្នាំ២០២១ រទេះរុញចំនួន១៥គ្រឿងត្រូវបានប្រគល់ជូនដល់ឃុំអបួនលើ ដើម្បីចែកជូនដល់ជនពិការដោយសារសង្គ្រាម។ លើសពីនេះការពិនិត្យសុខភាពនិងការអប់រំពីសុខភាពត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី១១ ដល់ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៤ សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន ២០០នាក់ នៅឃុំអបួនលើ ស្រុកកោះញែក ដោយមានការសហការពីក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យខេត្តត្បូងឃ្មុំ និងអ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារកម្ពុជា។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលបានចែករំលែកសាច់រឿងនៅក្នុងរបបខ្មែរក្រហមជាមួយអ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅចន្លោះឆ្នាំ២០២១និងឆ្នាំ២០២៤ ត្រូវបានជ្រើសរើសឱ្យមកទទួលការពិនិត្យសុខភាពដោយឥតគិតថ្លៃ និងបន្ទាប់មកគឺទទួលបានការអប់រំអំពីការថែទាំសុខភាពជាប្រចាំថ្ងៃ។ ការងារនេះស្ថិតក្រោមគម្រោង«ការលើកកម្ពស់សិទ្ធិនិងការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

## ទំនាក់ទំនងរវាងប្រវត្តិសាស្ត្រ និងសុខភាព

ស្រុកកោះញែកមានចម្ងាយប្រមាណ១០០គីឡូម៉ែត្រពីទីរួមខេត្តមណ្ឌលគិរី។ ថ្វីបើស្ថិតនៅតំបន់ដាច់ស្រយាល ស្រុកកោះញែកសម្បូរដីមានជីវជាតិដែលអំណោយផលដល់ដំណាំកសិកម្ម ដូចជា ស្រូវ និងកាហ្វេ។ នៅអំឡុងឆ្នាំ១៩៦០តំបន់នេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរឥស្សរៈ ហើយបន្ទាប់មកត្រូវបានខ្មែរក្រហមគ្រប់គ្រងទាំងស្រុង បន្ទាប់ពីរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ ជនជាតិដើមភាគតិចជាច្រើនរស់នៅទីនេះតាំងពីបុរាណមក។ ក្រោយមកមានជនជាតិខ្មែរ ដែលត្រូវបានបញ្ជូនឱ្យទៅធ្វើការ និងតាំងទីលំនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៦០។ ជនជាតិដើមភាគតិចត្រូវបានខ្មែរក្រហមចាត់ទុកថាជាមនុស្សមានភាពស្មោះត្រង់ និងមិនត្រូវបានប្រឡាក់ប្រឡូសដោយវណ្ណៈមូលធននិយម បុចក្រពត្តិនិយមឡើយ។ ជនជាតិដើមភាគតិចជាច្រើនបានចូលរួមបម្រើខ្មែរក្រហម និងមានតួនាទីក្នុងការដឹកនាំ។

ស្រុកកោះញែកគឺជាទីប្រជុំជនតំបន់១០៥ និងជាជង្រុកស្រូវដ៏ធំសម្រាប់ផ្គត់ផ្គង់កងទ័ពខ្មែរក្រហម។ ណៃ សារ៉ាន់ ហៅ យ៉ា ត្រូវបានជ្រើសតាំងជាលេខាភូមិភាគឦសាន។

នៅពេលខ្មែរក្រហមគ្រប់គ្រងប្រទេសកម្ពុជាទាំងស្រុងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជនដែលរស់នៅស្រុកអូររាំង ស្រុកកែវសីមា ស្រុកសែនមនោរម្យ (បច្ចុប្បន្នក្រុងសែនមនោរម្យ) ត្រូវបានជម្លៀសទៅស្រុកកោះញែក ដើម្បីធ្វើស្រែចម្ការ។ ខ្មែរក្រហមយល់ថា ការផលិតស្រូវអាចទទួលបានទិន្នផលខ្ពស់ និងដើម្បីងាយស្រួលគ្រប់គ្រងប្រជាជន។

ប្រជាជនត្រូវបានចាត់តាំងឱ្យលើកទំនប់ និងជីកប្រឡាយ និងធ្វើស្រែនៅឃុំស្រែហ៊ុយ និងឃុំផ្សេងទៀតនៅក្នុងស្រុកកោះញែក។ សត្វពាហនៈ និងរបស់របររបស់អ្នកដែលត្រូវបានជម្លៀស រួមមានសត្វដំរីត្រូវបានប្រមូលដាក់រួម និងប្រើប្រាស់សម្រាប់បម្រើឱ្យអង្គការបដិវត្តន៍។

នៅឆ្នាំ១៩៧៦ បន្ទាប់ពីការប៉ះទង្គិចគ្នារវាងកងទ័ពខ្មែរក្រហម និងប្រទេសវៀតណាមដោយសារជម្លោះព្រំដែន ខ្មែរក្រហមបានដាក់ការសង្ស័យលើជនជាតិដើមភាគតិច និងកម្មាភិបាលរបស់ខ្លួនមួយចំនួនថាជារនុកក្នុង ហើយធ្វើការចាប់ខ្លួននិងសម្លាប់អស់ជាច្រើននាក់។ នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៧៦

យ៉ា ដែលជាលេខាភូមិភាគឦសានត្រូវបានអង្គការចាប់ខ្លួន និងបញ្ជូនមកកាន់មន្ទីរស-២១ (គុកទួលស្លែង)។ បន្ទាប់ពីការសួរចម្លើយ ធ្វើទារុណកម្ម និងឆ្លើយសារភាពរួចមក យ៉ា ត្រូវបានអង្គការសម្លាប់នៅឆ្នាំ១៩៧៧។ យោងតាមការស្រាវជ្រាវរបស់អ្នកស្រី សារ៉ា ខូម និងលោក សឹម សុរិយា ទៅលើការបន្សុទ្ធកម្មរបស់ខ្មែរក្រហមនៅក្នុងតំបន់១០៥ ខ្មែរក្រហមចោទប្រកាន់ជនជាតិដើមភាគតិចដែលខ្លួនធ្លាប់ជឿជាក់ថាស្មោះត្រង់នឹងអង្គការបដិវត្តន៍ បានក្បត់នឹងអង្គការ ហើយបានចាប់ខ្លួននិងសម្លាប់ជាបន្តបន្ទាប់។

នៅឆ្នាំ១៩៨០ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ប្រជាជនមួយចំនួនបានធ្វើដំណើរវិលត្រឡប់មកភូមិឋានវិញ។ នៅឆ្នាំ១៩៨៣ ទីតាំងរដ្ឋបាលខេត្តត្រូវបានរៀបចំ និងផ្លាស់ទីពីស្រុកកោះញែកមកក្រុងសែនមនោរម្យវិញ។

ទំនាក់ទំនងរវាងប្រវត្តិសាស្ត្រនិងសុខភាព គឺជាចំណុចដែលត្រូវយកចិត្តទុកដាក់ និងដោះស្រាយ។ សុខភាពសាធារណៈ គឺជាកិច្ចការសំខាន់ និងជាកិច្ចខិតខំប្រឹងប្រែងដែលនៅតែបន្តតាមលទ្ធភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីធានាថាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានអាយុចាប់ពី៥៥ឆ្នាំឡើង និងមានចំនួនប្រហែល៥លាននាក់ ក្នុងចំណោមប្រជាជនកម្ពុជាសរុប មានឱកាសចែករំលែកសាច់រឿងដែលចងចាំពីរបបខ្មែរក្រហម និងទទួលបានការយកចិត្តដាក់ផ្នែកសុខភាព។ តាមរយៈការសិក្សាស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៣ម៉ឺន២ពាន់នាក់ បានបង្ហាញថា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ប្រឈមនឹងជំងឺ១០យ៉ាង (ជំងឺលើសឈាម ជំងឺក្រពះពោះវៀន ជំងឺគ្រុនចាញ់ ជំងឺផ្លូវចិត្ត ជំងឺបេះដូង ជំងឺរលាកសន្លាក់ ជំងឺហឺតរ៉ាំរ៉ៃ ជំងឺទឹកនោមផ្អែម ជំងឺរបេង និងជំងឺឆ្អូតជ្រូក) ហើយកំពុងយាយីអាយុជីវិតរបស់គាត់។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមភាគច្រើនបានលើកឡើងអំពីការឈឺចាប់កម្លាំង និងភាពតក់ស្លុតផ្នែកស្មារតីនិងផ្លូវចិត្តក្នុងអំឡុងរបបខ្មែរក្រហម និងក្រោយរបបខ្មែរក្រហម ដែលជាមូលហេតុចម្បងនៃបញ្ហាសុខភាពដែលគាត់កំពុងប្រឈមក្នុងបច្ចុប្បន្ន។



សាលាឃុំអបួនលើ ក្នុងស្រុកកោះញែក ខេត្តមណ្ឌលគិរី។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


ទួន ចក់ អាយុ៧៨ឆ្នាំ គឺជាជនពិការ នៅឃុំអរបួនលើ ស្រុកកោះញែក ខេត្តមណ្ឌលគិរី។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ពិធីបុណ្យកម្សាន្តភូមិរបស់ជនជាតិដើមភាគតិចស្ទៀងនៅភូមិក្តុលលើ

ឈុំ រ៉ា




ជនជាតិដើមភាគតិចស្ទៀងនៅភូមិក្តុលលើរៀបចំពិធីបុណ្យកម្សាន្តភូមិចំនួន៣ថ្ងៃ គឺចាប់ពីថ្ងៃទី៣០ ខែមេសា រហូតដល់ថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៦ នៅផ្ទះសហគមន៍ក្តុលលើ ស្ថិតនៅភូមិក្តុលលើ ឃុំទន្ទូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពិធីបុណ្យកម្សាន្តភូមិ ឬ ចូលឆ្នាំភូមិរបស់ជនជាតិដើមភាគតិចស្ទៀងនៅភូមិក្តុលលើត្រូវបានប្រារព្ធធ្វើឡើងចំនួន៣ថ្ងៃ គឺចាប់ពីថ្ងៃទី៣០ ខែមេសា រហូតដល់ថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៦ នៅផ្ទះសហគមន៍ក្តុលលើ- សាលាគរុភណ្ឌស្ទៀង នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ស្ថិតនៅភូមិក្តុលលើ ឃុំទន្ទូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

ជនជាតិដើមភាគតិចស្ទៀងតែងតែធ្វើពិធី«បុណ្យកម្សាន្តភូមិ ឬចូលឆ្នាំភូមិ» ក្នុងរយៈពេល៣ យប់៣ថ្ងៃ បន្ទាប់ពីពិធីបុណ្យចូលឆ្នាំខ្មែរត្រូវបានបញ្ចប់។ ទោះជាយ៉ាងណា «បុណ្យកម្សាន្តភូមិ ឬចូលឆ្នាំភូមិ» របស់ជនជាតិដើមភាគតិចស្ទៀងអាចមានការប្រែប្រួលខ្លះៗ ទៅតាមការសម្រេចរបស់ចាស់ទុំ និងអាជ្ញាធរក្នុងភូមិនីមួយៗ។

នៅក្នុងឆ្នាំ២០២៦នេះ គណៈកម្មការ និងអាជ្ញាធរភូមិក្តុលលើ ឃុំទន្ទូង ស្រុកមេមត់ សម្រេចរៀបចំកម្មវិធីបុណ្យកម្សាន្តភូមិ ឬចូលឆ្នាំភូមិចំនួនបីថ្ងៃ។ មុនពេលថ្ងៃបុណ្យកម្សាន្តភូមិ ឬចូលឆ្នាំភូមិ មកដល់ យើងសង្កេតឃើញ ប្រជាជនដែលជាជនជាតិដើមភាគតិចស្ទៀងក្នុងភូមិក្តុលលើគ្រប់ផ្ទះ មានការមមាញឹកបោសសម្អាត រៀបចំតុបតែងភូមិឋាន ផ្ទះសម្បែងឱ្យមានសោភ័ណភាព និងទិញសម្លៀកបំពាក់ថ្មីៗសម្រាប់

សមាជិកក្នុងក្រុមគ្រួសារ។ ចំពោះយុវជន យុវនារី ជនជាតិដើមភាគតិចស្ទៀងបាននាំគ្នាដើរបេះផ្លែឈើ ដូចជាផ្លែទុរេន គ្រោត ខ្នុរ ដូង ចេក ម្នាស់ ស្វាយ ល្ហុង និងផ្កាភ្ញី ដើម្បីយកមកតុបតែងនៅផ្ទះសហគមន៍ក្តុលលើ- សាលាគុរុកណ្ឌស្ទៀង។

កម្មវិធីបុណ្យកម្សាន្តភូមិ ឬចូលឆ្នាំភូមិជនជាតិដើមភាគតិចស្ទៀងនៅភូមិក្តុលលើចំនួន ៣ថ្ងៃមានដូចខាងក្រោម៖

**ថ្ងៃទី១៖**

ពិធីឡើងអ្នកតារបស់ជនជាតិដើមភាគតិចស្ទៀង គឺជាជំនឿប្រពៃណីដ៏សំខាន់មួយ ដែលអ្នកភូមិតែងតែប្រារព្ធធ្វើឡើងជាហូរហែតាំងពីយូរលង់ណាស់មកហើយ ដើម្បីបន់ស្រន់សុំសេចក្តីសុខ និងភោគផលកសិកម្ម។ តាមទំនៀមទម្លាប់ ពិធីនេះមានលក្ខណៈពិសេសដូចខាងក្រោម៖

**-វត្ថុតំណាងអ្នកតា**

ជនជាតិដើមភាគតិចស្ទៀងមានជំនឿលើវត្ថុស័ក្តិសិទ្ធិ និងអាទិទេពដែលថែរក្សាភូមិករ។ ក្នុងពិធីនេះ អ្នកភូមិយកថ្មចំនួនពីរដុំមកគូរជារូបមាត់ ភ្នែក និងច្រមុះ រួចដាក់នៅលើខ្ទមអ្នកតា ដើម្បីជាតំណាងឱ្យអ្នកមានឫទ្ធិអំណាច ឬបារមីដែលថែរក្សាទឹកដី ព្រៃភ្នំ និងសហគមន៍។

**-គ្រឿងសំណែន**

អ្នកភូមិមកជួបជុំគ្នារៀបចំគ្រឿងតង្វាយដាក់ក្នុងខ្ទមអ្នកតា រួមមានគ្រឿងបរិភោគ ដូចជា ក្បាលជ្រូកស្ងោរ, មាន់ស្ងោរ, បាយស, បាយក្រហម, នំចំណី និងអន្សម។ ភេសជ្ជៈ មានទឹកត្រឡាច ស្រាស និងស្រាថ្នាំ ជាដើម។ ការបន់ស្រន់ គឺអ្នកភូមិអញ្ជើញអារក្សអ្នកតាឱ្យមកទទួលតង្វាយ និងបន់ស្រន់សុំសេចក្តីសុខសប្បាយ ព្រមទាំងសុំទឹកភ្លៀងសម្រាប់ការបង្កបង្កើនផល។

**-អត្ថន័យនៃពិធីឡើងអ្នកតា**

ក្រៅពីសុំសេចក្តីសុខ ពិធីឡើងអ្នកតានេះគឺជាឱកាសសម្រាប់បងប្អូនជនជាតិដើមភាគតិចស្ទៀងក្នុងភូមិក្តុលលើ ឃុំទន្ទូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ មកជួបជុំគ្នា បង្កើនសាមគ្គីភាព និងបង្ហាញពីការដឹងគុណចំពោះធម្មជាតិ និងបុព្វបុរសដែលបានថែរក្សាពួកគេ។

**ថ្ងៃទី២៖**

អ្នកភូមិបានយកចង្ហាន់ និងបច្ច័យមកប្រគេនព្រះសង្ឃ ដើម្បីឧទ្ទិសកុសលដល់បុព្វការីជនដែលបានចែកឋានទៅ។ បន្ទាប់មកមានការពូនភ្នំខ្សាច់ដើម្បីសន្សំកុសល និងលាងជម្រះបាប។

**ថ្ងៃទី៣៖**

នៅថ្ងៃចុងក្រោយអ្នកភូមិតែងធ្វើពិធីស្រង់ព្រះដោយការស្រោចទឹកអប់លើព្រះពុទ្ធរូប ព្រះសង្ឃ ឪពុកម្តាយ និងចាស់ទុំ ដើម្បីសុំពរជ័យ និងសុំខមាទោសចំពោះកំហុសឆ្គងផ្សេងៗ។

នៅក្នុងពិធីបុណ្យកម្សាន្តភូមិ ឬចូលឆ្នាំភូមិនេះ អ្នកភូមិ ជាពិសេសយុវជន យុវនារី ក្នុងភូមិតែងតែជួបជុំគ្នាលេងល្បែងប្រជាប្រិយជាច្រើន ដូចជា បោះអង្គុញ ចោលឈូង ទាញព្រ័ត្រ លាក់កន្សែង និងការរាំលេងកម្សាន្តតាមចង្វាក់រាំវង់ រាំក្បាច់ សារ៉ាវ៉ាន់ ជាដើម។

**ចំណាប់អារម្មណ៍**

**រឹក អ៊ាង** ភេទប្រុស អាយុ៥៨ឆ្នាំ បច្ចុប្បន្នរស់នៅភូមិក្តុលលើ ឃុំទន្ទូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ មានប្រសាសន៍ថា ខ្ញុំបានចូលរួមកម្មវិធីបុណ្យកម្សាន្តភូមិ ឬចូលឆ្នាំភូមិជារៀងរាល់ឆ្នាំ ហើយឆ្នាំនេះខ្ញុំឃើញប្រជាជនក្នុងភូមិសប្បាយរីករាយ បង្ហាញពីសាមគ្គីភាព និងបង្កើតភាពស្និទ្ធស្នាល។ ពិធីបុណ្យភូមិនេះបានជួយថែរក្សា ការពារប្រពៃណី និងទំនៀមទម្លាប់របស់ជនជាតិភាគតិចស្ទៀង។ រឹក អ៊ាង បានរំឭកថា បងប្អូនជនជាតិដើមភាគតិចស្ទៀងមិនបានរៀបចំធ្វើពិធីបុណ្យភូមិអស់រយៈពេលជាច្រើនឆ្នាំនៅក្នុងរបបខ្មែរក្រហម។ រហូតដល់របបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ បងប្អូនជនជាតិដើមភាគតិច

ស្មៀងបានត្រឡប់មកជួបជុំក្រុមគ្រួសារវិញ និងបាននាំគ្នាប្រារព្ធធ្វើបុណ្យកម្សាន្តភូមិឡើងវិញ។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំនៅវ័យកុមារ ត្រូវរៀនពេលព្រឹក ហើយពេលរសៀលទៅឃ្វាលគោ ក្របី និងធ្វើជី។ ឈ្មោះ ប៊ិន គឺជាប្រធានសហករណ៍ក្នុងភូមិបានចាត់តាំងកងឈ្លបឱ្យដើរស៊ើបតាមផ្ទះប្រជាជនក្រែងលោមានអ្នកលួចដាំបាយហូបដើម្បីចាប់មកណែនាំ ប៉ុន្តែនៅក្នុងភូមិគ្មានប្រជាជនណាហ៊ានធ្វើខុសវិន័យអង្គការឡើយ។ កន្លះខែក្រោយមក ខ្មែរក្រហមជម្លៀសខ្ញុំចេញពីភូមិក្តុលលើឱ្យទៅស្នាក់នៅភូមិស្រែតាពេជ្រ ឃុំដាំតាម៉ៅ ស្រុកមេមត់។ ខ្ញុំស្នាក់នៅទីនោះរយៈពេលប្រាំថ្ងៃ ទើបខ្មែរក្រហមជម្លៀសខ្ញុំបន្តទៅភូមិកូនក្រពើ ឃុំដាំតាម៉ៅ ហើយបន្ទាប់មកទៅឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ។ ខ្ញុំមិនមានអាហារហូបគ្រប់គ្រាន់ទេ និងត្រូវធ្វើការងារពលកម្មធ្ងន់ធ្ងរ។ ខ្មែរក្រហមចែករបបបបរតែមួយកាតែប៉ុណ្ណោះក្នុងមួយគ្រួសារ។ ប្រជាជនជម្លៀសស្លាប់ច្រើនណាស់ដោយសារអត់អាហារ និងជំងឺ។ ពេលប្រជាជនឈឺថ្កាត់ម្តងៗមិនមានថ្នាំព្យាបាលទេ គឺម្នាក់ៗដេករង់ចាំតែថ្ងៃស្លាប់។ មិត្តភក្តិរបស់ខ្ញុំឈ្មោះ ខាត់ ត្រូវបានខ្មែរក្រហមវាយធ្វើទារុណកម្មក្នុងចំណោមអង្គប្រជុំ ដោយចោទថា មានបំណងរត់ទៅប្រទេសវៀតណាម។ ការពិត ខាត់ មិនបានរត់ទៅវៀតណាមទេ។ មិនយូរប៉ុន្មាន ខ្មែរក្រហមជម្លៀសខ្ញុំពីខេត្តក្រចេះ ទៅខេត្តកំពង់ចាម។ ក្រោយរបបខ្មែរក្រហមដួលរលំ ខ្ញុំជិះស្រឡាងមកឈប់នៅទន្លេបិត រួចធ្វើដំណើរដោយថ្មើរជើងរហូតដល់ស្រុកកំណើត។ ផ្ទះសម្បែងរបស់ខ្ញុំខូចខាតទាំងស្រុង ចំណែកភូមិហ៊ុមព័ទ្ធដោយព្រៃ និងគ្រាប់មិនទាន់ផ្ទុះនៅរាយប៉ាយមិនទាន់បោសសម្អាត។ សព្វថ្ងៃខ្ញុំមានប្រពន្ធឈ្មោះ ប៉ាវ ពាល និងមានកូន៤នាក់។

**សៅ ស្រីភាព** អាយុ១៨ឆ្នាំ បានរៀបរាប់ថា ខ្ញុំពិតជាសប្បាយរីករាយដែលបានចូលរួមក្នុងពិធីបុណ្យចូលឆ្នាំភូមិ។ ខ្ញុំសង្កេតឃើញតា យាយ អ៊ំ ពូមីង បង ដឹកនាំក្មេងៗជំនាន់ក្រោយឱ្យចេះរៀបចំធ្វើបុណ្យ ដើម្បីថែរក្សាប្រពៃណីពីដូនតារបស់ជនជាតិដើមភាគតិចស្មៀង។ នៅពេលខ្ញុំដឹងក្តី ខ្ញុំឃើញតាយាយនៅក្នុងភូមិរៀបចំពិធីបុណ្យកម្សាន្តភូមិ ឬចូលឆ្នាំភូមិជារៀងរាល់ឆ្នាំបន្ទាប់ពីបុណ្យចូលឆ្នាំប្រពៃណីខ្មែរចប់។ ខ្ញុំចាប់អារម្មណ៍ជាងគេ គឺពិធីឡើងអ្នកតាដែលប្រជាជនក្នុងភូមិត្រូវតែប្រារព្ធធ្វើដោយអ្នកចូលរួមគូរមុខប្លែកៗពីគ្នា កាន់ដំបង កាំភ្លើងកែច្នៃ វាយតាមជញ្ជាំងផ្ទះអ្នកភូមិរួមទាំងវាយមាន់ទា ដើម្បីដេញព្រាយបិសាចជំងឺអាសន្នរោគ កុំឱ្យមកយាយីអ្នកភូមិ និងសុំសេចក្តីសុខសប្បាយ មានភ្លៀងគ្រប់គ្រាន់សម្រាប់ដាំដុះដំណាំ។ ខ្ញុំសប្បាយរីករាយខ្លាំងណាស់ព្រោះអ្នកភូមិទាំងក្មេងចាស់មកជួបជុំយ៉ាងច្រើនកុះករក្នុងកម្មវិធីបុណ្យកម្សាន្តភូមិ និងលេងល្បែងប្រជាប្រិយនៅផ្ទះសហគមន៍ក្តុលលើ បុសាលាគរុភណ្ឌស្មៀង នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។







ជនជាតិដើមភាគតិចស្មៀងនៅភូមិក្តុលលើរៀបចំពិធីបុណ្យកម្សាន្តភូមិចំនួន៣ថ្ងៃ គឺចាប់ពីថ្ងៃទី៣០ ខែមេសា រហូតដល់ថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៦ នៅផ្ទះសហគមន៍ក្តុលលើ ស្ថិតនៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ក្រុមនិស្សិត ដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ ចុះផលិតវីដេអូឯកសារ

## ស្ដីពីការងារស្រាវជ្រាវប្រវត្តិសាស្ត្រ នៅអគារមរតកសង្គមរាស្ត្រនិយម សម្ដេចឪ-សម្ដេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)

***ស្រេង លីជា***



*ក្រុមនិស្សិតដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ ចុះផលិតវីដេអូឯកសារស្ដីពីការងារស្រាវជ្រាវប្រវត្តិសាស្ត្រ នៅអគារមរតកសង្គមរាស្ត្រនិយម សម្ដេចឪ-សម្ដេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) ពីថ្ងៃទី៤ ដល់ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៦ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅចន្លោះពីថ្ងៃទី៤ ដល់ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៦ ក្រុមនិស្សិតនៃដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានចុះមកបំពេញបេសកកម្មសិក្សា និងផលិតវីដេអូឯកសារ នៅទីតាំងអគារមរតកសង្គមរាស្ត្រនិយម សម្ដេចឪ-សម្ដេចម៉ែ(បុរីអូរស្វាយ-សែនជ័យ) នៃមជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តស្ទឹងត្រែង។

សកម្មភាពសំខាន់ៗនៃបេសកកម្មសិក្សាគឺមានរយៈពេល៤ថ្ងៃ ដោយផ្ដោតសំខាន់លើទិដ្ឋភាពចំនួនពីរធំៗគឺការងារសង្គម និងការស្រាវជ្រាវប្រវត្តិសាស្ត្រ។ ហេតុនេះ ក្រុមនិស្សិតត្រូវចុះអនុវត្តផ្ទាល់នៅថ្ងៃនីមួយៗដូចខាងក្រោម៖

**១) ថ្ងៃទី៤ ខែឧសភា៖ ការស្វែងយល់អំពីការប្ដេជ្ញាចិត្តរបស់អ្នកស្ម័គ្រចិត្ត**

ក្រុមនិស្សិតនៃដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ បានចាប់ផ្តើមថតសកម្មភាព និងសម្ភាសន៍ជាមួយ ហ៊ លីនីត អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តស្ទឹងត្រែង។ កិច្ចសម្ភាសន៍នេះបានរំលេចឱ្យឃើញពី៖

- បទពិសោធន៍ការងារជាក់ស្តែងនៅតាមសហគមន៍។
- ការលះបង់កម្លាំងកាយចិត្តក្នុងការជួយជ្រោមជ្រែងកិច្ចការងារមនុស្សធម៌ និងការចងក្រងប្រវត្តិសាស្ត្រក្នុងតំបន់អូរស្វាយ។
- មេរៀនជីវិត និងចំណេះដឹងដែលទទួលបានពីការងារជាអ្នកស្ម័គ្រចិត្ត។

## ២) ថ្ងៃទី៥ ខែឧសភា៖ ការសិក្សាពីបច្ចេកទេសស្រាវជ្រាវ និងការគ្រប់គ្រង

ក្រុមនិស្សិតនៃដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ បានជួបសម្ភាសន៍ជាមួយ លោក ស្រេង លីដា គឺជាបុគ្គលិកនៃមជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តស្ទឹងត្រែង។ ក្នុងកិច្ចពិភាក្សានេះ លោកស្រេង លីដា បានចែករំលែកនូវចំណេះដឹងពាក់ព័ន្ធមួយចំនួនដូចខាងក្រោម៖

- **បទពិសោធន៍ស្រាវជ្រាវប្រវត្តិភូមិ៖** បច្ចេកទេសនៃការប្រមូលទិន្នន័យ និងការចងក្រងរឿងរ៉ាវប្រវត្តិសាស្ត្រនៅតាមមូលដ្ឋាន។
- ការជ្រើសរើសអ្នកស្ម័គ្រចិត្ត៖ យុទ្ធសាស្ត្រ និងលក្ខខណ្ឌវិនិច្ឆ័យក្នុងការជ្រើសរើសយុវជនដែលមានឆន្ទៈដើម្បីចូលរួមបម្រើការងារនៅទីតាំងអគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ- សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) នៃមជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តស្ទឹងត្រែង។
- **គម្រោងអភិវឌ្ឍន៍៖** ការជ្រើសរើសអ្នកស្ម័គ្រចិត្តនៅគម្រោងដាំម្នាស់ទឹកឃ្មុំ និងប្រវត្តិដំណាំម្នាស់ទឹកឃ្មុំ។

## ៣) ថ្ងៃទី៦ ខែឧសភា៖ ការសិក្សាពីជីវិតពិតអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងការគ្រប់គ្រងភូមិ

ឈានចូលមកដល់ថ្ងៃទីបីនៃបេសកកម្មសិក្សា ក្រុមនិស្សិតនៃដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ បានបន្តចុះទៅជួបផ្ទាល់ជាមួយតួអង្គសំខាន់នៅក្នុងសហគមន៍ គឺលោកមេភូមិ អ៊ុំ ម៉ារ៉ាឌី ដើម្បីស្វែងយល់ពីទិដ្ឋភាពពីរដ៏សំខាន់៖

- **ខ្សែជីវិតពិតរបស់អ្នករស់រានមានជីវិតពីសម័យសង្គ្រាម៖** តាមរយៈកិច្ចសម្ភាសន៍របស់និស្សិតបានស្តាប់នូវការរៀបរាប់ពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់លោកមេភូមិ ក្នុងនាមជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ការចែករំលែកនេះបានផ្តល់នូវរូបភាពយ៉ាងច្បាស់ពីបទពិសោធន៍នៃការតស៊ូ ការឆ្លងកាត់ទុក្ខលំបាក និងការកសាងជីវិតឡើងវិញ បន្ទាប់ពីសម័យកាលដ៏ខ្មៅងងឹត ដែលជាទិន្នន័យប្រវត្តិសាស្ត្រដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន។
- **បទពិសោធន៍នៃការគ្រប់គ្រង និងការអភិវឌ្ឍន៍ភូមិ៖** ក្រៅពីរៀបរាប់សាច់រឿងបុគ្គល លោកមេភូមិ អ៊ុំ ម៉ារ៉ាឌី បានបង្ហាញពីតួនាទីជាអ្នកដឹកនាំមូលដ្ឋាន។ លោកបានពន្យល់អំពី៖ ទី១) របៀបគ្រប់គ្រងសន្តិសុខ និងសណ្តាប់ធ្នាប់នៅក្នុងភូមិ។ ទី២) ការផ្សះផ្សា និងការកសាងសាមគ្គីភាពរវាងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងប្រជាពលរដ្ឋក្នុងសហគមន៍។ និងទី៣) បញ្ហាប្រឈម និងភាពជោគជ័យក្នុងការដឹកនាំភូមិឱ្យមានការរីកចម្រើនរហូតមកដល់បច្ចុប្បន្ន។

## ៤) ថ្ងៃទី៧ ខែឧសភា៖ ការផ្តិតយកវីដេអូនៃតំបន់រ៉ាមសារ បន្ទាប់ពីបានចំណាយពេលថតទៅលើសាច់រឿង និងប្រវត្តិសាស្ត្រ

ក្រុមនិស្សិតនៃដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍បានបញ្ចប់បេសកកម្មរបស់ខ្លួនដោយការចុះផ្តិតយកទិដ្ឋភាព តំបន់រ៉ាមសារ ដែលជាតំបន់

ដ៏សើមមានសារសំខាន់ជាអន្តរជាតិ។ សកម្មភាពសំខាន់ៗនៅថ្ងៃចុងក្រោយនេះរួមមាន៖

- **ការថតរូបភាព និងវីដេអូទេសភាព៖** ក្រុមនិស្សិតនៃដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ បានធ្វើដំណើរតាមទូក ដើម្បីថតយកសោភ័ណភាពធម្មជាតិ រួមមានព្រៃលិចទឹកដែលដុះតាមដងទន្លេមានរូបរាងប្លែកៗ និងប្រព័ន្ធជីវៈចម្រុះដ៏សម្បូរបែប។ វីដេអូទាំងនេះនឹងត្រូវប្រើប្រាស់ជាប្លង់ជំនួយដ៏សំខាន់ ដើម្បីបង្ហាញពីបរិបទភូមិសាស្ត្រ ដែលអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមកំពុងរស់នៅ។
- **ការផ្សារភ្ជាប់រវាងមនុស្ស និងធម្មជាតិ៖** ការចុះថតនៅតំបន់រ៉ាមសារនេះ មានគោលបំណងបង្ហាញពីទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងប្រជាជនក្នុងសហគមន៍ ជាមួយនឹងទន្លេមេគង្គ ដែលជាប្រភពស្បៀង និងជាផ្នែកមួយនៃប្រវត្តិនៃការតាំងទីលំនៅរបស់អ្នកភូមិតាំងពីដើមរៀងមក។

ចុងក្រោយក្រុមនិស្សិតនៃដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ បង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម ៖






ក្រុមនិស្សិតដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ ចុះផលិតវីដេអូឯកសារស្តីពីការផ្សារស្រាវជ្រាវប្រវត្តិសាស្ត្រ នៅអគាររមរតកសង្គមរាស្ត្រនិយម សម្តេចឪ- សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) ពីថ្ងៃទី៤ ដល់ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៦ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**គួង ឆេងហុង** ៖ «ក្នុងនាមជានិស្សិតឆ្នាំទី៣ នៃដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងដែលបានមកបំពេញបេសកកម្មនៅខេត្តស្ទឹងត្រែង។ ទោះបីជាខ្ញុំមកខេត្តស្ទឹងត្រែងជាលើកដំបូង ប៉ុន្តែអ្នកភូមិអូរស្វាយបានបង្ហាញភាពស្និទ្ធស្នាល រាក់ទាក់ និងផ្តល់ភាពកក់ក្តៅដល់យើង។ ខ្ញុំសង្ឃឹមថាវីដេអូដែលយើងផលិតនឹងចូលរួមចំណែកផ្សព្វផ្សាយពីសក្តានុពលទេសចរណ៍ និងប្រវត្តិសាស្ត្រនៃតំបន់ទេសចរណ៍បុរីអូរស្វាយទៅកាន់ពិភពលោក ហើយខ្ញុំសូមលើកទឹកចិត្តឱ្យមានការស្រាវជ្រាវបន្ថែមទៀតដើម្បីជាប្រយោជន៍ដល់យុវជនជំនាន់ក្រោយ»។

**រិន សុបញ្ញា** ៖ «ខ្ញុំពិតជាមានក្តីរំភើប និងដឹងគុណយ៉ាងជ្រាលជ្រៅចំពោះការស្វាគមន៍យ៉ាងកក់ក្តៅពីក្រុមការងារ មជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តស្ទឹងត្រែង និងអ្នកភូមិអូរស្វាយ ទាំងអស់។ រយៈពេល ៦ថ្ងៃដែលខ្ញុំចុះមកថតនៅទីតាំងបុរីអូរស្វាយសែនជ័យ គឺលើសពីការចុះធ្វើកិច្ចការសាលាទៅទៀត។ ខ្ញុំសង្ឃឹមថានឹងមានឱកាសត្រឡប់មកទីនេះម្តងទៀត»។

**ម៉ុន ដារ៉ាណេ** ៖ «នាងខ្ញុំមានអារម្មណ៍រំភើប និងសប្បាយរីករាយយ៉ាងខ្លាំងដែលបានចុះកម្មសិក្សានៅស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ តាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា នាងខ្ញុំបានរៀនសូត្រកាន់តែច្បាស់អំពីប្រវត្តិសាស្ត្រ និងរឿងរ៉ាវរបស់ប្រជាជនក្នុងមូលដ្ឋានដែលមានទឹកចិត្តសប្បុរស និងរាក់ទាក់យ៉ាងខ្លាំង។ នាងខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានជួយសម្របសម្រួល និងផ្តល់នូវបទពិសោធន៍សម្រាប់ខ្ញុំយកទៅប្រើប្រាស់ក្នុងអាជីពការងារទៅថ្ងៃអនាគត»។

**ណាថាណា ឌូហាណា** ៖ «ខ្ញុំទើបតែបានបញ្ចប់ការផលិតវីដេអូដ៏មានអត្ថន័យនៅស្រុកបុរីអូរស្វាយសែនជ័យ។ អ្វីដែលធ្វើឱ្យខ្ញុំចាប់អារម្មណ៍បំផុត គឺភាពស្រស់ស្រាយ និងការរាក់ទាក់របស់ប្រជាជនក្នុងសហគមន៍។

**ស្រ៊ុន វស៊ីទ្ធីច័** ៖ «ខ្ញុំមានសេចក្តីរីករាយដែលបានចុះមកសិក្សា និងស្វែងយល់អំពីរឿងរ៉ាវជីវិតពិតរបស់ប្រជាជននៅតំបន់អូរស្វាយ។ បទពិសោធន៍នៃការចុះយកព័ត៌មាន និងការចុះសម្ភាសន៍អ្នករស់រានមានជីវិតពីសម័យសង្គ្រាម បានធ្វើឱ្យខ្ញុំយល់កាន់តែច្បាស់ពីតម្លៃនៃសន្តិភាព និងការចងចាំប្រវត្តិសាស្ត្រ។ ខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានផ្តល់ឱកាសនេះដល់ខ្ញុំ»។



*ក្រុមនិស្សិត ដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ ចុះផលិតវីដេអូឯកសារស្តីពីការងារស្រាវជ្រាវប្រវត្តិសាស្ត្រ នៅអគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) ពីថ្ងៃទី៤ ដល់ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៦ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

# មជ្ឈមណ្ឌលឯកសារកម្ពុជាតាំងបង្ហាញគម្រោង និងស្នាដៃស្ថាបត្យកម្មព្រះរាជបណ្ណាល័យ ហ្លួងម៉ែនៅក្នុងពិព័រណ៍ស្ថាបត្យកម្មឆ្នាំ២០២៦

*សោម ប៊ុនថន*



មជ្ឈមណ្ឌលឯកសារកម្ពុជាតាំងបង្ហាញគម្រោង និងស្នាដៃស្ថាបត្យកម្មព្រះរាជបណ្ណាល័យ ហ្លួងម៉ែនៅក្នុងពិព័រណ៍ស្ថាបត្យកម្មឆ្នាំ២០២៦ រយៈពេលពីរថ្ងៃគឺពីថ្ងៃទី២៣ ដល់ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៦ នៅមជ្ឈមណ្ឌល Phnom Penh Factory ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពិព័រណ៍ស្ថាបត្យកម្មធំប្រចាំឆ្នាំត្រូវបានរៀបចំឡើងរយៈពេលពីរថ្ងៃគឺពីថ្ងៃទី២៣ ដល់ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៦ នៅមជ្ឈមណ្ឌល Phnom Penh Factory ក្រោមអត្ថន័យនៃភាពតូចតាច។ នៅក្នុងពិព័រណ៍នេះមានការចូលពីបណ្ដាអ្នកលក់ ដៃគូដាក់តាំងបង្ហាញដ៏សម្បូរបែបដែលត្រូវបានជ្រើសរើសយ៉ាងសម្រិតសម្រាំង ចាប់ពីសម្ភារសំណង់ និងការរចនាស្ថាបត្យកម្មល្បីៗ រហូតដល់ផលិតផលធ្វើដោយដៃ រុក្ខជាតិលម្អ និងអាហារភេសជ្ជៈ។

មជ្ឈមណ្ឌលឯកសារកម្ពុជាបានចូលរួមដាក់តាំងបង្ហាញពីគម្រោងរបស់ខ្លួនរួមមាន១) ពិព័រណ៍រុក្ខជាតិកម្រ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការសិក្សាស្រាវជ្រាវជាច្រើនឆ្នាំមកហើយ និងសង្ឃឹមថារុក្ខជាតិមួយចំនួនអាចប្រើប្រាស់ជាឱសថសម្រាប់ជួយដល់សុខភាពលក្ខណៈគ្រួសារ ចំពោះអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ មជ្ឈមណ្ឌលឯកសារ

កម្ពុជាបានបង្កើតបន្ទប់ពិសោធន៍រុក្ខជាតិមួយ ដែលសិក្សាលើរុក្ខជាតិកម្រនៅក្នុងប្រទេសកម្ពុជា និងរុក្ខជាតិជាច្រើនប្រភេទទៀតមកពីបណ្តាប្រទេសដទៃ ដើម្បីបង្កាត់ពូជ និងអាចប្រើប្រាស់ជាឱសថ។ ២) ការតាំងបង្ហាញផលិតផលសិប្បកម្មក្នុងគម្រោងសូត្រ ចាមបុព្វណ៌នៃការចងចាំ ដូចជា ផ្ទាំងក្រណាត់សូត្រ និងក្រមាសូត្រ រំលេចដោយរចនាគោមសំពត់ដ៏ស្រស់ស្អាតដែលជាស្នាដៃផលិតដោយស្ត្រីជនជាតិចាមមកពីខេត្តកំពង់ចាម។ ៣) ការតាំងបង្ហាញស្នាដៃគម្រោងស្ថាបត្យកម្មព្រះរាជបណ្ណាល័យ ហ្វូងម៉ៃ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានជ័យលាភីលេខ១ ក្នុងការប្រកួតប្រជែងស្នាដៃស្ថាបត្យកម្ម «ពោធិ៍ចិនតុងកើតឡើងវិញ ការបំប្លែងអាកាសយានដ្ឋានចាស់ភ្នំពេញឱ្យក្លាយទៅជាទីក្រុងអេប៉ុង» ដឹកនាំដោយលោក ទិត្យ សត្យាវង្ស, កញ្ញា លាង ចន្ទី, កញ្ញា លឹម វណ្ណសូលីហ្សា និងលោក វ៉ន រ័ត្នវិសាល កាលពីថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៦។

គម្រោងនេះ គឺជាគំនិតផ្តួចផ្តើមមួយដើម្បីផ្លាស់ប្តូរអតីតអាកាសយានដ្ឋានអន្តរជាតិពោធិ៍ចិនតុង ទៅជាសួនច្បារទីក្រុងអេប៉ុង។ គម្រោងនេះអនុវត្តគោលការណ៍ស្នូលនៃការរចនាទីក្រុងដែលងាយរងគ្រោះដោយជំនន់ទឹកភ្លៀង ដែលត្រូវបានគេហៅថាជាគំរូ «ទីក្រុងអេប៉ុង» ដោយអនុញ្ញាតឱ្យទេសភាពស្រូបយករក្សាទុក ត្រង និងបញ្ចេញទឹកភ្លៀងដោយធម្មជាតិ។ អតីតអាកាសយានដ្ឋាននឹងក្លាយជាផ្លូវដើរដែលអាចជ្រាបទឹកបានជាមួយនឹងច្រករបៀងបៃតងដែលទឹកភ្លៀងជ្រាបចូលតាមរយៈផ្លូវជីវសាស្ត្រ សួនច្បារទឹកភ្លៀង និងផ្លូវក្រាលកៅស៊ូ។ ផ្នែកធំនៃតំបន់អាកាសយានដ្ឋាននឹងត្រូវបានផ្លាស់ប្តូរទៅជាតំបន់សើម បឹងស្តុកទឹក និងតំបន់ទំនាបលិចទឹកដែលអាចកាត់បន្ថយទឹកភ្លៀង ខណៈពេលដែលតំបន់នេះគាំទ្រដល់ជីវចម្រុះ និងសត្វព្រៃដែរ។

ការបង្កើតឡើងវិញនៃអាកាសយានដ្ឋានពោធិ៍ចិនតុងគឺច្រើនជាងការអភិវឌ្ឍន៍ប្រព័ន្ធជលសាស្ត្រទំនើបដែលគាំទ្រដល់បរិស្ថានក្នុងស្រុក និងសហគមន៍ទីក្រុង/ជនបទ។ គម្រោងនេះគឺជាគំនិតរចនាទីក្រុងដែលផ្តោតលើប្រជាជន ដែលនឹងកំណត់ស្តង់ដារសម្រាប់គម្រោងអភិវឌ្ឍន៍នាពេលអនាគត។ គំនិតនៃតំបន់បៃតងដែលមានស្រមោលនឹងកាត់បន្ថយកម្តៅទីក្រុង ខណៈពេលដែលបើកកន្លែងសាធារណៈ កន្លែងកម្សាន្តទីលានកីឡា និងសួនច្បារវប្បធម៌សម្រាប់ការប្រើប្រាស់ជាសាធារណៈពេញមួយឆ្នាំ។ គម្រោងនេះនឹងជួយបំពេញតម្រូវការនៃការអភិវឌ្ឍន៍ទីក្រុងនាពេលអនាគតប្រកបដោយចីរភាព ជាមួយនឹងសារសំខាន់នៃភាពធន់នឹងអាកាសធាតុ ការអភិរក្សជីវៈចម្រុះ និងបេតិកភណ្ឌពិសិដ្ឋរបស់ប្រទេសកម្ពុជា។ ប្រទេសកម្ពុជាអាចកំណត់ស្តង់ដារសម្រាប់ការអភិវឌ្ឍន៍ទីក្រុងប្រកបដោយចីរភាព ដោយការផ្លាស់ប្តូរទីតាំងប្រវត្តិសាស្ត្រមួយនៅក្នុងការរចនាទីក្រុងដែលងាយរងគ្រោះដោយទឹកជំនន់ ដែលមិនត្រឹមតែគាំទ្រដល់រាជធានី និងសហគមន៍ក្នុងតំបន់តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបរិស្ថាន និងបេតិកភណ្ឌរបស់ប្រទេសសម្រាប់មនុស្សជំនាន់ក្រោយទៀតផង។ នៅក្នុងគម្រោងនេះ គឺមានរួមបញ្ចូលអគារប្រវត្តិសាស្ត្រព្រះរាជបណ្ណាល័យ ហ្វូងម៉ៃ, ទីតាំងរំឭកវិញ្ញាណក្ខន្ធវីរកងទ័ពកម្ពុជា ដែលបានពលីនៅក្នុងបុព្វហេតុការពារ



មជ្ឈមណ្ឌលឯកសារកម្ពុជាតាំងបង្ហាញគម្រោង និងស្នាដៃស្ថាបត្យកម្មព្រះរាជបណ្ណាល័យ ហ្វូងម៉ៃនៅក្នុងពិព័រណ៍ស្ថាបត្យកម្មឆ្នាំ២០២៦ រយៈពេលពីរថ្ងៃគឺពីថ្ងៃទី២៣ ដល់ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៦ នៅមជ្ឈមណ្ឌល Phnom Penh Factory ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បូរណភាពទឹកដីពីការឈ្លានពានរបស់កងទ័ពថៃ, សាលពិព័រណ៍រូបថតមេដឹកនាំពិភពលោកដែលបានធ្វើដំណើរមកដល់ព្រលានយន្តហោះពោធិ៍ចិនតុង និងមជ្ឈមណ្ឌលភស្តុភារកម្ម។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិកព្រះរាជបណ្ណាល័យ ហ្វូងម៉ែ មានប្រសាសន៍ថា ទីតាំងស្តូបរំឭកវិញ្ញាណក្ខន្ធនេះបង្កើតឡើងក្នុងគោលបំណងដើម្បីការចងចាំនូវវីរភាពដ៏ក្លាហានចំពោះការពលីជីវិតរបស់វីរកងទ័ពក្នុងការការពារទឹកដីប្រទេសកម្ពុជាជាច្រើនជំនាន់ និងជាកន្លែងសម្រាប់អ្នកជំនាន់ក្រោយបានសិក្សាស្វែងយល់ពីប្រវត្តិសាស្ត្រ និងគំរូដ៏អង់អាចរបស់វីរកងទ័ពក្នុងការការពារទឹកដីពីការឈ្លានពាន និងយាយីពីសត្រូវ។ ការរចនាកន្លែងនេះយកលំនាំតាមស្រះទឹកនៅប្រាសាទព្រះវិហារ ដោយនៅលើជញ្ជាំងថ្មម៉ាបមានឆ្លាក់ឈ្មោះវីរកងទ័ពដែលបានពលីជីវិតក្នុងសមរភូមិតាមព្រំដែនក្នុងបុព្វហេតុជាតិមាតុភូមិ។ អ្នកទស្សនាអាចមកទីកន្លែងនេះដើម្បីសម្តែងការដឹងគុណ និងគោរពវិញ្ញាណក្ខន្ធដល់វីរកងទ័ព។

កាលពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៦ កន្លងមក សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីព្រះរាជាណាចក្រកម្ពុជា ស្នើឱ្យរដ្ឋមន្ត្រីក្រសួងការពារជាតិ ទៀ សីហា និង ឯកឧត្តម នាយឧត្តមសេនីយ៍ ណឹម សុវត្ថិ អគ្គនាយក អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស ពិភាក្សាលើទីតាំងសម្រាប់ការសាងសង់ស្តូបរំឭកដល់វិញ្ញាណក្ខន្ធកងទ័ព និង នគរបាលការពារព្រំដែនដែលពលីការពារព្រំដែន។ សម្តេចមហាបវរធិបតីថ្លែងថា ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃការឈ្លានពានរបស់ថៃ នឹងត្រូវចារនៅឯវិមានឈ្នះ-ឈ្នះ ប៉ុន្តែស្តូបសម្រាប់រំឭកវិញ្ញាណក្ខន្ធនឹងត្រូវសាងសង់ដាច់ដោយឡែក ដើម្បីជាការរំឭកដល់កូនចៅជំនាន់ក្រោយជាប្រចាំ។









មជ្ឈមណ្ឌលឯកសារកម្ពុជាតាំងបង្ហាញគម្រោង និងស្នាដៃស្ថាបត្យកម្មព្រះរាជបណ្ណាល័យ ហ្វូងម៉ែនៅក្នុងពិព័រណ៍ស្ថាបត្យកម្មឆ្នាំ២០២៦ រយៈពេលពីរថ្ងៃគឺពីថ្ងៃទី២៣ ដល់ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៦ នៅមជ្ឈមណ្ឌល Phnom Penh Factory ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ទិវាជាតិនៃការចងចាំ ២០ ឧសភា ២០២៦

សោម ប៊ុនថន





អដ្ឋិធាតុរបស់ជនរងគ្រោះពីរបបខ្មែរក្រហមក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ នៅខេត្តស្វាយរៀង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មកដល់ឆ្នាំ២០២៦នេះ គឺមានរយៈពេល៤៣ឆ្នាំហើយ ចាប់តាំងពីការប្រារព្ធទិវា ២០ ឧសភា ដំបូងនៅឆ្នាំ១៩៨៣ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមប្រមាណជាង៥លាននាក់ នៅតែចងចាំអំពីការប្រព្រឹត្តអំពើសាហាវឃោរឃៅ និងការកាប់សម្លាប់របស់ខ្មែរក្រហមមកលើប្រជាជនកម្ពុជា។ អំឡុងពេលប្រជាជនកម្ពុជាកំពុងពុះពារដើម្បីរស់ និងស្តារប្រទេសកម្ពុជាឡើងវិញពីការបំផ្លិចបំផ្លាញដ៏ធំធេងរបស់ខ្មែរក្រហម ទិវា២០ឧសភា នៅតែប្រារព្ធធ្វើឡើងនៅតាមតំបន់ជាច្រើននៅប្រទេសកម្ពុជា និងមានការចូលរួមយ៉ាងច្រើនកុះករពីជនរងគ្រោះ ទោះបីជាមានការលើកឡើងមួយចំនួនថា ទិវានេះគឺជាទិន្នាការនយោបាយប្រឆាំងនឹងខ្មែរក្រហមដែលជារដ្ឋាភិបាលស្របច្បាប់ និងមានអាសនៈនៅអង្គការសហប្រជាជាតិ។ មានភស្តុតាងជាច្រើនត្រូវបានរកឃើញទាក់ទងនឹងការប្រព្រឹត្តអមនុស្សធម៌របស់ខ្មែរក្រហម ដែលបណ្តាលឱ្យប្រជាជនកម្ពុជារាប់លាននាក់ស្លាប់ រហូតបង្កើតឱ្យមានតុលាការប្រជាជនបដិវត្តន៍កម្ពុជា នៅឆ្នាំ១៩៧៩ ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមដោយកំបាំងមុខ ប៉ុន្តែតុលាការនេះត្រូវបានចោទប្រកាន់ថាលម្អៀងព្រោះមិនមានការចូលរួមពីប្រទេសលោកសេរី។ រយៈពេល២៧ឆ្នាំក្រោយមក គឺនៅឆ្នាំ២០០៦ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ត្រូវបានបង្កើតឡើងដោយមានការចូលរួមពីរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ហើយបានកាត់ទោសមេដឹកនាំខ្មែរក្រហមចំនួន៥រូប គឺ កាំង ហ្គេចអ៊ាវ ហៅ ឌុច អតីតប្រធានមន្ទីរសន្តិសុខ ស-២១ (ឬគុកទួលស្លែង) នៃ

របបកម្ពុជាប្រជាធិបតេយ្យ, ខៀវ សំផន អតីតគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ, នួន ជា អតីតប្រធានសភាតំណាងប្រជាជននៃរបបកម្ពុជាប្រជាធិបតេយ្យ, អៀង សារី អតីតឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ, អៀង ធីរិទ្ធ អតីតរដ្ឋមន្ត្រីសង្គមកិច្ចនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលក្នុងចំណោមជនជាប់ចោទទាំង៥រូប គឺមានអៀង សារី និងអៀង ធីរិទ្ធ បានស្លាប់មុនការប្រកាសសាលក្រមរបស់តុលាការ។ ទោះបីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបញ្ចប់ដំណើរការកាត់ក្តី តាំងពីឆ្នាំ២០២២ ទៅហើយក្តី នៅក្នុងខែឧសភា ឆ្នាំ២០២៦ នេះ អាជ្ញាធរកម្ពុជាបានស្រាវជ្រាវ និងធ្វើកំណាយរកឃើញអដ្ឋិធាតុជនរងគ្រោះចំនួន៨០០ រួមទាំងសម្លៀកបំពាក់ ដែលទទួលរងការកាប់សម្លាប់ពីខ្មែរក្រហម នៅអតីតគុកកោះរំដួល ហៅកោះគរ ស្ថិតនៅក្នុងសង្កាត់រកាខ្ពស់ ក្រុងតាខ្មៅ ខេត្តកណ្តាល បន្ថែមទៀត។ ដូច្នេះក្រៅពីការផ្តល់យុត្តិធម៌ដល់ជនរងគ្រោះពីរបបខ្មែរក្រហមតាមផ្លូវតុលាការ គឺការស្រាវជ្រាវ ការសិក្សាអប់រំ និងការចងចាំអំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមនៅតែមានសារសំខាន់ និងផ្តល់នូវចំណេះដឹងដល់ក្មេងៗជំនាន់ក្រោយដើម្បីទប់ស្កាត់កុំឱ្យរបបនេះកើតឡើងម្តងទៀត។ ក្នុងនោះដែរ ចាប់តាំងពីឆ្នាំ២០០៧មក មជ្ឈមណ្ឌលឯកសារកម្ពុជា បានបោះពុម្ពសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងបានចែកជូនសិស្សានុសិស្សនៅតាមវិទ្យាល័យនៅទូទាំងប្រទេសកម្ពុជា ដើម្បីសិក្សារៀនសូត្រ, បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលគ្រូបង្គោលប្រវត្តិវិទ្យា, អក្សរសាស្ត្រខ្មែរ និងគ្រូសីលធម៌ ពលរដ្ឋវិជ្ជា, បានរៀបចំវេទិកាថ្នាក់រៀន និងអប់រំជាសាធារណស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ, បានផ្សព្វផ្សាយ និងបានរៀបចំសន្និសីទជាច្រើន ដើម្បីលើកកម្ពស់ការអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាលើទូទាំងពិភពលោក។



អដ្ឋិធាតុរបស់ជនរងគ្រោះពីរបបខ្មែរក្រហមក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ នៅខេត្តស្វាយរៀង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សអនុវិទ្យាល័យត្រពាំងប្រិយ៍ទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងសារមន្ទីរផ្ទះតាម៉ុក

**មេក ទិន**







*សិស្សអនុវិទ្យាល័យត្រពាំងប្រិយ៍ទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងសារមន្ទីរផ្ទះតាម៉ុក។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានទទួលស្វាគមន៍សិស្សចំនួន៦នាក់ មកពីអនុវិទ្យាល័យត្រពាំងប្រិយ៍ ដើម្បីទស្សនាពិព័រណ៍រូបថត និងសិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម (១៩៧៥-១៩៧៩)។ ដំណើរទស្សនកិច្ចនេះ ធ្វើឡើងក្នុងគោលបំណងផ្សារភ្ជាប់រវាងសិស្សានុសិស្សទៅនឹងទិដ្ឋភាពជីវិតរបស់ប្រជាជននៅក្នុងតំបន់អន្លង់វែងតាមរយៈពិព័រណ៍រូបថតចំនួន១០០សន្លឹក ផ្តោតលើ «ការបង្ខំយុត្តិធម៌» ដែលដាក់តាំងបង្ហាញនៅសារមន្ទីរផ្ទះតាម៉ុក។

ស្រុកអន្លង់វែង មិនត្រឹមតែជាតំបន់ភូមិសាស្ត្រដែលមានសក្តានុពលទេសចរណ៍ធម្មជាតិនោះទេប៉ុន្តែវាគឺជា ទីតាំង«សាក្សីរស់»នៃប្រវត្តិសាស្ត្រចុងក្រោយរបស់ក្រុមខ្មែរក្រហម។ ការរៀបចំពិព័រណ៍រូបថតនៅសារមន្ទីរផ្ទះតាម៉ុក បានក្លាយជាស្ពានចម្លងចំណេះដឹងយ៉ាងសំខាន់សម្រាប់សិស្សានុសិស្ស និងយុវជនដើម្បីស្វែងយល់ពីបុសគល់នៃសង្គ្រាម និងតម្លៃនៃសន្តិភាព។ រូបថតនីមួយៗដែលដាក់តាំងបង្ហាញក្នុងផ្ទះតាម៉ុក មិនមែនគ្រាន់តែជាក្រដាសពណ៌សខ្មៅនោះទេ ប៉ុន្តែវាគឺជា «ភស្តុតាងដែលមិនចេះនិយាយ

កុហក»។ ជាក់ស្តែង សិស្សានុសិស្ស បានទស្សនាពិព័រណ៍ និងបានឃើញរូបភាពផ្ទាល់ភ្នែកអំពីសកម្មភាពរស់នៅប្រចាំថ្ងៃក្នុងសម័យសង្គ្រាម រូបថតរចនាសម្ព័ន្ធដឹកនាំ, បុគ្គលសំខាន់ៗនៃចលនាខ្មែរក្រហម, ទិដ្ឋភាពនៃការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងការតស៊ូរបស់ប្រជាជន។ រូបភាពទាំងនេះជួយឱ្យសិស្សានុសិស្ស ងាយយល់ជាងការអានត្រឹមតែអត្ថបទក្នុងសៀវភៅបោះពុម្ព ដែលធ្វើឱ្យប្រវត្តិសាស្ត្រក្លាយជារូបភាពរស់រវើកក្នុងការសិក្សារបស់សិស្សានុសិស្ស។

សិស្សជាច្រើនដែលរស់នៅតំបន់អន្លង់វែង គឺជាកូនចៅរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលបានឆ្លងកាត់ផ្ទាល់។ ការបង្រៀនតាមរយៈពិព័រណ៍រូបថតក្នុងសារមន្ទីរផ្ទះតាម៉ុក ជួយឱ្យសិស្សទទួលយកការពិតយល់ដឹងពីកំហុសឆ្គងក្នុងអតីតកាល ដើម្បីកុំឱ្យកើតឡើងជាថ្មី។ បន្ថែមពីនេះ ធ្វើឱ្យមានការអត់ឱន ការយល់ដឹងពីប្រវត្តិសាស្ត្រជួយកាត់បន្ថយការរើសអើង និងបង្កើនការយោគយល់គ្នានៅក្នុងសង្គម។ សិស្សានុសិស្សមានមោទនភាពចំពោះតំបន់របស់ខ្លួន ដែលបានប្រែក្លាយតំបន់ដែលធ្លាប់តែល្បីខាងសង្គ្រាម ឱ្យទៅជាតំបន់ប្រវត្តិសាស្ត្រសម្រាប់សិក្សា និងទាក់ទាញទេសចរណ៍មកកម្សាន្ត។

ការផ្សារភ្ជាប់សិស្សានុសិស្ស និងយុវជនជាមួយពិព័រណ៍រូបថតនៅសារមន្ទីរផ្ទះតាម៉ុក មិនមែនជាការរំឭកភាពឈឺចាប់ទេ ប៉ុន្តែដើម្បីផ្តល់«ការចងចាំអតីតកាល កសាងបច្ចុប្បន្ន និងតម្រង់ទិសអនាគត»។ រូបថតទាំងនោះគឺជាមេរៀនសន្តិភាពដ៏មានអំណាចបំផុតដែលជួយឱ្យយុវជនជំនាន់ក្រោយ ក្លាយជាកម្លាំងចលករក្នុងការថែរក្សាសន្តិភាព និងការអភិវឌ្ឍន៍ជាតិឱ្យបានរឹងមាំជានិរន្តរ៍។

ចុងបញ្ចប់នៃដំណើរទស្សនកិច្ច សិស្សានុសិស្សបានសម្តែងនូវការយល់ឃើញផ្សេងៗគ្នា៖

**ជុម ដាលីន** ភេទស្រី អាយុ១៧ឆ្នាំ រៀនថ្នាក់ទី៩ នៃអនុវិទ្យាល័យត្រពាំងប្រិយ៍ បានបង្ហាញចំណាប់អារម្មណ៍ថា៖ បន្ទាប់ពីខ្ញុំបានចូលរួមក្នុងដំណើរទស្សនកិច្ចសិក្សាពិព័រណ៍រូបថតចំនួន១០០សន្លឹករួចមក ខ្ញុំពិតជាបានយល់ដឹងច្រើនពីរឿងរ៉ាវប្រវត្តិសាស្ត្រដែលបានកើតមានឡើងនៅក្នុងរបបខ្មែរក្រហម។ ពិព័រណ៍រូបថតនេះ បានបង្ហាញឱ្យឃើញពីសកម្មភាពធ្វើការងាររបស់ប្រជាជននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងរូបថតប្រជាជននៅតំបន់អន្លង់វែងមួយចំនួនទៀតដែលបង្ហាញពីការធ្វើសមាហរណកម្មបញ្ចប់សង្គ្រាម រូបថតរៀបអាពាហ៍ពិពាហ៍នៅក្នុងឆ្នាំ១៩៩០។ ខ្ញុំផ្ទាល់ធ្លាប់បានទៅទស្សនានៅ«គុកទួលស្លែង» ខ្ញុំបានឃើញរូបភាព ទីកន្លែងជាច្រើនដែលបន្សល់ទុកពីរបបខ្មែរក្រហម។ ខ្ញុំគិតថាការសិក្សារៀនសូត្រពីប្រវត្តិសាស្ត្រ គឺពិតជាល្អសម្រាប់ការចងចាំ ផ្សព្វផ្សាយ និងបង្រៀនដល់យុវជនជំនាន់ក្រោយៗទៀត។

**ម៉ន សុខលី** ភេទស្រី អាយុ១៦ឆ្នាំ បានលើកឡើងថា៖ ខ្ញុំពិតជាសប្បាយចិត្តក្នុងការមកចូលរួមសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅថ្ងៃនេះ ពីព្រោះបានធ្វើឱ្យខ្ញុំយល់ដឹងពីផ្ទាំងរូបថតនីមួយៗដែលដាក់តាំងនៅសារមន្ទីរតាម៉ុក។ ពីមុនមក ខ្ញុំធ្លាប់បានចូលមកទស្សនានៅសារមន្ទីរផ្ទះតាម៉ុក និងពិព័រណ៍រូបថតទាំងនេះ ប៉ុន្តែខ្ញុំមិនបានយល់ដឹងអំពីសាច់រឿងនៅក្នុងរូបថតនីមួយៗដូចពេលនេះទេ ដែលមានក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានធ្វើបទបង្ហាញ និងពន្យល់ពីរូបថតនីមួយៗដល់ខ្ញុំ។ ជាការពិត ណាស់ការសិក្សាប្រវត្តិសាស្ត្រតាមរយៈរូបថត គឺបានជួយបង្កើនដល់ការចងចាំបានច្រើន ដោយសារយើងបានមើលឃើញរូបភាពជាក់ស្តែង ដែលអាចឱ្យយើងស្រមើស្រមៃទៅតាមរូបភាពទាំងនោះ។ ខ្ញុំចាប់អារម្មណ៍ទៅលើពិព័រណ៍រូបថត «ប្រជាជនធ្វើការនៅស្រែអំបិល» ក្នុងរបបខ្មែរក្រហម។ រូបថតនេះបានបង្ហាញអំពីការងារនៅកណ្តាលថ្ងៃក្តៅ គ្មានមួកពាក់សមរម្យ ដែលបានធ្វើឱ្យខ្ញុំដឹងពីទុក្ខលំបាក ភាពនឿយហត់របស់ប្រជាជននៅក្នុងរបបខ្មែរក្រហម។

**សូ ស្រីពេជ្រ** ភេទស្រី អាយុ១៥ឆ្នាំ បាននិយាយថា៖ បន្ទាប់ពីខ្ញុំបានទស្សនាពិព័រណ៍រូបថត និងឯកសារ

នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងសារមន្ទីរផ្ទះតាម៉ុក ខ្ញុំពិតជាទទួលបានចំណេះដឹងបន្ថែមពីប្រវត្តិ-សាស្ត្រដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម។ ពិព័រណ៍រូបថតទាំងអស់ដែលដាក់តាំងនៅសារមន្ទីរផ្ទះតាម៉ុក សុទ្ធតែបានបង្ហាញឱ្យឃើញពីរបៀបរបបរស់នៅ ការធ្វើការងាររបស់ប្រជាជនខ្មែរតាំងពីរបបកម្ពុជាប្រជាធិបតេយ្យ រហូតដល់ធ្វើសមាហរណកម្មបញ្ចប់សង្គ្រាម។ ហេតុនេះហើយ ខ្ញុំគិតថា ទុក្ខលំបាកភាពឈឺចាប់ ដែលប្រជាជនខ្មែរបានជួប យុវជនជំនាន់ក្រោយដូចជាខ្ញុំត្រូវតែដឹង ដើម្បីធ្វើយ៉ាងណាកុំឱ្យកើតមានរបបផ្តាច់ការនេះម្តងទៀត។ ខ្ញុំចង់ឱ្យបង្កើតក្រុមសិក្សាបែបនេះជាប្រចាំ ដើម្បីបានសិក្សាស្វែងយល់កាន់តែច្បាស់ពីប្រវត្តិសាស្ត្រដែលបានកើតឡើងកន្លងមក។





*សិស្សអនុវិទ្យាល័យត្រពាំងប្រិយ៍ទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងសារមន្ទីរផ្ទះតាម៉ុក។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*



# ស្ត្រីជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

## ចែករំលែករឿងរ៉ាវនៅក្នុងរបបខ្មែរក្រហម បន្ទាប់ពីបានទស្សនាពិព័រណ៍អចិន្ត្រៃយ៍នៅមជ្ឈមណ្ឌលឯកសារកម្ពុជាសាខាខេត្តព្រៃវែង

ថុន ស្រីពេជ្រ







អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចែករំលែករឿងរ៉ាវនៅក្នុងរបបខ្មែរក្រហម បន្ទាប់ពីបានទស្សនាពិព័រណ៍អចិន្ត្រៃយ៍នៅមជ្ឈមណ្ឌលឯកសារកម្ពុជាសាខាខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៦ ស្ត្រីចំនួន ៤នាក់ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បានមកទស្សនាផ្ទាំងពិព័រណ៍អចិន្ត្រៃយ៍ នៃមជ្ឈមណ្ឌលឯកសារកម្ពុជាប្រចាំខេត្តព្រៃវែង។ គោលបំណង នៃការទស្សនា គឺដើម្បីរំឭកពីការចងចាំ ចែករំលែករឿងរ៉ាវ និងបទពិសោធន៍រស់នៅក្នុងរបបខ្មែរក្រហមដែលនៅដក់ជាប់ក្នុងចិត្តរបស់គាត់ប្រមាណជា៥០ឆ្នាំមកហើយ។

បុគ្គលិកប្រចាំការមជ្ឈមណ្ឌលឯកសារកម្ពុជាសាខាខេត្តព្រៃវែង បានទទួលស្វាគមន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទាំង៤នាក់យ៉ាងកក់ក្ដៅ និងបានចែករំលែកអំពីកិច្ចការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានអនុវត្តកន្លងមក និងផែនការទៅអនាគត ក្នុងគោលបំណងថែរក្សាការចងចាំ និងយុត្តិធម៌។ ក្នុងដំណើរទស្សនកិច្ចនេះ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបានពិនិត្យមើល និងអានសៀវភៅដែលមានរូបថតបង្ហាញពីសកម្មភាពការងារប្រចាំថ្ងៃរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តព្រៃវែង រូបថតអ្នកទោស និងរូបថតមេដឹកនាំខ្មែរក្រហម បានជំរុញឱ្យអ្នកទាំងបួននាក់ចែករំលែកសាច់រឿងនៃការបាត់បង់សាច់ញាតិ ការតក់ស្លុត ការអត់ឃ្លាន ការស្អប់របបខ្មែរក្រហម ទៅកាន់បុគ្គលិកមជ្ឈ-

មណ្ឌលឯកសារកម្ពុជា សាខាខេត្តព្រៃវែង។

**ខន ខិនី** ភេទស្រី អាយុ៦០ឆ្នាំ រស់នៅភូមិលេខ៣ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង បានចែករំលែកថា៖ នៅក្នុងរបបខ្មែរក្រហម សមាជិកក្រុមគ្រួសាររបស់ខ្ញុំបានស្លាប់អស់ជាច្រើននាក់។ ចាប់តាំងពីនោះមក ខ្ញុំត្រូវក្លាយជាក្មេងកំព្រានៅអាយុ១២ឆ្នាំ។ ហេតុនេះ ខ្ញុំស្អប់របបខ្មែរក្រហម ព្រោះរបបនេះបានសម្លាប់ឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំ។ ខ្មែរក្រហមបានចាត់ទុកខ្ញុំជាប្រជាជនថ្មី ហើយនៅពេលចេញទៅធ្វើការនៅតាមការដ្ឋានម្តងៗ ខ្មែរក្រហមតែងតែឱ្យខ្ញុំច្រៀងបទ«ឈាមក្រហមឆ្អៅ»។ សម័យនោះ យោធាខ្មែរក្រហមមានវ័យក្មេងៗ និងស្ពាយកាំភ្លើងអូសដី ប៉ុន្តែប្រជាជនខ្លាចយោធាក្មេងៗទាំងនោះខ្លាំងណាស់។

**អ៊ំ សាខន** ភេទស្រី អាយុ៧៥ឆ្នាំ រស់នៅភូមិលេខ៣ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង បានរៀបរាប់ថា៖ ខ្ញុំមិនមានគំនិតស្អប់របបខ្មែរក្រហមទេ ប្រសិនបើខ្មែរក្រហមមិនសម្លាប់មនុស្ស មិនបង្អត់បាយប្រជាជន គឺរបបនេះនឹងមិនងាយដួលរលំទេ។ នៅក្នុងរបបខ្មែរក្រហម ប្តីរបស់ខ្ញុំគឺត្រូវខ្មែរក្រហមយកទៅសម្លាប់។ ខ្ញុំមិនត្រឹមតែបាត់បង់ប្តីទេ គឺបាត់បង់សាច់ថ្លៃសឹងតែទាំងអស់។ ខ្ញុំគិតថា ប៉ុល ពត, ខៀវ សំផន មិនមែនជាអ្នកបញ្ជាទេ គឺកម្មាភិបាលខ្មែរក្រហមនៅតាមមូលដ្ឋានជាអ្នកយកប្តីខ្ញុំទៅសម្លាប់។ នៅសម័យនោះ ប្រធានកងចាត់តាំងខ្ញុំឱ្យធ្វើការនៅតាមកងចល័ត ហើយនៅពេលខ្ញុំចង់បត់ដៃបត់ជើង ខ្ញុំត្រូវស្រែកសុំការអនុញ្ញាតពីប្រធានកងជាមុន។

**សេង ធន់សុធា** ភេទស្រី អាយុ៥៦ឆ្នាំ រស់នៅភូមិលេខ៣ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង បានលើកឡើងថា៖ នៅក្នុងរបបខ្មែរក្រហម ប្រសិនបើថ្នាក់លើមិនបញ្ជាឱ្យសម្លាប់ប្រជាជនទេ គឺថ្នាក់ក្រោមមិនហ៊ានយកប្រជាជនទៅសម្លាប់ទេ។ ខ្មែរក្រហមបានធ្វើបាបប្រជាជន ដោយបានចាត់តាំងប្រជាជនឱ្យធ្វើការងារជាទម្ងន់។ កម្មាភិបាលខ្មែរក្រហមសុទ្ធតែពាក់មួក ស្លៀកពាក់ខោអាវថ្មីៗ ចំណែកប្រជាជនមិនមានមួក និងសម្លៀកបំពាក់ថ្មីទេ គឺមានតែក្រមាមួយ និងខោអាវចាស់ៗតែប៉ុណ្ណោះ។

**សេង ថា** ភេទស្រី អាយុ៦៤ឆ្នាំ រស់នៅភូមិលេខ៣ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង រៀបរាប់ថា៖ ខ្ញុំមិនស្គាល់មុខមាត់របស់ ប៉ុល ពត ទេ ព្រោះនៅក្នុងរបបខ្មែរក្រហម ខ្ញុំគិតតែពីធ្វើការទៅតាមបញ្ជារបស់កម្មាភិបាលក្នុងមូលដ្ឋាន ព្រោះកម្មាភិបាលប្រធានឃុំ និងប្រធានភូមិ មានសិទ្ធិចាប់ប្រជាជនយកទៅសម្លាប់។ របបខ្មែរក្រហម កម្មាភិបាលក្មេងៗខ្មែរក្រហមមួយចំនួនគឺជាអ្នករាយការណ៍ទៅថ្នាក់លើឱ្យចាប់ឪពុកម្តាយបង្កើតរបស់ខ្លួនយកទៅសម្លាប់។

មុននឹងបញ្ចប់ការទស្សនាពិព័រណ៍អចិន្ត្រៃយ៍ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តព្រៃវែង ដារ៉ាវ័ត្ន មេត្តា បានពិភាក្សាអំពីសារសំខាន់នៃការចែករំលែករឿងរ៉ាវឆ្លងកាត់របបខ្មែរក្រហមជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ មេត្តាបានលើកឡើងថាជាការចូលរួមកសាងប្រវត្តិសាស្ត្រមួយនាពេលអនាគត គឺជាផ្នែកដ៏សំខាន់ដើម្បីជួយទប់ស្កាត់កុំឱ្យមានអំពើប្រល័យពូជសាសន៍។ សកម្មភាពក្នុងថ្ងៃនេះគឺដើម្បីលើកទឹកចិត្តដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមឱ្យចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនទៅកាន់កូនចៅៗរបស់ខ្លួន ដើម្បីជាការចងចាំ និងបង្កើតការសន្ទនាអន្តរជំនាន់។



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចែករំលែករឿងរ៉ាវនៅក្នុងរបបខ្មែរក្រហម បន្ទាប់ពីបានទស្សនាពិព័រណ៍អចិន្ត្រៃយ៍នៅមជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ការិយាល័យព័ត៌មានសាធារណៈ
















«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍អំពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ធនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់បតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង រស់ សំពៅ អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៨៨២ ៥០៥ ឬ

អ៊ីម៉ែល ៖ truthsampeou.r@dccam.org

សូមអរគុណ!














# ជាតិនេះ ខ្ញុំប្រិះតែនឹងស្លាប់ចំនួន១៤លើក (ត)

សៀវ សុផុន



*សៀវ សុផុន បួសជាព្រះសង្ឃនៅវត្តល្ងា អំឡុងឆ្នាំ១៩៧០ និងឆ្នាំ១៩៧១។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ឪពុក-ម្តាយ របស់ខ្ញុំជាក់ជាពុំខាន។ នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ គឺមុនខ្មែរក្រហមវាយរំដោះទីក្រុងភ្នំពេញមួយថ្ងៃ ប៊ុនធឿន បានជិះកង់ប្រុសម៉ាក់ Peugeot បាញ់ថ្នាំថ្មីពណ៌ស្វាយកំភេម ចេញពីផ្ទះរបស់ខ្លួននៅម្តុំឃ្លាំងរំសេវ មកអើតមើលខ្ញុំដែលជួលផ្ទះថ្មមួយល្វែងដើម្បីរស់នៅម្តុំផ្សារអូឡាំពិច ទាំងកណ្តាលព្រឹកព្រម ទាំងមានទឹកមុខស្រពាប់ស្រពោន។ ព្រឹកនោះ ប៊ុនធឿន ស្លៀកខោខ្ឡូវជើងវែងពណ៌ខ្មៅ ពាក់អាវដៃខ្លីតេតារ៉ុង ពណ៌កាគី និងពាក់មួកសម្បុកពណ៌ខ្មៅ អង្គុយនិយាយនៅលើកង់មកកាន់ខ្ញុំ ព្រោះខ្ញុំឈរនៅក្បែរគ្នាដែរ។ ពេលនោះទោះបីជាខ្ញុំឱ្យគាត់ចុះមកអង្គុយលេងនៅលើកៅអីទាំងអស់គ្នាក៏គាត់ពុំព្រមដែរ ដោយនិយាយបដិសេធថា អញប្រញាប់ទៅវិញព្រោះមានធុរៈផ្ទាល់ខ្លួនបន្តិចៗ បន្ទាប់មក ប៊ុនធឿន ដកយកអាម៉ូនីកា (ឧបករណ៍ផ្លុំទភ្លេង) ចេញពីចង្កេះខោរបស់ខ្លួន និងហុចមកឱ្យខ្ញុំទុកជាវត្ថុអនុស្សាវរីយ៍ រួចហើយក៏ជិះកង់ចេញទៅវិញ ហើយចាប់តាំងពីពេលនោះខ្ញុំបាត់ដំណឹងគាត់រហូត។ លុះក្រោយឆ្នាំ១៩៧៩ ទើបខ្ញុំដឹងច្បាស់ថា ប៊ុនធឿន ពិតជាស្លាប់ប្រាកដមែន។ ខ្ញុំតែងតែនឹករឭក ប៊ុនធឿន ជានិច្ច ពិសេសគឺយើងបន្សល់អនុស្សាវរីយ៍គ្រប់ទីកន្លែងក្នុងក្រុងសៀមរាប និងនៅឯរាជធានីភ្នំពេញ។ ការបាត់បង់ ប៊ុនធឿន ហាក់បីដូចជាបាត់បង់របស់យ៉ាងសំខាន់សម្រាប់ខ្ញុំ ទោះបីជាខ្ញុំខិតខំបន់ស្រន់ដល់ព្រះឥន្ទព្រះព្រហ្មណ៍ យមរាជ ឱ្យមកជួយរក ប៊ុនធឿន ក៏ពុំអាចរកឃើញដែរ។ ខ្ញុំបានត្រឹមតែសោកស្តាយនៅក្នុងចិត្តតែម្នាក់ឯងតែប៉ុណ្ណោះ។ លុះរយៈពេល៣៦ឆ្នាំក្រោយមក គឺមកដល់ឆ្នាំ២០១៥ នាល្ងាចថ្ងៃអាទិត្យ គឺក្រោយពេលចេញព្រះវស្សារួច ទើបខ្ញុំបានជួបមនុស្សសំខាន់ម្នាក់នៅភោជនីយដ្ឋានអាប៉ូឡូប្រាសាទ ក្នុងក្រុងសៀមរាប គឺនៅពេលចូលរួមពិធីអាពាហ៍ពិពាហ៍របស់គ្រួសារមួយ ដែលខ្ញុំពុំចាំឈ្មោះ ទើបខ្ញុំទទួលព័ត៌មានសំខាន់ដែលខ្ញុំអន្ទះសាប្រាថ្នាចង់ដឹងជាយូរមកហើយ។ មនុស្សប្រុសម្នាក់នោះឈ្មោះ តាន់ ស៊ីថា ឬ ព្រឿន ស៊ីថា ហៅចូច ឬ មោង គឺជាប្អូនជីដូនមួយបង្កើតនឹង ប៊ុនធឿន ដែលមានអាយុដំណាលគ្នានឹងប៊ុនធឿនដែរ។ ស៊ីថាបាននិយាយរឿង ប៊ុនធឿន ប្រាប់ខ្ញុំគ្រប់ជ្រុងជ្រោយរហូតដល់យើងអាចយកជាផ្លូវការបាន។ ស៊ីថា និយាយបន្តថា ប៊ុនធឿនដើរជាមួយគាត់រហូតមក ប្រសិនបើ ប៊ុនធឿន នៅរស់ម្ល៉េះសមនឹងបានមកជួបមុខម្តាយ និងប្អូនស្រីរបស់ខ្លួនវិញជាក់ជាពុំខាន ហើយខាងក្រោមគឺដំណើររឿងដែល ស៊ីថា នៅចងចាំ៖

ស៊ីថា និង ប៊ុនធឿនបានជិះកង់ម្នាក់មួយគ្រឿងចេញមកពីព្រែកពោធិ៍ស្ថិតក្នុងទឹកដីនៃខេត្តកណ្តាល ដោយមានឌុបអីវ៉ាន់ពីក្រោយកង់រៀងៗខ្លួន សំដៅទៅជួបមុខឪពុកម្តាយរបស់ខ្លួនដែលរស់នៅក្នុងភូមិថ្នល់បែក ឃុំកៀនសង្កែ ស្រុកសូទ្រនិគម ខេត្តសៀមរាប។ ស៊ីថា និង ប៊ុនធឿន បានមកដល់ភូមិអូរ ស្ថិតនៅក្នុងឃុំសង្វើយ ស្រុកជីក្រែង ខេត្តសៀមរាប ក៏ជួបអ្នកជម្លៀសដូចគ្នាឈ្មោះសែតប៊ុនសុងភេទប្រុសគឺជាអ្នកស្រុកសូទ្រនិគមដែរ។ សែត ប៊ុនសុង បាននិយាយពិគ្រោះគ្នាថា យើងបានរត់ពីដីដែកចូលទៅក្រុងសៀមរាប ដែលជាគូសត្រូវរបស់ខ្មែរក្រហម។ ក្រោយមកខ្មែរក្រហមបានវាយឈ្នះរដ្ឋាភិបាលលន់ នល់ ព្រមទាំងជម្លៀសយើងចេញមកវិញ ប៉ុន្តែបែរជាយើងទៅសុំជ្រកកោននឹងខ្មែរក្រហមដែលជាក្រុមបិសាចនិងធ្លាប់ជាមនុស្សកោងកាចខ្លាចក្រែងតែសម្លាប់យើងចោល។ ពេលឮពាក្យថាសម្លាប់ ស៊ីថា និង ប៊ុនធឿនបានពិគ្រោះគ្នារួចហើយសម្រេចចិត្តជិះកង់ត្រឡប់ក្រោយវិញ ដោយគ្មានរួញរាក្នុងចិត្តបន្តិចណាឡើយ។ ពេលអ្នកទាំងពីរ

មកដល់ព្រែកពោធិ៍ក្នុងទឹកដីនៃខេត្តកណ្ដាល ក៏បានជួបជុំគ្រួសាររបស់ ប៊ុនធឿនវិញ ពិសេសគឺបងស្រី ប៊ុនធឿន ធ្វើជាគ្រូបង្រៀនពីសង្គមចាស់ឈ្មោះ គាន់ គឹមអន និងប្ដីធ្វើជាគ្រូបង្រៀនដូចគ្នា ដែលមានស្រុកកំណើតនៅព្រែកពោធិ៍ នេះដែរ។ មិនយូរប៉ុន្មានខ្មែរក្រហមធ្វើការជម្លៀសគ្រួសារ គាន់ គឹមអន បន្តទៀត។ ទិសដៅដែលខ្មែរក្រហមជម្លៀសក្រុមគ្រួសារនេះម្ដងទៀត គឺឱ្យដើរឡើងទៅខាងលើព្រែកពោធិ៍ឆ្ពោះទៅកាន់ភូមិខ្ទីង ដែលមានចម្ងាយ៧០ទៅ៨០គីឡូម៉ែត្រ និងសម្បូរណ៍ដោយជំងឺគ្រុនចាញ់។ ដោយឡែក ស៊ីថា បានធ្វើការពិចារណាម្នាក់ឯងថា ប្រសិនបើខ្លួនត្រឡប់ទៅស្រុកកំណើតក៏ស្លាប់! ហើយបើជម្លៀសទៅកាន់ភូមិខ្ទីង ក៏ស្លាប់! ដូច្នេះ ស៊ីថា បានសម្រេចជ្រើសរើសយកជម្រើសទី១ គឺវិលត្រឡប់ទៅស្រុកកំណើត ហើយប្រសិនបើស្លាប់រស់យ៉ាងណាគឺបានជួបមុខឪពុកម្ដាយ និងបងប្អូនរបស់ខ្លួនវិញ។ មិនបង្អង់យូរ ស៊ីថាបានដើរកាត់តម្រង់មកកាន់ភូមិកំណើតរបស់ខ្លួនវិញតែម្នាក់ឯងរីឯចរាចរនៅតាមផ្លូវក៏ពុំដូចមុនដែរ ព្រោះខ្មែរក្រហមស្ទាក់ផ្លូវនៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដើម្បីឱ្យអ្នកដំណើរធ្វើប្រវត្តិរូប និងចុះឈ្មោះជាអ្នកស្រុករស់នៅជាអចិន្ត្រៃយ៍ក្នុងភូមិមួយដែលសុទ្ធសឹងតែជាជនជាតិដើមភាគតិចកួយ ដែលមានប្រពៃណីស្លដែក និងមានពាក្យដាវដែកកំពង់ស្វាយរហូតមក។ ស៊ីថា ចេះនិយាយភាសាកួយបានមួយចំនួនធំ និងរស់នៅទីនោះរហូតដល់ឆ្នាំ១៩៧៩។ បន្ទាប់មក ស៊ីថា បានវិលត្រឡប់ទៅជួបជុំក្រុមគ្រួសារនៅស្រុកកំណើត និងរៀបការប្រពន្ធមានកូន និងសង់ផ្ទះសម្បែងរស់នៅបានសមរម្យស្ថិតនៅតាមបណ្ដោយផ្លូវជាតិលេខ៦ ក្នុងភូមិចុងកៅស៊ូ ក្រុងសៀមរាប។ ស៊ីថា ទើបទទួលមរណភាពនៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ ដោយជំងឺថ្លើម ក្នុងអាយុ៧០ឆ្នាំ។ ចំណែក សែត ប៊ុនសុង បានទៅរស់នៅជាមួយឪពុកឈ្មោះ ថ្វាង សែត និងម្ដាយឈ្មោះ ឆាយ សូត្រ នៅភូមិគោកសង្កែ ឃុំខ្នាស់ ស្រុកសូទ្រនិគម ក្រោយពីខ្មែរក្រហមជម្លៀសចេញពីភូមិគោកមនក្នុងស្រុកសូទ្រនិគមដដែល។ សែត ប៊ុនសុង បានធ្វើមរណកាល ដោយជំងឺថ្លើមនៅដើមឆ្នាំ២០២០ ក្នុងអាយុ៧២ឆ្នាំ នៅភូមិព្រះត្រពាំង ឃុំដំដែក ស្រុកសូទ្រនិគមខេត្តសៀមរាប។

## លើកទី៣ ដូរផ្ទះពីស្លាកចាស់ ទៅនៅឃ្លាំងរំសេវ (ក្រុងភ្នំពេញ)

នៅឆ្នាំ១៩៧៣ គឺនៅពេលដែលខ្ញុំជិះយន្តហោះយោធាពណ៌ប៉ារ៉ា មានចុងកន្ទុយបះទៅលើបន្តិចធុន ស៊ី-១២៣ ចេញពីវាលយន្តហោះថ្មីផ្សារក្រោមក្រុងសៀមរាបទៅកាន់ក្រុងភ្នំពេញ។ ពេលទៅដល់ភ្នំពេញភ្លាម ខ្ញុំបានពឹងមិត្តភក្ដិម្នាក់ឈ្មោះ អាំងប៊ុនធិឱ្យជូនទៅលេងផ្ទះសម្លាញ់ ប៊ុនធឿន ព្រោះ ប៊ុនធឿន ចេញទៅរៀននៅភ្នំពេញមុនខ្ញុំបន្តិច។ ប៊ុនធឿន គ្រាន់តែឃើញខ្ញុំភ្លាមក៏លោតចុះពីលើគ្រែក្រោមផ្ទះមកដី ហើយបានស្រែកខ្លាំងៗប្រាប់បងស្រីថា៖ ចែអើយ! អាផុន! មិត្តភក្ដិខ្ញុំវាមកពីសៀមរាបហើយ! ព្រមទាំងសើចក្អាកក្អាយសប្បាយចិត្តឥតឧបមា ព្រោះខ្ញុំពុំបានផ្ដល់ដំណឹងជាមុនឱ្យវាបានដឹងឡើយ។ ជារៀងរាល់ព្រឹក ខ្ញុំមានទម្លាប់ដឹកទឹកពាងបីក្អឹក តំណាងឱ្យព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ រួចហើយទើបជិះកង់ចេញទៅសាលារៀន និងពេលត្រឡប់មកដល់ផ្ទះវិញ បានដាំបាយ ហូបជាមួយមុខម្ហូបក្រៀមក្រោះ អាំង-ដុត តែម្នាក់ឯងអស់ជាច្រើនឆ្នាំ។ ទោះបីជាខ្ញុំស្ថិតក្នុងសភាពទុក៌តយ៉ាងដូច្នេះក៏ដោយ ប៉ុន្តែលទ្ធផលនៃការសិក្សារៀនសូត្រវិញ គឺតែងទទួលបានផ្លែផ្កាដែលឪពុកម្ដាយប្រាថ្នាចង់បាន។

នៅឆ្នាំ១៩៧៣ ពេលខ្ញុំដាក់ពាក្យស្នើសុំចូលរៀនដំបូងនៅវិទ្យាល័យ



ផ្លូវនៅមាត់ស្ទឹងសៀមរាបត្រើយខាងលិច ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៧៤។ ទី១) អ៊ុង វិជ្ជោ ហៅ ប៊ុនធឿន ធាក់រ៉ឺម៉ក (ស្លាប់) ទី២) សៀវ សុផុន អង្គុយខាងក្រោយ ដាក់ដៃលើជង្គង់ និង ៣) លិម ប៊ុនសឹង អង្គុយជាប់ សៀវ សុផុន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

យុវជនស្រោចស្រង់ជាតិ ឬ សរសេរពេញតាមភាសាបារាំង (Jeunesse de Sauvetage) ឯទីក្រុងភ្នំពេញ គឺក្រោយពីលោកចាងហ្វាងសាលាបានឃើញនិទ្ទេស BIBN នៅលើសញ្ញាប័ត្របឋមរបស់ខ្ញុំ ដែលចារដោយទឹកប៊ិចពណ៌ក្រហមរួចហើយ លោកញញឹម និងសម្លឹងមើលមុខខ្ញុំ បន្ទាប់មកសរសេរលិខិតតូចមួយដោយបានណែនាំខ្ញុំឱ្យកាន់សំបុត្រនេះទៅជួបលេខាការីរបស់គាត់នៅបន្ទប់ផ្សេងមួយទៀតដើម្បីជ្រើសរើសយកថ្នាក់រៀន។ កាលដែលខ្ញុំប្រឡងបឋមនៅក្នុងក្រុងសៀមរាបនាសម័យសង្គម បេក្ខជនជាប់និទ្ទេស Mention BIEN គឺមានចំនួនបីបួននាក់តែប៉ុណ្ណោះដែលប្រកបដោយគុណភាព ព្រោះពីដើមសិស្សមានចំនួនតិចជាងពេលបច្ចុប្បន្ននេះឆ្ងាយណាស់។ រីឯដង់ស៊ីតេប្រជាជនរស់នៅក្នុងក្រុងភ្នំពេញគឺមានចំនួនខ្ពស់ខុសប្រក្រតីរហូតដល់មានពាក្យចចាមអារ៉ាមដែលខ្ញុំឮមុននឹងចេញដំណើរពីខេត្តសៀមរាបមកថា សិស្សនៅភ្នំពេញក្នុងថ្នាក់រៀនីមួយៗ មានចំនួនច្រើនលើសលប់រហូតដល់សាលាកម្រនឹងទទួលយកសិស្សថ្មីឱ្យចូលរៀន។

នៅតំបន់ស្ដាតចាស់គឺខ្ញុំរស់នៅជ្រកកោនរៀនសូត្រជាមួយម្ដាយមីងបង្កើតឈ្មោះ សៀវ លឿម និងប្ដីរបស់គាត់គឺជាទាហានពាក់ស័ក្តិ៣ឈ្មោះ ហេង ស្រី ជាអតីតគ្រូបង្រៀនពីសង្គមចាស់ និងមានកូនប្រុសស្រីសរុបចំនួន៧ នាក់។ ក្រោយមក ឪពុកមារបស់ខ្ញុំពីរនាក់ដែលជាជនភៀសសឹក ម្នាក់ឈ្មោះ សែត ប៊ុនសុង និងម្នាក់ទៀតឈ្មោះ សែត ស៊ិនថៃបានរត់ពីស្រុកកំណើតក្នុងតំបន់ខ្មែរក្រហមមករស់នៅជាមួយខ្ញុំដែរ។ ម្ដាយមីងខ្ញុំ សៀវ សឿម ទទួលរ៉ាប់រងបន្ទុកនៃការហូបចុកកាន់តែធ្ងន់ធ្ងរ។ ដោយមើលឃើញដូច្នេះ ខ្ញុំបានផ្ដល់ដំណឹង និងជម្រាបទៅឪពុករបស់ខ្ញុំឈ្មោះ សៀវ ជុនលី នៅខេត្តសៀមរាប។ ឪពុករបស់ខ្ញុំកំពុងរៀបចំដំឡើងម៉ាស៊ីនកិនស្រូវមួយគ្រឿងនៅភូមិសន្ទាន់ ឃុំទឹកវិល ស្រុកពួក ដែលដើមឡើយរោងម៉ាស៊ីនស្រូវនេះស្ថិតនៅស្ពានថ្លាំង ក្នុងភូមិថ្លាំង ឃុំព្រៃជ្រូក ស្រុកពួក។ ខ្ញុំជម្រាបឪពុកខ្ញុំដើម្បីសុំប្ដូរផ្ទះមករស់ជាមួយមិត្ត ប៊ុនធឿន។ ឪពុកខ្ញុំពុំមានជំទាស់ឡើយ ហើយថែមទាំងផ្ញើថវិកាមកឱ្យខ្ញុំដើម្បីផ្ដល់ជូនម្ដាយមីងដែលត្រូវជាប្អូនស្រីពៅរបស់គាត់ ក្នុងការទូទាត់រ៉ាល់ការចំណាយគ្រប់សព្វជុំវិញការរស់នៅរបស់ខ្ញុំក្នុងពេលកន្លងមក។ ក្រោយពីជម្រាបជូនដំណឹងក្នុងការផ្លាស់ប្ដូរកន្លែងរស់នៅដល់ម្ដាយមីង និងឪពុកមាបានជ្រះស្រឡះរួចហើយ រយៈពេលប្រមាណជាមួយសប្ដាហ៍ក្រោយមក ប៊ុនធឿនមកជួយដឹកអីវ៉ាន់របស់ខ្ញុំមកកាន់ម្ដុំឃ្លាំងរំសេវ គឺជាផ្ទះបងស្រី តាន់ គឹមអន និងបងប្រុស តាន់ ឡាំហឿន ដែលជាបងបង្កើតរបស់ ប៊ុនធឿន។ ផ្ទះនោះគឺជាប្រភេទឈើ មានជញ្ជាំងក្ដារប្រក់ស័ង្កសី សង់ខ្ពស់ផុតពីដី និងមានពីរផ្ទះជាប់ជញ្ជាំងគ្នា។ នៅត្រង់ចំណុចនេះដែលបញ្ជាក់ថា ខ្ញុំបានរួចផុតពីស្លាប់លើកទី២ មូលហេតុគឺគ្រួសារម្ដាយមីង សៀវ លឿម និងប្ដីរួមជាមួយកូនប្រុសស្រីទាំង៧ នាក់ គឺនៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ត្រូវបានខ្មែរក្រហមសម្លាប់ចោលទាំងអស់ នៅក្នុងភូមិរំលោង ឃុំទ្រៀល ស្រុកបារាយណ៍ ខេត្តកំពង់ធំ។

## លើកទី៤ ដោះដូរផ្ទះជាថ្មីម្ដងទៀត

ខ្ញុំរស់នៅជាមួយប៊ុនធឿនពិសេសគឺជ្រកកោនក្រោមផ្ទះអ្នកគ្រូ តាន់គឹមអន និងប្ដីរបស់គាត់គឺខ្ញុំទទួលបានភាពងាយស្រួល និងសុខសប្បាយជាធម្មតា។ ប៊ុនធឿន ជាអ្នករ៉ាប់រងទៅទិញឈើសម្បកកែសគ្រាប់វែងៗ នៅឯព្រលានយន្តហោះពោធិ៍ចិនតុង មកធ្វើជាគ្រែឱ្យខ្ញុំដេក ព្រមទាំងធ្វើបន្ទប់មានទ្វារចាក់សោរដោយឡែកមួយសម្រាប់ខ្លួនខ្ញុំផ្ទាល់។ នៅក្រោមផ្ទះភ្លោះនេះ គឺមានចាក់សាបស៊ីម៉ង់ត៍ស្អាតល្អ មានបន្ទប់ទឹកសង់ពីថ្មចំនួនពីរ ដាច់ដោយឡែកពីគ្នា មានគ្រែធ្វើពីឈើធំមួយដើម្បីអង្គុយលេង និងមានតុកៅអីសម្រាប់អង្គុយបរិភោគអាហារទៀតផង។ ដោយឡែកចំពោះខ្ញុំម្នាក់ឯង គឺទៅហូបបាយដាក់ខែនៅខាងក្រៅ ទោះបីជាបង គឹមអន ធានាដាំឱ្យហូប ប៉ុន្តែខ្ញុំសុំអង្វរគាត់កុំឱ្យដាំជានិច្ច។ ជួនកាលប្រពន្ធរបស់បងប្រុស តាន់ ឡាំហឿង បានពឹងពាក់ខ្ញុំឱ្យជិះម៉ូតូឌុបគាត់ទៅផ្សារដេអ៊ីននៅជិតវិមានឯករាជ្យ និងបានឆៀងជូនគាត់មួយភ្លែតចូលទិញបន្លែផ្លែឈើ ត្រីសាច់នៅក្នុងផ្សារតូចមួយស្ថិតនៅខាងស្ដាំដៃ ទើបត្រឡប់មកផ្ទះវិញ។

ក្នុងមួយថ្ងៃៗ ខ្ញុំត្រូវជិះកង់ចេញពីឃ្លាំងរំសេវទៅរៀននៅស្ដាតចាស់ គឺកាន់តែឆ្ងាយទៅៗ ដែលបានញ៉ាំងឱ្យខ្ញុំនឿយណាយក្នុងចិត្ត និងចង់ដូរកន្លែងរស់នៅសាជាថ្មីម្ដងទៀតដើម្បីបាននៅជិតសាលារៀនជាងនេះបន្តិច។ មិនយូរប៉ុន្មានបងថ្លៃប្រុស ស៊ិន ម៉េង ដែលត្រូវជាប្ដីរបស់បងស្រីជីដូនមួយបង្កើតខ្ញុំឈ្មោះ អាំង គឹមភន់ ធ្វើជាគ្រូបង្រៀន បានទៅសុំពួកម៉ាកគាត់ម្នាក់ឈ្មោះ ឈន់ ថុង ហៅ កាំង គឺជាគ្រូពេទ្យដូចគាត់ដែរ ដើម្បីផ្ញើខ្ញុំឱ្យស្នាក់នៅផ្ទះជាមួយ។ មិត្តភក្តិរបស់បង ស៊ិន ម៉េង ពុំយល់ទាស់អ្វីទេ និងបានយល់ព្រមទទួលយករូបខ្ញុំឱ្យទៅរស់នៅក្នុងផ្ទះល្វែងមួយ រួមជាមួយប្អូនប្រុសបង្កើតរបស់គាត់ម្នាក់ឈ្មោះ កាំង ប៊ួយ រៀនពេទ្យឆ្នាំទី៣ និងប្អូនប្រុសជីដូនមួយគាត់ម្នាក់ទៀតឈ្មោះ លឹម ទ្រី (ភ្នែកម្ទូប) គឺជា

**(តទៅលេខក្រោយ)**

រូបក្របមុខ៖
កុមារកំព្រាក្រោយរបបខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩ នៅមុខប្រាសាទអង្គរវត្ត។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា/ភ្នាក់ងារសារព័ត៌មានវៀតណាម)

រូបក្របក្រោយ៖
កុមារកំពុងធ្វើការនៅតាមការដ្ឋានក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណះ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ៧៨ ៦៩៨ ៣៣៣

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chaktomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 317, April 2026
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.